# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

# របាយការណ៍
## ស្ដីពី
# ការបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៥
# និងលើកទិសដៅការងារ ឆ្នាំ២០២៦
# ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ




ព.ស. ២៥៦៩
ក.ស. ២០២៥

# មាតិកា

ទំព័រ

**១. ការអនុវត្តអនុសាសន៍ ១០ចំណុច របស់សម្តេចធិបតីនាយករដ្ឋមន្ត្រី ........ ២**

**២. លទ្ធផលការងារសំខាន់ៗ ដែលសម្រេចបាន ........ ៥**

២.១. ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម ........ **៥**

២.១.១. ការពង្រឹងការអនុវត្តគោលនយោបាយ និងសិក្សាស្រាវជ្រាវ ........ ៥

២.១.២. ការពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាស្វែងរកការងារ និងវេទិកាការងារ ........ ៨

២.១.៣. ការពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ ........ ១០

២.១.៤. ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស តាមរយៈបច្ចេកវិទ្យាឌីជីថល. ១០

២.១.៥. ការពង្រឹងការអនុវត្តគោលនយោបាយជាតិ ស្តីពីមុខរបរនិងការងារ និងកម្មវិធីជំរុញ ការលើកកម្ពស់ផលិតភាពការងារ ........ ១១

**២.២. ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ........ ១២**

២.២.១. ការពង្រឹងប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមបច្ចេកវិទ្យាឌីជីថល ........ ១២

២.២.២. ការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ........ ១៣

២.២.៣. ការពង្រឹង និងពង្រីកការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញ ........ ១៤

២.២.៤. ការពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍ ........ ១៧

២.២.៥. ការជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ........ ១៧

**២.៣. ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ .. ១៨**

២.៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច និងយន្តការអធិការកិច្ចការងារ ........ ១៨

២.៣.២. ការលើកកម្ពស់លក្ខខណ្ឌ ស្តីពីសុវត្ថិភាព និងសុខភាពការងារ ........ ២០

២.៣.៣. ការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ ........ ២១

២.៣.៤. ការពង្រឹងសមត្ថភាពស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងការពិភាក្សា កំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត ........ ២២

២.៣.៥. ការលើកកម្ពស់សុខដុមនីយកម្ម នៃទំនាក់ទំនងវិជ្ជាជីវៈ ........ ២៤

**២.៤. ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព........ ២៧**

២.៤.១. ការពង្រឹង និងពង្រីកទីផ្សារការងារនៅបរទេសដែលមានលក្ខខណ្ឌការងារល្អ ........ ២៧

២.៤.២. ការពង្រឹងយន្តការ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការជ្រើសរើស ការបណ្តុះបណ្តាល និងការបញ្ជូនពលករទៅធ្វើការនៅបរទេស ........ ២៧

២.៤.៣. ការពង្រឹងយន្តការគ្រប់គ្រង និងសេវាគាំពារនៅតាមប្រទេសទទួល ដល់ពលករទេសន្តរប្រវេសន៍កម្ពុជា ........ ២៩

២.៤.៤. ការពង្រឹងយន្តការ នៃការធ្វើសមាហរណកម្មពលករទេសន្តរប្រវេសន៍កម្ពុជា ដែលធ្វើមាតុភូមិនិវត្តន៍ ........ ៣០
២.៤.៥. ការពង្រឹងការគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជា ........ ៣២
**២.៥. ការអភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្ត នៃស្ថានភាពសង្គម-សេដ្ឋកិច្ច ........ ៣២**
២.៥.១. ការពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម ........ ៣២
២.៥.២. ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម ........ ៣៦
២.៥.៣. ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម ........ ៣៨
២.៥.៤. ការពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គម ........ ៣៨
២.៥.៥. ការអភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម ........ ៣៩
**២.៦. ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅ ........ ៣៩**
២.៦.១. ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក ........ ៣៩
២.៦.២. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានឱ្យកាន់តែមានប្រសិទ្ធភាពស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ........ ៤០
២.៦.៣. អភិវឌ្ឍសមត្ថភាពមន្ត្រី គ្រប់គ្រងចំណេះដឹង គ្រប់គ្រងស្ថិតិ និងកសាងលិខិតបទដ្ឋានគតិយុត្ត ៤១
២.៦.៤. ពង្រឹងភាពជាម្ចាស់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ សមភាពយេនឌ័រ និងសេវាសង្គម ........ ៤៣
២.៦.៥. ពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ ........ ៤៥
**៣. បញ្ហាប្រឈម ........ ៤៦**
**៤. ទិសដៅអនុវត្តការងារបន្ត ........ ៤៨**
**៥. សេចក្តីសន្និដ្ឋាន ........ ៥២**

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

# របាយការណ៍
# ស្តីពី
# ការបូកសរុបលទ្ធផលការងារ ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦
# របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ

ឈរលើមូលដ្ឋានគ្រឹះដ៏រឹងមាំនៃសុខសន្តិភាព និងការអភិវឌ្ឍដែលត្រូវបានកសាងឡើងក្នុងរយៈពេលជាងពីរទសវត្សរ៍កន្លងមកនេះ កម្ពុជាបាននិងកំពុងបន្តដំណើរឆ្ពោះទៅមុខប្រកបដោយភាពជឿជាក់ក្នុងនីតិកាលទី៧នៃរដ្ឋសភា។ ក្រោមការដឹកនាំដ៏ស្វាហាប់ និងប្រកបដោយចក្ខុវិស័យវែងឆ្ងាយរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** រាជរដ្ឋាភិបាលបានដាក់ចេញ និងកំពុងជំរុញការអនុវត្ត **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** យ៉ាងសកម្ម ដើម្បីធានាបាននូវកំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព សំដៅប្រែក្លាយកម្ពុជាឱ្យទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។ ក្នុងស្មារតីនេះ ការបន្តកែទម្រង់ និងការពង្រឹងភាពធន់នៃវិស័យសេដ្ឋកិច្ច-សង្គម ត្រូវបានចាត់ទុកជាអាទិភាពខ្ពស់បំផុត ដើម្បីឆ្លើយតបនឹងការផ្លាស់ប្តូរយ៉ាងឆាប់រហ័សនៃរចនាសម្ព័ន្ធសេដ្ឋកិច្ច ការងារ និងភូមិសាស្ត្រនយោបាយ។

យ៉ាងណាមិញ ឆ្នាំ២០២៥ បានក្លាយជាឆ្នាំសាកល្បងដ៏សំខាន់មួយសម្រាប់កម្ពុជា ដែលតម្រូវឱ្យមានភាពបត់បែន និងយុទ្ធសាស្ត្រដោះស្រាយវិបត្តិដ៏មុតស្រួច។ ក្រៅពីឥទ្ធិពលនៃភាពមិនប្រាកដប្រជានៃសេដ្ឋកិច្ច និងពាណិជ្ជកម្មសកល កម្ពុជាបានប្រឈមនឹងវិបត្តិសង្គ្រាមតាមបណ្តោយព្រំដែន ដែលបានបង្កផលប៉ះពាល់ដោយផ្ទាល់ដល់សេដ្ឋកិច្ច សង្គមកិច្ច និងជាពិសេសបានបង្កឱ្យមានការវិលត្រឡប់យ៉ាងគំហុកនៃពលករខ្មែរមកកាន់មាតុប្រទេសវិញ។ ស្ថានភាពនេះ រួមជាមួយនឹងការវិវត្តយ៉ាងឆាប់រហ័សនៃបច្ចេកវិទ្យា បានដាក់សម្ពាធមកលើទីផ្សារការងាររបស់កម្ពុជា។ ទោះជាយ៉ាងនេះក្តី រាជរដ្ឋាភិបាលមិនបានចាត់ទុកបញ្ហាប្រឈមទាំងនេះជាឧបសគ្គរាំងនោះទេ ប៉ុន្តែជាកម្លាំងចលករដើម្បីពន្លឿនការកែទម្រង់ និងចាប់យកកាលានុវត្តភាពថ្មីៗសម្រាប់ការអភិវឌ្ឍ ប្រកបដោយចក្ខុវិស័យវែងឆ្ងាយសម្រាប់កម្ពុជា។

ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបំពេញបេសកកម្មយ៉ាងសកម្មក្នុងការប្រែក្លាយបញ្ហាប្រឈមទាំងនេះ ទៅជាកាលានុវត្តភាព ដោយសម្រេចបាននូវសមិទ្ធផលជាក់ស្តែងគួរជាទីមោទនៈតាមរយៈការអនុវត្ត «ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨» ប្រកបដោយភាពបុរេសកម្ម។ នៅក្នុងវិស័យការងារ ក្រសួងបានរក្សាស្ថិរភាពទីផ្សារការងារឱ្យមានភាពរឹងមាំ ដោយសម្រេចបាននូវកំណើននៃការចុះបញ្ជីសហគ្រាសថ្មី និងការកើនឡើងនៃចំនួនកម្មករនិយោជិតក្នុងវិស័យសេដ្ឋកិច្ចក្នុងប្រព័ន្ធ។ ក្រសួងបានគ្រប់គ្រងវិបត្តិនៃការវិលត្រឡប់របស់ពលករប្រកបដោយប្រសិទ្ធភាព ដោយប្រែក្លាយពួកគេឱ្យទៅជាកម្លាំងពលកម្មដ៏មានសក្តានុពលសម្រាប់ការផ្គត់ផ្គង់តម្រូវការ


អាសយដ្ឋាន អគារលេខ៣ មហាវិថីសហព័ន្ធរុស្ស៊ី សង្កាត់ទឹកល្អក់១ ខណ្ឌទួលគោក ទូរស័ព្ទៈ(០២៣) ៨៨ ៤៣ ៧៥ និងទូរសារ :(០២៣)៨៨ ២៧ ៦៩

កម្លាំងពលកម្មក្នុងស្រុក ដើម្បីឆ្លើយតបនឹងកំណើននៃការវិនិយោគដែលកើតចេញពីកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការទាក់ទាញការវិនិយោគ សំដៅធ្វើពិពិធកម្មសេដ្ឋកិច្ច ព្រមទាំងបង្កើតការងារដែលមានតម្លៃបន្ថែមខ្ពស់ជូនដល់ប្រជាជនកម្ពុជាគ្រប់រូប។ ទន្ទឹមនឹងនេះ យន្តការដោះស្រាយវិវាទការងារ និងការលើកកម្ពស់សុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ ត្រូវបានពង្រឹង ដើម្បីធានាថាបរិយាកាសធុរកិច្ច និងវិនិយោគនៅកម្ពុជានៅតែមានភាពទាក់ទាញ និងប្រកបដោយភាពប្រកួតប្រជែង។

ទន្ទឹមនឹងវឌ្ឍនភាពនៃវិស័យការងារ ក្រសួងបានពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គមយ៉ាងទូលំទូលាយទៅកាន់បុគ្គលស្វ័យនិយោជន៍ និងអ្នកប្រកបរបរនៅក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ ដែលបានបង្ហាញពីការបោះជំហានប្រកបដោយយុទ្ធសាស្ត្រក្នុងការប្រែក្លាយសេដ្ឋកិច្ចក្រៅប្រព័ន្ធឱ្យចូលមកក្នុងប្រព័ន្ធ និងពង្រឹងភាពធន់នៃជីវភាពប្រជាពលរដ្ឋប្រឈមនឹងវិបត្តិនានា។ ដើម្បីគាំទ្រដល់និរន្តរភាពនៃទីផ្សារការងារ និងការអភិវឌ្ឍមូលធនមនុស្ស ក្រសួងបានបន្តជំរុញការអនុវត្តយ៉ាងជោគជ័យ នូវកម្មវិធីថ្នាក់ជាតិស្តីពីការបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យសម្រាប់គោលដៅ ១,៥លាននាក់។ កម្មវិធីនេះ បានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ជីវភាពរបស់ប្រជាជនកម្ពុជា តាមរយៈការបណ្តុះបណ្តាលជំនាញ (Skilling) ការផ្លាស់ប្តូរជំនាញ (Reskilling) និងការបង្កើនជំនាញ (Upskilling) ដល់យុវជនកម្ពុជាក៏ដូចជាពលករដែលបានធ្វើមាតុភូមិនិវត្តន៍ ដើម្បីឱ្យពួកគេមានលទ្ធភាពចាប់យកឱកាសការងារថ្មី និងបង្កើនផលិតភាពការងារស្របតាមការវិវត្តនៃពិភពការងារ។

របាយការណ៍បូកសរុបលទ្ធផលការងារ ឆ្នាំ២០២៥ និងលើកទិសដៅការងារ ឆ្នាំ២០២៦ នេះ នឹងបង្ហាញជូនយ៉ាងលម្អិតអំពីកិច្ចខិតខំប្រឹងប្រែង និងសមិទ្ធផលសំខាន់ៗ ដែលជាសក្ខីភាពនៃការប្តេជ្ញាចិត្តរបស់ក្រសួងក្នុងការធានាថា កម្ពុជានៅតែបន្តរក្សាបាននូវស្ថិរភាព និងកំណើនការងារប្រកបដោយចីរភាព ទោះបីជាស្ថិតក្នុងកាលៈទេសៈនៃភាពមិនប្រាកដប្រជាជាសកល និងតំបន់យ៉ាងណាក្តី។

## ១. ការអនុវត្តអនុសាសន៍ ១០ចំណុច របស់សម្តេចធិបតីនាយករដ្ឋមន្ត្រី

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបន្តអនុវត្តយ៉ាងខ្ជាប់ខ្ជួន និងប្រកបដោយការប្តេជ្ញាចិត្តខ្ពស់ក្នុងការអនុវត្តនូវអនុសាសន៍ណែនាំ ១០ ចំណុចរបស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ដោយក្រសួងបានសម្រេចលទ្ធផលដូចខាងក្រោម៖

១. បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា (ក.ជ.ប.អ.) ចំនួន ២៣លើក ដើម្បីពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២៦ ជូនដល់បងប្អូនកម្មករនិយោជិតវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប។ ជាលទ្ធផល ក.ជ.ប.អ. បានឯកភាពជាឯកច្ឆន្ទស្នើតួលេខចំនួន ២០៨ដុល្លារអាម៉េរិក ជូន **សម្តេចធិបតី** ជ្រាបជារបាយការណ៍ និងពិនិត្យសម្រេច។ យោងលើរបាយការណ៍ និងការពិភាក្សាបន្ថែមជាមួយភាគីពាក់ព័ន្ធ **សម្តេចធិបតី** បានសម្រេចបន្ថែម ២ដុល្លារអាម៉េរិក លើតួលេខ ២០៨ដុល្លារអាម៉េរិក ដែលធ្វើឱ្យប្រាក់ឈ្នួលអប្បបរមាកើនឡើងដល់ចំនួន ២១០ដុល្លារអាម៉េរិក ក្នុង ១ខែ ចាប់ពីថ្ងៃទី១ ខែមករា ឆ្នាំ២០២៦ តទៅ។ បើបូកទាំងប្រាក់អត្ថប្រយោជន៍ជាកាតព្វកិច្ចផ្សេងៗទៀត កម្មករនិយោជិតទទួលបានប្រាក់ឈ្នួលទាបបំផុតចន្លោះពី ២២៧ដុល្លារអាម៉េរិក ដល់ ២៣៨ដុល្លារអាម៉េរិក ក្នុង ១ខែ។

២. បានបន្តអនុវត្តរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្ត សម្រាប់បុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកសមាជិក ប.ស.ស. ដោយបានចុះបញ្ជិកាសមាជិកថ្មី ចំនួន ៣២៥ ៦៩០នាក់ (ស្រី ១៩៣ ៧៧៤នាក់)។ គិតត្រឹមឆ្នាំ២០២៥ នេះ សមាជិក ប.ស.ស. ផ្នែកថែទាំសុខភាពតាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួន ៨៥៩ ៧២៦នាក់ (ស្រី ៥១៥ ៥១៣នាក់)។

៦៧

៣. បានបន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យចំនួន ១,៥លាននាក់ ដោយបានបណ្តុះបណ្តាលសិស្សប្រមាណ ១២,៥ម៉ឺននាក់ ក្នុងនោះ គ្រឹះស្ថានក្រោមឱវាទក្រសួងចំនួនប្រមាណ ១០,៩ម៉ឺននាក់ និងក្រោមមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) ចំនួនប្រមាណ ១,៦ម៉ឺននាក់។

៤. បានជំរុញការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាងសរុបចំនួន ៤៣ ៩៨៩នាក់ (ស្រី ២៧ ៥៦០នាក់) ក្នុងនោះ កូនជាងកំពុងហ្វឹកហ្វឺនមានចំនួន ១១ ៧១៤នាក់ (ស្រី ៧ ២៥២នាក់) និងកូនជាងបានបញ្ចប់ការហ្វឹកហ្វឺនចំនួន ៣៦ ៩៥៦នាក់ (ស្រី ២៣ ៥៦៦នាក់)។

៥. បានបង្កើនប្រសិទ្ធភាពក្នុងការអនុវត្តកម្មវិធីឧបត្ថម្ភសាច់ប្រាក់របស់រាជរដ្ឋាភិបាល សម្រាប់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ។ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះចំនួន ១២២ ៨៦២នាក់ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួន ១៧០ ០៦៣នាក់ ព្រមទាំងបានចំណាយថវិកាប្រមាណ ១១៣ ៣៩៧លានរៀល។ បើគិតត្រឹមឆ្នាំ២០២៥ នេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ជាស្ត្រីមានផ្ទៃពោះចំនួន ៦៩៦ ៧៥១នាក់ និងកុមារអាយុក្រោម ២ឆ្នាំ ចំនួន ៧៣២ ១២៣នាក់ ព្រមទាំងបានចំណាយថវិកាសរុបប្រមាណ ៤០៩ ៩៦៤លានរៀល។

៦. បានដាក់ឱ្យអនុវត្តនូវការជ្រើសរើសពានរង្វាន់ "សហគ្រាសមួយជា សហគមន៍សុខសាន្តមួយប្រចាំឆ្នាំ២០២៥" ដោយផ្អែកលើលក្ខណៈវិនិច្ឆ័យអនុលោមភាពចំនួន ៨ និងត្រូវបានបែងចែកជា ៣កម្រិត និងបានប្រគល់ពានរង្វាន់ជាលើកដំបូងដល់សហគ្រាសចំនួន ៣៦ ក្នុងនោះ ពានមាសមានចំនួន ២២សហគ្រាស, ពានប្រាក់មានចំនួន ៥សហគ្រាស និងពានសំរឹទ្ធិមានចំនួន ៩សហគ្រាស ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចធិបតីនាយករដ្ឋមន្ត្រី** ក្នុងពិធីសំណេះសំណាលជាមួយថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី១៣៩ នៃទិវាពលកម្មអន្តរជាតិ។ ទន្ទឹមនឹងនេះ លេខាធិការដ្ឋាននៃក្រុមការងាររៀបចំយន្តការវាយតម្លៃសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ បានចេញប្រកាសស្តីពីលក្ខខណ្ឌវិនិច្ឆ័យផ្តល់ពានរង្វាន់សហគ្រាសមួយជាសហគមន៍សុខសាន្តមួយប្រចាំឆ្នាំ២០២៦, សេចក្តីសម្រេចស្តីពីការកែសម្រួលសមាសភាពគណៈកម្មការវាយតម្លៃ និងជ្រើសរើសសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ និងបានចេញសេចក្តីជូនដំណឹងស្តីពីការដាក់ពាក្យចូលរួមប្រឡងប្រណាំង។

៧. ក្រសួងបានជំរុញឱ្យមានការបង្កើតទារកដ្ឋាន និងបានដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវទារកដ្ឋាននៅរោងចក្រ ម៉ាវ៉ែល ហ្គាមិន ឯ.ក (Marvel Garment Co., LTD) កាលពីថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៥ ក្រោមអធិបតីភាព **សម្តេចធិបតីនាយករដ្ឋមន្ត្រី**។ ក្រសួងបានចូលរួមរៀបចំពិធីបើកការដ្ឋានសាងសង់ទារកដ្ឋាននៅក្រុមហ៊ុន អ៊ីលីថិច (ខេមបូឌា) ហ្គាម៉ិនឯ.ក (EALYTEX (CAMBODIA) GARMENT CO., LTD) នៅខេត្តកំពង់ឆ្នាំង ជាមួយការជាវីស្ថានទូតសហរដ្ឋអាមេរិកប្រចាំកម្ពុជា ព្រមទាំងបានចុះពិនិត្យវឌ្ឍនភាពនៃការសាងសង់អគារទារកដ្ឋានចំនួន ២៤លើក និងតាមដានវឌ្ឍនភាពប្រតិបត្តិការប្រចាំថ្ងៃ នៅទារកដ្ឋានចំនួន ១២លើក ព្រមទាំងបានចុះត្រួតពិនិត្យការបំពាក់សម្ភារបច្ចេកទេសក្នុងអគារទារកដ្ឋានចំនួន ២៥លើក ក្នុងរោងចក្រ ម៉ាវ៉ែល។ បន្ថែមលើនេះ ក្រសួងបានចុះពិនិត្យ និងជួបពិភាក្សាជាមួយតំណាងរោងចក្រ តារាល អ៊ិនធើណេសិនណល ឯ.ក (TARAL INTERNATIONAL CO., LTD) អំពីគម្រោងសាងសង់ទារកដ្ឋានសហគមន៍ នៅខេត្តកំពង់ស្ពឺ និងបានទំនាក់ទំនងទៅសហគ្រាស ក្រុមហ៊ុន រោងចក្រ ដើម្បីស្រង់ព័ត៌មានពាក់ព័ន្ធនឹងការបង្កើតទារកដ្ឋានប្រចាំសហគ្រាសសរុបចំនួន ៣២៣សហគ្រាស។

៧

៨. បានសហការជាមួយភាគីពាក់ព័ន្ធជំរុញការកែលម្អកន្លែងហូបបាយ ឬអាហារដ្ឋាននៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រដែលកំពុងដំណើរការឱ្យបានសមរម្យសម្រាប់កម្មករនិយោជិតសរុបចំនួន ១ ៤៧៩សហគ្រាស ក្នុងនោះ មានកន្លែងហូបបាយ ឬអាហារដ្ឋានសមរម្យចំនួន ១ ២៧២សហគ្រាស និងជំរុញឱ្យកែលម្អចំនួន ២០៧ សហគ្រាស និងបានជំរុញឱ្យបង្កើតកន្លែងហូបបាយ ឬអាហារដ្ឋានថ្មីចំនួន ២២សហគ្រាស។ ព្រមជាមួយគ្នានេះ ក្រសួងបានប្រជុំពិនិត្យ និងរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំកន្លែងបរិភោគអាហារ និងអាហារដ្ឋាននៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រចំនួន ៤លើក, បានចុះត្រួតពិនិត្យ និងស្រង់ព័ត៌មានកន្លែងបរិភោគអាហារ និងអាហារដ្ឋាននៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ នៅខេត្តកំពង់ស្ពឺ ខេត្តកំពង់ឆ្នាំង តំបន់សេដ្ឋកិច្ចពិសេសភ្នំពេញ ខេត្តស្វាយរៀង ព្រះសីហនុ កំពត តាកែវ កំពង់ចាម និងពោធិ៍សាត់សរុបចំនួន ៨៥សហគ្រាស និងបានទំនាក់ទំនងទៅសហគ្រាស ក្រុមហ៊ុន រោងចក្រ ដើម្បីស្រង់ព័ត៌មានកន្លែងបរិភោគអាហារ និងអាហារដ្ឋានសរុបចំនួន ៣២៣សហគ្រាស។

៩. បានសហការជាមួយភាគីពាក់ព័ន្ធសិក្សាយន្តការគាំទ្រ និងលើកទឹកចិត្តឱ្យមានការផ្លាស់ប្តូរជាបណ្តើរៗនូវមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិត ដែលស្របតាមបទដ្ឋានបច្ចេកទេស និងមានផាសុកភាពជាងមុនត្រឹមឆ្នាំ២០២៧ ដែលក្រសួងបានចេញសេចក្តីសម្រេច ស្តីពីការបង្កើតក្រុមការងារសុវត្ថិភាពចរាចរណ៍ផ្លូវគោកសម្រាប់គាំពារកម្មករនិយោជិត នៃបេឡាជាតិសន្តិសុខសង្គម, រៀបចំសិក្ខាសាលាស្តីពី "ការជំរុញការផ្លាស់ប្តូររថយន្តដឹកកម្មករនិយោជិតឱ្យស្របតាមបទដ្ឋានបច្ចេកទេស និងមានផាសុកភាព" ដោយមានអ្នកចូលរួមសរុបប្រមាណ ៥០០នាក់។ បើគិតត្រឹមឆ្នាំ២០២៥ នេះ បានត្រួតពិនិត្យលើមធ្យោបាយដឹកជញ្ជូនកម្មករនិយោជិតដែលមានការផ្លាស់ប្តូរស្របតាមបទដ្ឋានបច្ចេកទេស និងមានផាសុកភាព ដោយមានរថយន្តដឹកកម្មករនិយោជិតប្រភេទដឹកអ្នកដំណើរចំនួន ១ ៤២៤គ្រឿង នៃរថយន្តដឹកជញ្ជូនកម្មករនិយោជិតសរុបចំនួន ៣ ២៤៨គ្រឿង។ ក្រសួង បានរៀបចំពិធី "ប្រកាសដាក់ឱ្យអនុវត្តសាកល្បងលើការកែលម្អរថយន្តដឹកជញ្ជូនកម្មករនិយោជិតឱ្យកាន់តែមានផាសុកភាព និងសុវត្ថិភាព និងត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្តដឹកជញ្ជូនកម្មករនិយោជិត" ក្រោមសហអធិបតីភាព **ឯកឧត្តម ហេង សួរ** រដ្ឋមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និង **ឯកឧត្តម ប៉េង ពោធិ៍នា** រដ្ឋមន្ត្រីក្រសួងសាធារណការ និងដឹកជញ្ជូន ដែលមានអ្នកចូលរួមប្រមាណជា ៧៤៦នាក់។ បន្ថែមពីនេះ បានផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកចំនួន ៤០៧លើក ដែលមាន ៤០៧សហគ្រាស ដោយមានអ្នកចូលរួមចំនួន ១១៤ ៨០០នាក់ (ស្រី ៨៩ ៤៦២នាក់)។

១០. បានជំរុញកម្មវិធីធ្វើតេស្តវាយតម្លៃសមត្ថភាពទទួលស្គាល់ជំនាញ ដើម្បីផ្តល់ឱកាសដល់បងប្អូនកម្មករនិយោជិតទាំងក្នុង និងក្រៅប្រទេស និងបុគ្គលសេដ្ឋកិច្ចក្រៅប្រព័ន្ធ អាចស្នើសុំធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាពបញ្ជាក់កម្រិតជំនាញក្នុងការទទួលបានវិញ្ញាបនបត្រគុណវុឌ្ឍិជាតិ ដើម្បីបង្ហាញពីសមត្ថភាព និងកម្រិតជំនាញរបស់ខ្លួន ដោយក្រសួងបានកំណត់លក្ខខណ្ឌសម្រាប់ចូលធ្វើតេស្ត, យន្តការធានាគុណភាព និងតម្លាភាពនៃការធ្វើតេស្ត និងការជ្រើសរើសមជ្ឈមណ្ឌលសម្រាប់ធ្វើតេស្តបន្ថែមទៀត។ គិតត្រឹមឆ្នាំ២០២៥ នេះ ក្រសួងបានចុះបញ្ជីទទួលស្គាល់មជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពនៃគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ (ជីវេត) សរុបចំនួន ១៥ (ឯកជនចំនួន ៣), បណ្តុះបណ្តាលគ្រូ/អ្នកបច្ចេកទេសឱ្យក្លាយជាអ្នកវាយតម្លៃសមត្ថភាពបានចំនួន ៥៦៤នាក់ (ស្រី ១២៣នាក់), អ្នកវាយតម្លៃដែលបានចុះបញ្ជិកាសរុបចំនួន ១៤៣នាក់ និងមានអ្នកបានធ្វើតេស្តទទួលស្គាល់ជំនាញនៅតាមមជ្ឈមណ្ឌលវាយតម្លៃសមត្ថភាពសរុបចំនួន ៤ ០៧៥នាក់។

## ២. លទ្ធផលការងារសំខាន់ៗ ដែលសម្រេចបាន

### ២.១. ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម

### ២.១.១. ការពង្រឹងការអនុវត្តគោលនយោបាយ និងសិក្សាស្រាវជ្រាវ

ក្រសួង បានដឹកនាំការរៀបចំ និងជំរុញការអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម កាន់តែមុតស្រួច ស៊ីជម្រៅ និងប្រទាក់ក្រឡាគ្នាជាមួយការកំណត់សូចនាករសមិទ្ធកម្ម ឬបច្ច័យផលទីផ្សារការងារជាក់លាក់ ដែលអាចវាស់វែង តាមដាន និងត្រួតពិនិត្យបានជាប្រចាំ សំដៅម្ខាងដើម្បីជំរុញកំណើនឱកាសការងារដែលមានផលិតភាពខ្ពស់ និងម្ខាងទៀត ដើម្បីធានាបានថាប្រជាជនដែលមានជំនាញ និងបទពិសោធការងារនឹងមានលទ្ធភាពទទួលបានការងារប្រសើរជាងមុន ជាពិសេសនៅក្នុងវិស័យសេដ្ឋកិច្ចដែលមានការរីកចម្រើន។ ជាលទ្ធផល ក្នុងឆ្នាំ២០២៥ នេះ ក្រសួង៖

- បានជំរុញការបង្កើតការងារប្រមាណ ៨០ម៉ឺនកន្លែង ទាំងនៅក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធ និងសេដ្ឋកិច្ចក្រៅប្រព័ន្ធ សម្រាប់កម្លាំងពលកម្មក្នុងស្រុក ដែលទើបឈានចូលក្នុងទីផ្សារការងារជាលើកដំបូង ឬផ្លាស់ប្តូរការងារ និងពលករទេសន្តរប្រវេសន៍ខ្មែរដែលបានវិលត្រឡប់មកមាតុភូមិវិញ

- បានទទួលការចុះបញ្ជីសហគ្រាស ក្រុមហ៊ុន រោងចក្រ និងជំរុញការប្រកាសចំនួនកម្មករនិយោជិតដែលកំពុងបម្រើការងារ ដោយសម្រេចបានកំណើនការងារក្នុងប្រព័ន្ធជាង ៤០ម៉ឺនកន្លែង៖

  - សហគ្រាស ក្រុមហ៊ុន រោងចក្រ បានកើនឡើងពី ៤៤ ៧៩៨ ដល់ ៤៦ ៦៤៩សហគ្រាស (កើនឡើង ១ ៨៥១សហគ្រាស) ក្នុងនោះ វិស័យកាត់ដេរកើនឡើងពី ១ ៥៦៦ ដល់ ១ ៨៦៧សហគ្រាស (កើនឡើង ៣០១សហគ្រាស) និងវិស័យក្រៅពីកាត់ដេរ កើនឡើងពី ៤៣ ២៣២ ដល់ ៤៤ ៧៨២ សហគ្រាស (កើនឡើង ១ ៥៥០សហគ្រាស)
  - កម្មករនិយោជិតក្នុងសេដ្ឋកិច្ចក្នុងប្រព័ន្ធកើនឡើងពី ១ ៨១៦ ០៤៦នាក់ ដល់ ២ ២១៧ ៥២៥នាក់ (កើនឡើង ៤០១ ៤៧៩នាក់) ក្នុងនោះ វិស័យកាត់ដេរកើនឡើង ២១០ ០៤៦នាក់ និងវិស័យក្រៅពីកាត់ដេរកើនឡើង ១៩១ ៤៣៣នាក់
  - បើគិតជាវិស័យធំៗ ទាំង ៣ គិតត្រឹមឆ្នាំ២០២៥នេះ វិស័យកសិកម្មមានសហគ្រាស ក្រុមហ៊ុន រោងចក្រចំនួន ៣៨៦សហគ្រាស (កម្មករចំនួន ៥៨ ១២៥នាក់), វិស័យឧស្សាហកម្មមានចំនួន ៧ ៥៦៥សហគ្រាស (កម្មករចំនួន ១ ៥១០ ៦៩៧នាក់) និងវិស័យសេវាកម្មមានចំនួន ៣៨ ៦៩៨សហគ្រាស (កម្មករ ៦៤៨ ៧០៣នាក់)។

- បានដាក់ចេញ និងអនុវត្តអន្តរាគមន៍គាំទ្រអតីតពលករខ្មែរដែលបានវិលត្រឡប់ប្រមាណ ៩៦ម៉ឺននាក់ និងបានជួយឱ្យអតីតពលករខ្មែរប្រមាណ ៦២ម៉ឺននាក់ទទួលបានការងារធ្វើ ក្នុងនោះ ប្រមាណ ៣១ម៉ឺននាក់ បានចូលធ្វើការនៅក្នុងសហគ្រាស ក្រុមហ៊ុន និងរោងចក្រ ដែលជាការងារក្នុងប្រព័ន្ធ ហើយប្រមាណ ៣១ម៉ឺននាក់ផ្សេងទៀត បានទទួលការងារនៅតាមសហគ្រាសធុនមីក្រូ តូចនិងមធ្យម ដូចជាសិប្បកម្ម ភោជនីយដ្ឋាន និងនៅតាមការដ្ឋានសំណង់ដែលជាការងារក្រៅប្រព័ន្ធ (អន្តរាគមន៍លម្អិតមាននៅក្នុងចំណុច ២.៤.៤)។

៦៧

### រូបភាព ២.១.១៖ បម្រែបម្រួលសហគ្រាស ក្រុមហ៊ុន រោងចក្រ និងកម្មករនិយោជិត ចុះបញ្ជិកាជាមួយក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ (ឆ្នាំ២០២៥ ធៀបឆ្នាំ២០២៤)




*ប្រភព៖ នាយកដ្ឋានអធិការកិច្ចការងារ*

*សម្គាល់៖ ខាងឆ្វេង ជាសហគ្រាស ក្រុមហ៊ុន រោងចក្រ រីឯខាងស្តាំជា កម្មករនិយោជិត។*

### រូបភាព ២.១.២៖ ចំនួនកម្មករនិយោជិតបែងចែកតាមសកម្មភាពសេដ្ឋកិច្ចសំខាន់ៗ (គិតត្រឹមឆ្នាំ២០២៥)




*ប្រភព៖ នាយកដ្ឋានអធិការកិច្ចការងារ*

- បានដឹកនាំការរៀបចំសេចក្តីព្រាងគោលនយោបាយជាតិចំនួន ៣ រួមមាន៖ គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០២៦-២០៣៥,គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០២៦-២០៣៥,និង គោលនយោបាយជាតិស្តីពីទេសន្តរប្រវេសន៍ការងារ ឆ្នាំ២០២៦-២០៣៥ ដោយសម្រេចបានលទ្ធផលដូចខាងក្រោម៖

- គោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០២៦-២០៣៥៖ បានបង្កើតក្រុមការងាររៀបចំគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ ឆ្នាំ២០២៦-២០៣៥ របស់ក្រសួង សម្រាប់ធ្វើការដឹកនាំ រៀបចំសេចក្តីព្រាងគោលនយោបាយបាយ,រៀបចំកិច្ចប្រជុំបច្ចេកទេសផ្ទៃក្នុងចំនួន ១០លើក និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ប្រមូលធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិសរុបចំនួន ៣លើក
- គោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០២៦-២០៣៥៖ បានបង្កើតក្រុមការងាររៀបចំគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ឆ្នាំ២០២៦-២០៣៥ របស់ក្រសួងសម្រាប់ធ្វើការដឹកនាំ, បានរៀបចំសេចក្តីព្រាង និងបានរៀបចំកិច្ចប្រជុំក្រុមការងាររៀបចំគោលនយោបាយ និងប្រជុំបច្ចេកទេសចំនួន ១៣លើក
- គោលនយោបាយជាតិស្តីពីទេសន្តរប្រវេសន៍ការងារ ឆ្នាំ២០២៦-២០៣៥៖ បានបង្កើតក្រុមការងារបច្ចេកទេសសិក្សា រៀបចំសេចក្តីព្រាងគោលនយោបាយជាតិ ស្តីពីទេសន្តរប្រវេសន៍ការងារ, រៀបចំកិច្ចប្រជុំបច្ចេកទេសផ្ទៃក្នុងចំនួន ១៥លើក និងបានរៀបចំសិក្ខាសាលាពិគ្រោះយោបល់ ប្រមូលធាតុចូលពីក្រសួង ស្ថាប័នពាក់ព័ន្ធចំនួន ២លើក

- បានបញ្ចប់ម៉ូឌែលព្យាករណ៍តម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មដល់ឆ្នាំ២០៣០ ដោយប្រើប្រាស់ម៉ូឌែលវិភាគ ដូចជា Compound Annual Growth Rate ( CAGR ), Moving Average ( MA ), Auto-Regressive Integrated Moving Average ( ARIMA ), Regression Analysis ដោយប្រើប្រាស់ទិន្នន័យអង្កេតសេដ្ឋកិច្ច សង្គមកិច្ចកម្ពុជា ឆ្នាំ២០២៣ និងអង្កេតកម្លាំងពលកម្ម ឆ្នាំ២០១៩

- បានបញ្ចប់ការរៀបចំម៉ូឌែលសេដ្ឋកិច្ចដោយប្រើប្រាស់ទិន្នន័យ Input-Output Table របស់ធនាគារអភិវឌ្ឍន៍អាស៊ី ( ADB ) រួមមាន Backward និង forward linkage, output multiplier, employment multiplier និង value added multiplier និងបានរៀបចំជាទម្រង់គណនាសម្រាប់ធ្វើ Policy Simulation

- បានបន្តការសិក្សាស្រាវជ្រាវ និងអភិវឌ្ឍម៉ូឌែលសេដ្ឋកិច្ច Computable General Equilibrium ( CGE ) និង Social Accounting Matrix ( SAM )

- បានបន្តកិច្ចពិភាក្សាបច្ចេកទេសជាមួយ អគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិផលិតភាព សេដ្ឋកិច្ចកម្ពុជា ( គ.ជ.ផ.ក. ) នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ លើប្រធានបទ "ម៉ូដែលនៃការគណនា និងវាស់វែងផលិតភាពសេដ្ឋកិច្ចកម្ពុជា"

- បានចាប់ផ្តើមការសិក្សាលើ Structural Model for Sustainable Development ( SMSD ) ក្រោមកិច្ចសហការជាមួយអង្គការអន្តរជាតិខាងការងារ ( ILO )។

- បានរៀបចំសន្និសីទសេដ្ឋកិច្ចការងារឆ្នាំ២០២៥ ក្រោមប្រធានបទ "ការរៀបចំអនាគតការងារនៅកម្ពុជា៖ ជំនាញ មុខរបរនិងការងារ និងការគាំពារសង្គម សំដៅបង្កើតទីផ្សារការងារដែលមានភាពធន់" ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តមអគ្គបណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ដែលមានអ្នកចូលរួមសរុបចំនួន ៣៥០រូប

- បានបោះពុម្ពផ្សាយ "ទស្សនវិស័យមុខរបរ និងការងារ" សម្រាប់ឆមាសទី១ និងឆមាសទី២ ឆ្នាំ២០២៥

- បានចេញផ្សាយរបាយការណ៍សំខាន់ៗជាច្រើន ដូចជា (១). អង្កេតទស្សនវិស័យការងារចំនួន ២លើក សម្រាប់ឆមាសទី ១ និងឆមាសទី២ឆ្នាំ២០២៥, (២). របាយការណ៍វាយតម្លៃលើការធ្វើសមាហរណកម្មទីផ្សារការងារ

នៅក្នុងប្រទេសកម្ពុជានៃពលករទេសន្តរប្រវេសន៍ដែលបានត្រឡប់មកពីប្រទេសថៃ, (៣). របាយការណ៍អង្កេត ស្ដីពីការវាយកម្រិតនៃប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗទៀតរបស់សមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.), (៤). របាយការណ៍អង្កេត ស្តីពីឥរិយាបថរបស់សមាជិក ប.ស.ស. ក្នុងការប្រើប្រាស់កន្លែងផ្តល់សេវាសុខភាពសាធារណៈ និងឯកជន, (៥). របាយការណ៍អង្កេត ស្តីពីការលើកកម្ពស់ជីវភាពរស់នៅ និងការថែទាំសុខភាពរបស់សមាជិក ប.ស.ស. (កាតព្វកិច្ច) និងគ្រួសារ, (៦). លក្ខខណ្ឌរស់នៅ និងការថែទាំសុខភាពរបស់សមាជិក ប.ស.ស. (របបភាគទានកាតព្វកិច្ច) តាមមុខរបរ, (៧). របាយការណ៍អង្កេត ស្តីពីអត្ថប្រយោជន៍ សិទ្ធិ និងកាតព្វកិច្ចរបស់សមាជិកបេឡាជាតិរបបសន្តិសុខសង្គមកម្ពុជា, (៨). របាយការណ៍អង្កេត ស្តីពីការវាយតម្លៃភាពពេញចិត្តរបស់សមាជិកបេឡាជាតិសន្តិសុខសង្គម (ប.ស.ស.), (៩). របាយការណ៍អង្កេត ស្តីពីការចាកចេញពីប្រព័ន្ធសន្តិសុខសង្គមនៃក្រុមបុគ្គលស្វ័យនិយោជន៍, (១០). របាយការណ៍អង្កេត ស្តីពីសមត្ថភាព ឬលទ្ធភាពក្នុងការបង់ភាគទាន ប.ស.ស. (គ្រួសារមិនមែនសមាជិក ប.ស.ស.), (១១). របាយការណ៍អង្កេត ស្តីពីការស្ទង់មតិសិស្សក្រោយបញ្ចប់ការសិក្សាពីគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងតម្រូវការជំនាញរបស់និយោជក និង (១២). អង្កេត ស្តីពីជំនាញ និងការងារកម្ពុជាឆ្នាំ២០២៥ ៖ ភាពមិនស៊ីគ្នានៃជំនាញ និងគុណវុឌ្ឍិ

- បានរៀបចំរបាយការណ៍ ស្តីពីការវាយតម្លៃកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងងាយរងហានិភ័យ ១,៥លាននាក់

- បានរៀបចំសូចនាករសំខាន់ៗពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ២.១.២. ការពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាស្វែងរកការងារ និងវេទិកាការងារ

ក្រសួង បានពង្រឹងប្រសិទ្ធភាពនៃយន្តការផ្តល់សេវាស្វែងរកការងារ និងវេទិកាការងារ ដើម្បីតភ្ជាប់តម្រូវការទីផ្សារ និងជួយផ្គត់ផ្គង់កម្លាំងពលកម្មគ្រប់កម្រិតជំនាញឱ្យទទួលបានឱកាសការងារយ៉ាងឆាប់រហ័សប្រកបដោយបរិយាបន្ន។ កម្មវិធីអាទិភាពនេះត្រូវបានអនុវត្តយ៉ាងសកម្មដោយទីភ្នាក់ងារជាតិមុខរបរ និងការងារ (NEA) ជាយន្តការប្រតិបត្តិ តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងទិន្នន័យ ការពង្រីកការប្រមូលព័ត៌មានឱកាសការងារ និងការជំរុញការប្រើប្រាស់ថ្នាលបច្ចេកវិទ្យាឌីជីថល សំដៅបង្កើនអត្រាអ្នកទទួលបានការងារធ្វើឱ្យកើនឡើងជាអតិបរមា។ ជាលទ្ធផលក្នុងឆ្នាំ២០២៥ ក្រសួង៖

- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានជ្រើសរើសកម្លាំងពលកម្មចំនួន ៨២២ ៥៨១កន្លែង តាមរយៈការប្រើប្រាស់បច្ចេកវិទ្យាព័ត៌មាន ដោយមានអ្នកចូលប្រើប្រាស់គេហទំព័របានចំនួន ៣ ០២៣ ៧១៨លើក, Facebook ចំនួន ១ ០៦៤ ៩២៩នាក់, YouTube ចំនួន ១៦ ៥៩៦លើក, Tiktok ចំនួន ២ ៩៩២ ៨៦៣លើក និងអ្នកទាញយកប្រើប្រាស់សេវាតាមរយៈកម្មវិធីស្វែងរកការងារលើទូរសព្ទឆ្លាត (Mobile App) ចំនួន ៦ ៤៩៤នាក់ និងកម្មវិធីនាទីទីផ្សារការងារ និងមុខរបរនៅតាមស្ថានីយទូរទស្សន៍នានា

- បានរៀបចំវេទិកាការងារចំនួន ៥៩៧ដង មានអ្នកចូលរួមចំនួន ១៤២ ៩៧៨នាក់ (ស្រី ៦៨ ៤៦៥នាក់)

- បានរៀបចំពិព័រណ៍ចល័តចំនួន ៧២១ដង មានអ្នកចូលរួមចំនួន ៨៨ ៥០៨នាក់ (ស្រី ៤៣ ១០៦នាក់)

- បានរៀបចំពិព័រណ៍ការងាររាជធានី ខេត្តចំនួន ២០ដង មានអ្នកចូលរួមសរុបចំនួន ១៤ ០០១នាក់ (ស្រី ៦ ៦១៦នាក់)

- បានប្រមូល និងរក្សាបាននូវនិន្នាការជ្រើសរើសកម្លាំងពលកម្មខ្ពស់នៅឆ្នាំ២០២៥ បើធៀបនឹងឆ្នាំ២០២៤។ គិតត្រឹមចុងឆ្នាំ២០២៥ នេះ ការជ្រើសរើសកម្លាំងពលកម្មដែលកំពុងមានសុពលភាពមានសរុបចំនួន ៨១ ៧០៧ កន្លែង ក្នុងនោះវិស័យសេវាកម្មមានចំនួន ២ ៥៥៣កន្លែង, ឧស្សាហកម្មចំនួន ៧៥ ៤៦៩កន្លែង និងកសិកម្មចំនួន ៣ ៦៨៥កន្លែង

៩៧

- បានរៀបចំពិព័រណ៍ការងារ និងផលិតភាពជាតិ ឆ្នាំ២០២៥ នៅមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ មានអ្នកចូលរួមទស្សនាសរុបចំនួន ៩៥ ៥២២នាក់ ក្នុងនោះ មានអ្នកទស្សនាដោយផ្ទាល់ចំនួន ៣១ ៤៧៦នាក់ និងមានអ្នកទស្សនាតាមអនឡាញចំនួន ៦៤ ០៤៦នាក់

- បានចុះជួបនិយោជកទាំងថ្មី និងចាស់ ដើម្បីប្រមូលព័ត៌មានអំពីឱកាសការងារ កម្មសិក្សាការងារសរុបចំនួន ១ ៨៥៦ដង ស្មើនឹង ១ ៣៦៦សហគ្រាស

- បានចុះឈ្មោះអ្នកស្វែងរកការងារធ្វើតាមរយៈទីភ្នាក់ងារជាតិមុខរបរ និងការងារសរុបចំនួន ១៧៥ ៣៦៩នាក់ (ស្រី ៦៣ ១៥៤នាក់) ដោយបានផ្តល់ និងបញ្ជូនអ្នកស្វែងរកការងារធ្វើទៅនិយោជក តាមរយៈបច្ចេកវិទ្យាព័ត៌មានចំនួន ២៤០ ៥២០ដង/នាក់ (ស្រី ៩៦ ៤៥០ដង/នាក់) មានអ្នកទទួលបានការងារធ្វើសរុបចំនួន ១៨៥ ២៤៣នាក់ (ស្រី ៦៦ ៦៩៤នាក់)។

**រូបភាព ២.១.៣៖ ព័ត៌មាននៃការជ្រើសរើសកម្លាំងពលកម្មប្រចាំខែដែលផ្សព្វផ្សាយដោយ ទ.ជ.ម.ក. (២០២៤ និង២០២៥)**




*ប្រភព៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក.)*
*សម្គាល់៖ តួលេខខាងលើជាចំនួនព័ត៌មាននៃការជ្រើសរើសកម្លាំងពលកម្មដែលមាននៅចុងខែនីមួយៗ*

**តារាង ២.១.១៖ ការពង្រីកយន្តការវេទិកាការងារទាំងនៅថ្នាក់ជាតិ ថ្នាក់រាជធានី ខេត្ត និងតាមមូលដ្ឋាន**

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ១ | រៀបចំវេទិកាការងារ | ដង | 66 | 597 | 804.55% |
| | | ស្រី | 4,713 | 68,465 | 1,352.68% |
| | | អ្នកចូលរួម | 10,224 | 142,978 | 1,298.45% |
| ២ | រៀបចំកិច្ចសម្ភាសន៍ការងារ | ដង | 101 | 100 | -0.99% |
| | | ស្រី | 1,405 | 5,661 | 302.92% |
| | | អ្នកចូលរួម | 3,115 | 12,064 | 287.29% |
| ៣ | រៀបចំពិព័រណ៍ចល័ត (មជ្ឈមណ្ឌលការងារ ១៤រាជធានី ខេត្ត) | ដង | 924 | 721 | -21.97% |
| | | ស្រី | 39,529 | 43,106 | 9.05% |
| | | អ្នកចូលរួម | 69,608 | 88,508 | 27.15% |

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ៤ | រៀបចំពិព័រណ៍ការងារ ថ្នាក់ជាតិប្រចាំឆ្នាំ | ដង | 1 | 1 | 0.00% |
| | | ស្រី | 0 | - | - |
| | | អ្នកចូលរួម | 104,689 | 95,522 | -8.76% |
| ៥ | រៀបចំពិព័រណ៍ការងារ រាជធានី ខេត្ត | ដង | 2 | 20 | 900.00% |
| | | ស្រី | 1,874 | 6,616 | 253.04% |
| | | អ្នកចូលរួម | 6,559 | 14,001 | 113.46% |
| ៦ | រៀបចំសិក្ខាសាលាផ្សព្វផ្សាយ និងប្រមូលអ្នកស្វែងរកការងារធ្វើនៅតាមមូលដ្ឋាន | ដង | 155 | 35 | -77.42% |
| | | ស្រី | 1,324 | 552 | -58.31% |
| | | អ្នកចូលរួម | 5,179 | 1,767 | -65.88% |
| ៧ | ការចូលរួមតាំងបង្ហាញសេវាការងារសាធារណៈ | ដង | 8 | 13 | 62.50% |
| | | ស្រី | 43,899 | 12,783 | -70.88% |
| | | អ្នកចូលរួម | 555,293 | 87,820 | -84.18% |

*ប្រភព៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ (ទ.ជ.ម.ក.)*

### ២.១.៣. ការពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ការងារ និងវិជ្ជាជីវៈ

ក្រសួង បានពង្រឹង និងពង្រីកសេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីព ដើម្បីតម្រង់ទិសកម្លាំងពលកម្មគ្រប់កម្រិតឱ្យជ្រើសរើសជំនាញបានត្រឹមត្រូវ និងកសាងភាពធន់ដើម្បីភាពប្រកួតប្រជែងលើទីផ្សារការងារ។ ជាលទ្ធផលឆ្នាំ២០២៥ នេះ ក្រសួងបានផ្តល់ការណែនាំ និងប្រឹក្សាយោបល់ អាជីព ការងារ និងវិជ្ជាជីវៈទៅដល់ សិស្ស និស្សិត អ្នកស្វែងរកការងារធ្វើ និងកម្មករនិយោជិតសរុបចំនួន ៧២ ១០៩នាក់ (ស្រី ៣៧ ៥៩៣នាក់) ក្នុងនោះ៖

- បានផ្តល់ប្រឹក្សាយោបល់អំពីអាជីព ការងារ និងវិជ្ជាជីវៈទៅអ្នកស្វែងរកការងារចំនួន ៥៤ ៤១៩នាក់ (ស្រី ២៧ ៥៤៦នាក់)
- បានរៀបចំសិក្ខាសាលា ស្តីពីផែនការអាជីព និងជ្រើសរើសជំនាញសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិចំនួន ២៦៦ដង អ្នកចូលរួមចំនួន ១៣ ៥០៥នាក់ (ស្រី ៧ ៩៧៤នាក់)
- បានរៀបចំសិក្ខាសាលាស្តីពីការណែនាំអាជីព ការងារ និងវិជ្ជាជីវៈ សម្រាប់សិស្ស-និស្សិត នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសាកលវិទ្យាល័យចំនួន ៤០ដង អ្នកចូលរួមចំនួន ២ ០៤៧នាក់ (ស្រី ១ ០៥៤នាក់)
- បានរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការត្រៀមលក្ខណសម្បត្តិក្នុងការស្វែងរកការងារចំនួន ៦៨វគ្គ មានអ្នកចូលរួមចំនួន ២ ១៣៨នាក់ (ស្រី ៩៧៩នាក់)។

### ២.១.៤. ការពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេស តាមរយៈបច្ចេកវិទ្យាឌីជីថល

ក្រសួង បានពង្រឹងយន្តការគ្រប់គ្រងការប្រើប្រាស់កម្លាំងពលកម្មក្នុងប្រទេសតាមរយៈបច្ចេកវិទ្យាឌីជីថល ដើម្បីធានាបាននូវការគាំពារសិទ្ធិ អត្ថប្រយោជន៍ស្របច្បាប់ និងកសាងភាពធន់នៃទីផ្សារការងារ។ ជាលទ្ធផលឆ្នាំ២០២៥ នេះ ក្រសួង៖

- បានផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរចំនួន ២៧៥ ៤០៣នាក់ (ស្រី ១៥៥ ៥៥០នាក់) និងបានប្តូរសៀវភៅការងារពីទម្រង់ចាស់ទៅទម្រង់ថ្មីចំនួន ២ ៩៦៤នាក់ (ស្រី ១ ៦៣៩នាក់)។

### តារាង ២.១.២៖ ការផ្តល់សេវាសៀវភៅការងារដល់កម្មករនិយោជិតខ្មែរ

| ល.រ | បរិយាយ | ឯកតា | ២០២៤ | | | ២០២៥ | | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ថ្នាក់កណ្តាល | រាជធានីខេត្ត | សរុប | ថ្នាក់កណ្តាល | រាជធានីខេត្ត | |
| ១ | ផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ | សរុប | 289,580 | 287,630 | 1,950 | 275,403 | 100,690 | 174,713 | -4.90% |
| | | ស្រី | 184,967 | 183,831 | 1,136 | 155,550 | 60,693 | 94,857 | -15.90% |
| ២ | ប្តូរសៀវភៅការងារពីទម្រង់ចាស់មកថ្មី | សរុប | 4,089 | 4,089 | 0 | 2,964 | 1,874 | 1,090 | -27.51% |
| | | ស្រី | 1,869 | 1,869 | 0 | 1,639 | 1,116 | 523 | -12.31% |
| ៣ | បច្ចុប្បន្នភាពទិដ្ឋាការ "ចូល" | សរុប | 80,122 | 79,388 | 734 | 118,715 | 48,277 | 70,438 | 48.17% |
| | | ស្រី | 54,750 | 54,671 | 79 | 82,091 | 32,999 | 49,092 | 49.94% |
| ៤ | បច្ចុប្បន្នភាពទិដ្ឋាការ "ចេញ" | សរុប | 142,818 | 141,856 | 962 | 183,202 | 84,807 | 98,395 | 28.28% |
| | | ស្រី | 89,820 | 89,537 | 283 | 120,750 | 56,958 | 63,792 | 34.44% |
| ៥ | ទុតិយតាសៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរ | សរុប | 10,048 | 10,048 | 0 | 236 | 62 | 174 | -97.65% |
| | | ស្រី | 7,691 | 7,691 | 0 | 143 | 43 | 100 | -98.14% |

*ប្រភព៖ នាយកដ្ឋានមុខរបរ និងបាត្តពលកម្ម និងមន្ទីរ ក.ប. រាជធានី ខេត្ត*

- បានចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក "ចូល" ចំនួន ១៨ ៦៣០សហគ្រាស មាន ២១ ៤១០សំណើ មានកម្មករនិយោជិតចំនួន ១៤៩ ៣៦៩នាក់ (ស្រី ៩១ ៨៦៣នាក់) និងបានចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិក "ចេញ" ចំនួន ២១ ៤២៤សហគ្រាស មាន ២៣ ៦៣៦សំណើ មានកម្មករនិយោជិតចំនួន ១៨០ ៣៦៣នាក់ (ស្រី ១០៩ ៤៥៨នាក់)។

## ២.១.៥. ការពង្រឹងការអនុវត្តគោលនយោបាយជាតិ ស្តីពីមុខរបរនិងការងារ និងកម្មវិធីជំរុញការលើកកម្ពស់ផលិតភាពការងារ

ក្រសួង បានពង្រឹងការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារ និងកម្មវិធីជំរុញផលិតភាពការងារ ដើម្បីពង្រឹងសមត្ថភាពប្រកួតប្រជែង និងកសាងភាពធន់នៃកម្លាំងពលកម្មជាតិ។ ជាលទ្ធផលឆ្នាំ ២០២៥ នេះ ក្រសួង៖

- បានរៀបចំកិច្ច ប្រជុំស្តីពីការផ្តល់សុពលភាពលើរបាយការណ៍វាយតម្លៃលើការអនុវត្តគោលនយោបាយជាតិស្តីពីមុខរបរ និងការងារឆ្នាំ២០១៥-២០២៥ ចំនួន ៥លើក មានអ្នកចូលរួមសរុបចំនួន ២២៧នាក់ នៅខេត្តសៀមរាប និងរាជធានីភ្នំពេញ មកពីក្រសួង ស្ថាប័នពាក់ព័ន្ធដែលជាសមាជិកគណៈកម្មការអន្តរក្រសួង

- បានអនុម័តលើរបាយការណ៍វាយតម្លៃលើការអនុវត្តគោលនយោបាយជាតិ ស្តីពីមុខរបរ និងការងារ ឆ្នាំ២០១៥-២០២៥

- បានបន្តចូលរួមលើកកម្ពស់ផលិតភាពការងារ តាមរយៈការរៀបចំវគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ផលិតភាព និងសហគ្រិនភាព ដល់សិស្ស និស្សិត អ្នកស្វែងរកការងារ និងកម្មករនិយោជិតចំនួន ៤៤វគ្គ អ្នកចូលរួមចំនួន ១ ១៧៦នាក់ (ស្រី ៥៤៤នាក់) មានសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលបានបញ្ជូនកម្មករនិយោជិតឱ្យចូលរួមវគ្គបណ្តុះបណ្តាលអំពីជំនាញទន់ចំនួន ១៣៩សហគ្រាស

- បានចូលរួមសិក្ខាសាលាបណ្តុះបណ្តាល ស្តីពីប្រព័ន្ធគ្រប់គ្រង និងវាយតម្លៃកម្មវិធីមុខរបរ និងការងារសមរម្យ សម្រាប់យុវជននៅកម្ពុជា ដំណាក់កាលទី៣ (DEY III) នៅខេត្តពោធិ៍សាត់។

៦៧

## ២.២. ការធ្វើបរិវត្តកម្មប្រព័ន្ធអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

### ២.២.១. ការពង្រឹងប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមបច្ចេកវិទ្យាឌីជីថល

ក្រសួង បានពង្រឹងប្រព័ន្ធអភិបាលកិច្ច និងការគ្រប់គ្រងវិស័យអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ តាមរយៈការធ្វើបរិវត្តកម្មប្រព័ន្ធបច្ចេកវិទ្យាឌីជីថល ដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពនៃការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញ។ កម្មវិធីអាទិភាពនេះ ត្រូវបានអនុវត្ត តាមរយៈការរៀបចំ និងធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិ និងការដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យា (TVET MIS) ឱ្យកាន់តែពេញលេញ សំដៅធានាបាននូវគុណភាពបណ្តុះបណ្តាលនៅគ្រប់គ្រឹះស្ថានជីវេត។ ក្នុងន័យនេះ ក្រសួង៖

- បានរៀបចំលិខិតបទដ្ឋានគតិយុត្ត គោលនយោបាយ និងផែនការយុទ្ធសាស្ត្រពាក់ព័ន្ធនឹងវិស័យជីវេត និងអនុវត្តគោលនយោបាយជាតិស្តីពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈឆ្នាំ២០១៧-២០២៥។ គិតត្រឹមឆ្នាំ២០២៥ នេះ មានគ្រឹះស្ថានជីវេត ក្រោមឱវាទសរុបចំនួន ២៦០គ្រឹះស្ថាន ក្នុងនោះ គ្រឹះស្ថានសាធារណៈចំនួន ៣៧, គ្រឹះស្ថានឯកជនចំនួន ១៩៩ (ចុះបញ្ជិកានៅក្រោមឱវាទក្រសួងផ្ទាល់ចំនួន ៧៨គ្រឹះស្ថាន និងគ្រឹះស្ថានក្រោមឱវាទមន្ទីរចំនួន ១២១គ្រឹះស្ថាន) និងអង្គការ/សមាគមចំនួន ២៤ មានបុគ្គលិក មន្ត្រីរាជការ សាស្ត្រាចារ្យ និងគ្រូបច្ចេកទេស កំពុងបម្រើការងារសរុបចំនួន ៦ ៦៤៦នាក់ (ស្រី ២ ០៧៦នាក់)
- បានធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងព័ត៌មានវិទ្យាតាមបច្ចេកវិទ្យាឌីជីថល ដោយបានពង្រីកមុខងារគ្រប់គ្រងគ្រឹះស្ថាន និងទិន្នន័យ ក្នុងវិស័យជីវេត ដូចជាសិក្ខាកាម, សិស្ស, និស្សិត, កញ្ចប់ស្តង់ដាបណ្តុះបណ្តាល, ឯកសារ និងវីដេអូបង្រៀន, បានភ្ជាប់សិស្សស្វែងរកការងារធ្វើជាមួយទីភ្នាក់ងារជាតិមុខរបរ និងការងារ និងអាចចេញវិញ្ញាបនបត្រឬសញ្ញាបត្រតាមប្រព័ន្ធដោយភ្ជាប់នឹងថ្នាលផ្ទៀងផ្ទាត់ឯកសារ verify.gov.kh របស់រាជរដ្ឋាភិបាល បានចំនួន ៦៧ ៨៨៦សន្លឹក ព្រមទាំងបានបណ្តុះបណ្តាលជនបង្គោលឱ្យចេះប្រើប្រាស់កម្មវិធីចុះឈ្មោះរៀនតាមប្រព័ន្ធឌីជីថល ដើម្បីត្រៀមជួយដល់ក្រុមគោលដៅក្នុងការចុះឈ្មោះចូលរៀនកម្មវិធីបណ្តុះបណ្តាលដែលមានអ្នកចូលរួមចំនួន ៣៦១នាក់ (ស្រី ៧០នាក់)
- បានពង្រឹងសមត្ថភាពថ្នាក់ដឹកនាំ គណៈគ្រប់គ្រង មន្ត្រីរាជការ និងបុគ្គលិកនៃអគ្គនាយកដ្ឋាន នាយកដ្ឋានជំនាញ និងគ្រឹះស្ថានជីវេត ចំនួនសរុប ៦០៧នាក់ (ស្រី ១៤៥នាក់) ក្នុងនោះ ក្នុងប្រទេស ៤៥៥នាក់ (ស្រី ១២៦នាក់) និងក្រៅប្រទេស ១៥៣នាក់ (ស្រី ១៩នាក់)។

**តារាង ២.២.១៖ បច្ចុប្បន្នភាពបុគ្គលិក និងសាស្ត្រាចារ្យនៅគ្រឹះស្ថានជីវេត**

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ១ | គ្រឹះស្ថាន | គ្រឹះស្ថាន | 253 | 260 | 2.77% |
| ១.១ | គ្រឹះស្ថានសាធារណៈក្រោមឱវាទក្រសួង | គ្រឹះស្ថាន | 37 | 37 | 0.00% |
| ១.២ | គ្រឹះស្ថានឯកជនក្រោមឱវាទក្រសួង | គ្រឹះស្ថាន | 72 | 78 | 8.33% |
| ១.៣ | គ្រឹះស្ថានឯកជនក្រោម ឱវាទមន្ទីរ ក.ប. | គ្រឹះស្ថាន | 121 | 121 | 0.00% |
| ១.៤ | គ្រឹះស្ថានអង្គការ/សមាគម ក្រោមឱវាទក្រសួង | គ្រឹះស្ថាន | 23 | 24 | 4.35% |
| ២ | ថ្នាក់ដឹកនាំ | សរុប | 724 | 743 | 2.62% |
| | | ស្រី | 148 | 157 | 6.08% |

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ៣ | គ្រូ/សាស្ត្រាចារ្យកំពុងបង្រៀន | សរុប | 3,193 | 3,268 | 2.35% |
| | | ស្រី | 892 | 912 | 2.24% |
| ៤ | អ្នកជំនាញការ/សាស្ត្រាចារ្យបរទេស | សរុប | 126 | 118 | -6.35% |
| | | ស្រី | 49 | 46 | -6.12% |
| ៥ | បុគ្គលិករដ្ឋបាល | សរុប | 2,496 | 2,517 | 0.84% |
| | | ស្រី | 950 | 961 | 1.16% |
| **បុគ្គលិកសរុប** | | សរុប | **6,539** | **6,646** | **1.64%** |
| | | ស្រី | **2,039** | **2,076** | **1.81%** |

*ប្រភព៖ នាយកដ្ឋានគ្រប់គ្រងគ្រឹះស្ថានសិក្សា*

### ២.២.២. ការពង្រឹងគុណភាពអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ

ក្រសួង បានពង្រឹងគុណភាពនៃការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដោយរួមបញ្ចូលនូវជំនាញទន់ ជំនាញឌីជីថល និងជំនាញបៃតង ដើម្បីអភិវឌ្ឍកម្លាំងពលកម្មកម្ពុជាឱ្យមានសមត្ថភាពខ្ពស់ និងកសាងភាពធន់ឆ្លើយតបនឹងការវិវត្តនៃសេដ្ឋកិច្ចសកល។ កម្មវិធីអាទិភាពនេះ ត្រូវបានអនុវត្តដោយមានការចូលរួមយ៉ាងសកម្មពីអគ្គនាយកដ្ឋានអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ, គណៈវិស្វករកម្ពុជា និងអង្គភាពពាក់ព័ន្ធ។ ជាលទ្ធផលឆ្នាំ២០២៥ នេះ ក្រសួង៖

- បានបញ្ចប់ការអភិវឌ្ឍកញ្ចប់ស្តង់ដា បណ្តុះបណ្តាលផ្អែកលើសមត្ថភាពបន្ថែមចំនួន ៣៤គុណវុឌ្ឍិ លើ ២០មុខជំនាញ។ បើគិតត្រឹមឆ្នាំ២០២៥ នេះ ក្រសួងបានអភិវឌ្ឍកញ្ចប់ស្តង់ដា បណ្តុះបណ្តាលផ្អែកលើសមត្ថភាព បានចំនួន ២៥៦គុណវុឌ្ឍិ លើ ១១៦មុខជំនាញ និងបានអភិវឌ្ឍកញ្ចប់សិក្សាផ្អែកលើសមត្ថភាព បានចំនួន ៣៩៩ម៉ូឌុល ២ ៦២០មេរៀន លើ ៦៧គុណវុឌ្ឍិ (C1, C2 និង C3) នៃ ៦០មុខជំនាញ លើវិស័យអាទិភាពទាំង ១០ រួមមាន វិស័យសំណង់, អគ្គិសនីនិងថាមពល, អេឡិចត្រូនិក, កម្មន្តសាល, មេកានិកទូទៅ/មេកានិករថយន្ត, ធុរកិច្ច និងព័ត៌មានវិទ្យា, សេវាកម្ម, បរិក្ខារត្រជាក់និងកម្តៅ, ទេសចរណ៍ និងកសិកម្ម និងកសិ-ឧស្សាហកម្ម ក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ
- បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយការអនុវត្តលក្ខណៈវិនិច្ឆ័យធានាគុណភាព វិស័យបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដល់គ្រឹះស្ថានឯកជន ឯកជន សមាគម និងអង្គការមិនមែនរដ្ឋាភិបាល ចំនួន ១លើក, បានតាមដានការអនុវត្តប្រព័ន្ធគ្រប់គ្រងគុណភាពស្តង់ដា ISO ចំនួន ៣៦គ្រឹះស្ថាន និងបានចុះត្រួតពិនិត្យ តាមដាន និងវាយតម្លៃគុណភាពគ្រឹះស្ថានឯកជន ចំនួន ២៩គ្រឹះស្ថាន ក្នុងនោះ ចំនួន ១២គ្រឹះស្ថាន ទទួលបានចំណាត់ថ្នាក់នៃការវាយតម្លៃគុណភាព "**ល្អប្រសើរ**"
- បានចុះអធិការកិច្ច និងវាយតម្លៃការបណ្តុះបណ្តាលរបស់គ្រូបច្ចេកទេស/ឯកទេសនៅតាមគ្រឹះស្ថានចំនួន ១៧គ្រឹះស្ថាន មានគ្រូចូលរួមសរុបចំនួន ១០៥នាក់ (ស្រី ៥នាក់)
- បានធ្វើវិក្រឹតការផ្អែកគរុកោសល្យ និងជំនាញបច្ចេកទេស ស្របតាមការរីកចម្រើននៃបដិវត្តន៍ឧស្សាហកម្ម ៤.០ ជំនាញបច្ចេកវិទ្យាឌីជីថល និងជំនាញបៃតងបានចំនួន ៦១វគ្គ មានគ្រូចូលរួមសរុបចំនួន ១ ០៤៩នាក់ (ស្រី ១៦៤នាក់) ក្នុងនោះ ការបណ្តុះបណ្តាលសមត្ថភាពជំនាញតាមកម្មវិធីត្រឡប់ទៅឧស្សាហកម្មវិញ (RIS) បានចំនួន ៣១វគ្គ មានគ្រូចូលរួមចំនួន ២២៦នាក់ (ស្រី ២៤នាក់), បច្ចេកទេសក្នុងការប្រើប្រាស់វិធីសាស្ត្របណ្តុះបណ្តាលផ្អែកលើសមត្ថភាព (CBT) បានចំនួន ៧វគ្គ មានគ្រូចូលរួមចំនួន ៣៤៧នាក់ (ស្រី ៦៧នាក់),

១៧

វគ្គបណ្តុះបណ្តាលក្រៅប្រទេសបានចំនួន ១១វគ្គ មានគ្រូចូលរួមចំនួន ៥៧នាក់ (ស្រី ៨នាក់) និងពង្រឹងសមត្ថភាព និងគុណភាពគ្រូបច្ចេកទេសឌីជីថល និងឧស្សាហកម្ម ៤.០ បានចំនួន ១២វគ្គ មានគ្រូចូលរួមចំនួន ៤១៩នាក់ (ស្រី ៦៥នាក់)

- បានជ្រើសរើស និងបណ្តុះបណ្តាលគ្រូឧទ្ទេសលើផ្នែកគរុកោសល្យ និងផ្នែកបច្ចេកទេស (Master Trainer) ចំនួន ៣៧នាក់ (ស្រី ១នាក់) និងមានគ្រូបច្ចេកទេសចំនួន ៦០នាក់ (ស្រី ១៧នាក់) ត្រូវបានប្តូរជំនាញ (Reskilling) និងបង្កើនជំនាញ (Upskilling)

- បានទំនាក់ទំនង និងជំរុញលើកទឹកចិត្តអ្នកបច្ចេកទេសមកពីឧស្សាហកម្ម និងគណៈវិស្វករកម្ពុជា/ស្ថាប័នជំនាញចូលរួមផ្តល់ការបណ្តុះបណ្តាលនៅតាមគ្រឹះស្ថានជីវេត ចំនួន ២៥៣នាក់ (ស្រី ៣៩នាក់)

- បានចុះតាមដាន និងវាយតម្លៃសមត្ថភាពគ្រូបច្ចេកទេសនៅតាមគ្រឹះស្ថានជីវេត ដែលបានរៀបចំការរៀបចំនួន ២២គ្រឹះស្ថាន

- បានត្រួតពិនិត្យវាយតម្លៃដោយបានចុះបញ្ជីវិស្វករថ្មីសរុបចំនួន ១ ៤០៧នាក់ (ស្រី ១១១នាក់) ក្នុងនោះ វិស្វករជាតិចុះបញ្ជីវិស្វករដំបូង (RE) មានចំនួន ១ ៤០៦នាក់ (ស្រី ១១១នាក់) និងវិស្វករបរទេស (RFE) មានចំនួន ១នាក់។ បានធ្វើបច្ចុប្បន្នភាពវិស្វករគិតត្រឹមឆ្នាំ២០២៥ នេះ សរុបចំនួន ១០ ១៧២នាក់ (ស្រី ៤៧៥នាក់) ក្នុងនោះ វិស្វករជាតិចំនួន ១០ ១២៨នាក់ (ស្រី ៤៧៥នាក់) និងវិស្វករបរទេសចំនួន ៤៤នាក់

- បានរៀបចំវគ្គបណ្តុះបណ្តាលដល់វិស្វករចុះបញ្ជីសរុបចំនួន ១០លើក មានវិស្វករចូលរួមចំនួន ១ ៨២០នាក់ (ស្រី ១៨៥នាក់) ក្នុងនោះ ដោយផ្ទាល់ចំនួន ៦លើក មានវិស្វករចូលរួមចំនួន ១ ៥៩១នាក់ (ស្រី ១៥១នាក់) និងតាមប្រព័ន្ធអនឡាញចំនួន ៤លើក មានវិស្វករចូលរួមចំនួន ២២៩នាក់ (ស្រី ៣៤នាក់) ក្នុងគោលបំណងដើម្បីបង្កើនចំណេះដឹង ជំនាញ បទពិសោធថ្មីៗ ពាក់ព័ន្ធនឹងវិស័យវិស្វកម្មស្របទៅនឹងការវិវត្តនៃបច្ចេកវិទ្យានាពេលបច្ចុប្បន្ន

- បានផ្សព្វផ្សាយពីសារៈប្រយោជន៍នៃការចុះបញ្ជីវិស្វករនៅគណៈវិស្វករកម្ពុជាសរុបចំនួន ៥លើក មានអ្នកចូលរួមសរុបចំនួន ១ ៣៦១នាក់ (ស្រី ៤១៣នាក់) ដល់វិស្វករ និងនិស្សិតផ្នែកវិស្វកម្ម យល់ដឹងពីសារៈប្រយោជន៍នៃការចុះបញ្ជីវិស្វករនៅគណៈវិស្វករកម្ពុជា បទដ្ឋានគតិយុត្ត និងបទដ្ឋានបច្ចេកទេសនានាពាក់ព័ន្ធនឹងវិស័យវិស្វកម្ម

- បានរៀបចំសិក្ខាសាលា និងការចែករំលែកចំណេះដឹងជំនាញ និងបទពិសោធរបស់វិស្វករអាជីពដល់និស្សិត តាមគ្រឹះស្ថានជីវេត បានចំនួន ២លើក មានអ្នកចូលរួមសរុបចំនួន ៧៣៥នាក់ (ស្រី ២៧៨នាក់) ដើម្បីត្រៀមលក្ខណសម្បត្តិឱ្យក្លាយជាធនធានបញ្ញវន្តវិស្វកម្ម ប្រកបដោយគុណភាព ក្រោយបញ្ចប់ការសិក្សា។

### ២.២.៣. ការពង្រីក និងពង្រឹងការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញ

ក្រសួង បានដឹកនាំការពង្រឹង និងពង្រីកការបណ្តុះបណ្តាលកម្លាំងពលកម្មជំនាញប្រកបដោយភាពបុរេសកម្ម ដើម្បីគាំទ្រដល់ការអនុវត្តគោលនយោបាយអភិវឌ្ឍន៍សេដ្ឋកិច្ច-សង្គម និងកសាងភាពធន់ប្រកបដោយបរិយាបន្ន។ ជាលទ្ធផលឆ្នាំ២០២៥ នេះ សម្រេចបានដូចខាងក្រោម៖

- បានបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈទូទាំងប្រទេសសរុបចំនួន ១៦៣ ២២៩នាក់ (ស្រី ៦៩ ៧០១នាក់) ក្នុងនោះ គ្រឹះស្ថានក្រោមឱវាទក្រសួងចំនួន ១៤៧ ៦៥០នាក់ (ស្រី ៦១ ៧៩៧នាក់) និងក្រោមមូលនិធិអភិវឌ្ឍន៍ជំនាញ (SDF) ចំនួន ១៥ ៥៧៩នាក់ (ស្រី ៧ ៩០៤នាក់)

- បានបណ្តុះបណ្តាលសិក្ខាកាម សិស្ស និស្សិត សរុបចំនួន ១៤៧ ៦៥០នាក់ (ស្រី ៦១ ៧៩៧នាក់) តាមរយៈគ្រឹះស្ថានជីវេត នៅក្រោមឱវាទក្រសួងសរុបចំនួន ២៦០គ្រឹះស្ថាន ដោយបែងចែកតាមកម្រិតដូចខាងក្រោម៖

- បរិញ្ញាបត្របច្ចេកទេសចំនួន ២៤ ២៩៨នាក់ (ស្រី ៨ ៩៨០នាក់)
- សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេសចំនួន ២៣ ៣៥៧នាក់ (ស្រី ៥ ៨៥៩នាក់)
- សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ (C3) ចំនួន ១ ៤១៨នាក់ (ស្រី ៣២៩នាក់)
- សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ (C2) ចំនួន ៣ ២៧៩នាក់ (ស្រី ៩៨១នាក់)
- សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1) ចំនួន ៨១ ២៤៣នាក់ (ស្រី ៣៧ ៩០៤នាក់)
- វិញ្ញាបនបត្រចំនួន ១៤ ០៥៥នាក់ (ស្រី ៧ ៧៤៤នាក់)។

- បានជំរុញការអភិវឌ្ឍសមត្ថភាពកម្លាំងពលកម្មដែលនៅក្នុងទីផ្សារការងារ និងត្រៀមចូលទីផ្សារការងារតាមរយៈការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង ដោយមានសហគ្រាស ក្រុមហ៊ុន រោងចក្របានចុះបញ្ជិកាចំនួន ១ ២២៦ មានកូនជាងហ្វឹកហ្វឺនចំនួន ៤៣ ៩៨៩នាក់ (ស្រី ២៧ ៥៦០នាក់), កូនជាងកំពុងហ្វឹកហ្វឺនចំនួន ១១ ៧១៤នាក់ (ស្រី ៧ ២៥២នាក់) និងបានបញ្ចប់ការហ្វឹកហ្វឺនចំនួន ៣៦ ៩៥៦នាក់ (ស្រី ២៣ ៥៦៦នាក់)

- បានបណ្តុះបណ្តាលគ្រូ/អ្នកបច្ចេកទេសឱ្យក្លាយជាអ្នកវាយតម្លៃសមត្ថភាពចំនួន ១២៦នាក់ (ស្រី ២២នាក់), បានទទួលបេក្ខជនចុះឈ្មោះក្នុងថ្នាល E-RPL ចំនួន ២៦៦នាក់ (ស្រី ៣៤នាក់) និងបានធ្វើតេស្ត ទទួលស្គាល់ជំនាញសម្រាប់ទទួលបានគុណវឌ្ឍិចំនួន ២៤៥នាក់ (ស្រី ៣០នាក់)

- បានរៀបចំទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៨ ឆ្នាំ២០២៥ ក្រោមប្រធានបទ **"TVET បង្កើតឱកាសការងារ សាងក្តីសង្ឃឹមដល់យុវជន"** មានការតាំងបង្ហាញស្នាដៃរបស់សិស្ស និស្សិត មកពីបណ្តាគ្រឹះស្ថានជីវេតនានា និងមានស្តង់ពិព័រណ៍ចំនួន ៥៥៥ស្តង់ ដោយមានការចូលរួមពីស្ថាប័នពាក់ព័ន្ធចំនួន ៥៦៨ ក្នុងនោះ មានក្រសួង ស្ថាប័ន គ្រឹះស្ថានជីវេត គ្រឹះស្ថានឯកជន អង្គការ សមាគម និងដៃគូអភិវឌ្ឍន៍ចំនួន ២៣៩ និងក្រុមហ៊ុនឯកជនចំនួន ៣២៩ មានអ្នកចូលរួមសរុបចំនួន ៦៦ ១៥៨នាក់ (ស្រី ៣០ ២១៥នាក់)

- បានរៀបចំកម្មវិធីតម្រង់ទិសវិជ្ជាជីវៈនៅតាមសាលាចំណេះទូទៅចំនួន ៤២៧សាលា អ្នកចូលរួមសរុប ៩៤ ២២៦នាក់ (ស្រី ៥៥ ៣៥៩នាក់) និងកម្មវិធីផ្សព្វផ្សាយ អ.ប.វ. នៅតាមសហគមន៍ សហគ្រាស គ្រឹះស្ថានចំនួន ៤ ៧៩៣ដង អ្នកចូលរួមសរុប ៣៧៩ ០០២នាក់ (ស្រី ១៩០ ០៣៨នាក់)។

**តារាង ២.២.២៖ ចំនួនសិក្ខាកាម សិស្ស និស្សិត ទទួលបានការបណ្តុះបណ្តាល ឆ្នាំ២០២៤-២០២៥**

| កម្រិត | ការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ | ២០២៤ | | ២០២៥ | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | |
| ៦ | បរិញ្ញាបត្របច្ចេកទេស | 30,252 | 11,561 | 24,298 | 8,980 | -19.68% |
| ៥ | សញ្ញាបត្រជាន់ខ្ពស់បច្ចេកទេស | 20,569 | 7,046 | 23,357 | 5,859 | 13.55% |
| ៤ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ៣ (C3) | 1,664 | 461 | 1,418 | 329 | -14.78% |
| ៣ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ២ (C2) | 2,646 | 765 | 3,279 | 981 | 23.92% |
| ២ | សញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1) | 52,564 | 20,813 | 81,243 | 37,904 | 54.56% |
| ១ | វិញ្ញាបនបត្រវិជ្ជាជីវៈ | 15,311 | 8,799 | 14,055 | 7,744 | -8.20% |
| សរុបរួម | | **123,006** | **49,445** | **147,650** | **61,797** | **20.03%** |

*ប្រភព៖ នាយកដ្ឋានព័ត៌មានទីផ្សារការងារ*

## រូបភាព ២.២.១៖ ចំនួនសិក្ខាកាម សិស្ស និស្សិត ទទួលបានការការបណ្តុះបណ្តាលបែងចែកតាមវិស័យ




*ប្រភព៖ នាយកដ្ឋានព័ត៌មានទីផ្សារការងារ*

## តារាង ២.២.៣៖ ការអនុវត្តកាតព្វកិច្ចហ្វឹកហ្វឺនកូនជាង

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ១ | សហគ្រាស គ្រឹះស្ថាន ដែលបានចុះបញ្ជិកា និងកូនជាងត្រូវបានហ្វឹកហ្វឺន | ស.ហ | 1,040 | 1,226 | 17.88% |
| | | សរុប | 38,846 | 43,989 | 13.24% |
| | | ស្រី | 26,296 | 27,560 | 4.81% |
| ២ | សហគ្រាស គ្រឹះស្ថាន និងកូនជាងកំពុងហ្វឹកហ្វឺន | ស.ហ | 111 | 307 | 176.58% |
| | | សរុប | 4,681 | 11,714 | 150.25% |
| | | ស្រី | 3,258 | 7,252 | 122.59% |
| ៣ | កូនជាងដែលបានធ្វើតេស្តបញ្ចប់ និងផ្តល់វិញ្ញាបនបត្រ បញ្ជាក់ការហ្វឹកហ្វឺនកូនជាង | ស.ហ | 929 | 1,030 | 10.87% |
| | | សរុប | 34,165 | 36,956 | 8.17% |
| | | ស្រី | 23,038 | 23,566 | 2.29% |

*ប្រភព ៖ នាយកដ្ឋានបណ្តុះបណ្តាល*

*សម្គាល់៖ តួលេខកូនជាងដែលបានធ្វើតេស្តបញ្ចប់ឆ្នាំ២០២៥ រាប់បញ្ចូលតួលេខកូនជាងដែលមិនទាន់បញ្ចប់ពីឆ្នាំ២០២៤។*

- បានបន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (១,៥លាននាក់) កម្រិត C1 តាមប្រព័ន្ធ TVET 1.5M ដោយទទួលបានអ្នកស្នើចុះឈ្មោះចូលរៀនចំនួន ៦២ ៦៣៣នាក់ (ស្រី ៣០ ២៣៣នាក់)។ បើគិតត្រឹមឆ្នាំ២០២៥ នេះ ក្រសួងទទួលបានអ្នកស្នើចុះឈ្មោះចូលរៀនសរុបចំនួន ១៤៨ ២៧២នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ៦២ ៥៨១នាក់), សិស្សកំពុងសិក្សា និងបានបញ្ចប់សរុបចំនួន ៨៦ ៧៣០នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ៤២ ៣៤៣នាក់) ក្នុងនោះ សិស្សកំពុងសិក្សាមានចំនួន ៧ ៤៤៥នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ៣ ១៤៤នាក់) និងសិស្សបានបញ្ចប់ការសិក្សាចំនួន ៧៩ ២៨៥នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ៣៩ ១៩៩នាក់) ដោយមានសិស្សទទួលបានការងារធ្វើមានចំនួន ៥១ ៥៩១នាក់ (មានបណ្ណសមធម៌ ឬបណ្ណងាយរងហានិភ័យចំនួន ២៦ ៨៦៦នាក់)។

**រូបភាព ២.២.២៖ វឌ្ឍនភាពនៃការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជន មកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ (គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥)**




*ប្រភព៖ នាយកដ្ឋានព័ត៌មានទីផ្សារការងារ*

## ២.២.៤. ការពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍

ក្រសួង បានពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាព និងបន្សុីកម្មវិធីបណ្តុះបណ្តាលទៅនឹងតម្រូវការទីផ្សារការងារ ក៏ដូចជាការកសាងភាពធន់នៃកម្លាំងពលកម្មកម្ពុជា។ ជាលទ្ធផល ឆ្នាំ២០២៥ នេះ ក្រសួង៖

- បានចុះអនុស្សរណៈនៃការយោគយល់គ្នា (MoU) ជាមួយសហគ្រាស គ្រឹះស្ថាន ឧស្សាហកម្ម ក្រុមហ៊ុនឯកជន និងដៃគូសរុបចំនួន ៥០៧។ បើគិតត្រឹមឆ្នាំ២០២៥ នេះ អនុស្សរណៈនៃការយោគយល់គ្នា (MoU) និងកិច្ចព្រមព្រៀងនៅមានសុពលភាពសរុបចំនួន ៧៦២
- បានផ្តល់ឱកាសឱ្យសិស្ស និស្សិត ចុះកម្មសិក្សា និងទស្សនកិច្ចសិក្សា នៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រចំនួន ៣ ៦០៥ មានសិក្ខាកាមចូលរួមចំនួន ៤៥ ២១៥នាក់ (ស្រី ២២ ១០១នាក់) និងសិស្ស និស្សិតទទួលបានការងារក្នុងអំឡុងពេលចុះកម្មសិក្សា/ទស្សនកិច្ចសិក្សាចំនួន ៣៨ ៤៣៤នាក់ (ស្រី ១៨ ៣៨០នាក់)
- បានបណ្តុះបណ្តាលសិស្ស និស្សិត ក្នុងកម្មវិធីភាពជាដៃគូរដ្ឋ និងឯកជន (PPP) ចំនួន ១៣២នាក់ (ស្រី ៥៩នាក់) ព្រមទាំងបានពង្រឹង និងពង្រីកការអនុវត្តការបណ្តុះបណ្តាលតាមកម្មវិធីការបណ្តុះបណ្តាលនៅកន្លែងការងារបានចំនួន ៥៤៩នាក់ (ស្រី ២៦០នាក់)។

## ២.២.៥. ការជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍

ក្រសួង បានជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ ដើម្បីឆ្លើយតបទៅនឹងបដិវត្តន៍ឧស្សាហកម្ម ៤.០ និងកសាងភាពធន់នៃកម្លាំងពលកម្មជាតិក្នុងយុគសម័យឌីជីថល។ ក្នុងន័យនេះ ក្រសួង៖

- បានបន្តជំរុញការស្រាវជ្រាវ និងនវានុវត្តន៍ដល់គ្រឹះស្ថានធីវេតទាំង ៣៧គ្រឹះស្ថាន ដែលបានបង្កើតជាសមិទ្ធផលស្នាដៃរបស់សិស្ស និស្សិតសរុបចំនួន ៤៥ ដែលបានដាក់តាំងបង្ហាញក្នុងទិវាជាតិអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈលើកទី៨ ឆ្នាំ២០២៥ ថ្មីៗនេះ នៅមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ

- បានបញ្ជូនគ្រឹះស្ថានចំនួន ៣ (វិទ្យាស្ថាន NTTI, វិទ្យាស្ថាន PPI និងវិទ្យាស្ថាន NPIC) ចូលរួមប្រកួតប្រជែងជំនាញ ABU Robocon ឆ្នាំ២០២៥ មានបេក្ខជនចំនួន ១២នាក់ (ទទួលជ័យលាភីចំនួន ៩នាក់) និងបានបញ្ជូនបេក្ខជនចូលរួមប្រកួតប្រជែងជំនាញ ASEAN TVET FRIENDLY MATCH 2025 នៅឯប្រទេសម៉ាឡេស៊ីចំនួន ៥នាក់ លើ ៤ជំនាញ រួមមាន ជំនាញតបណ្តាញអគ្គិសនី, ផ្សារ, រៀបឥដ្ឋ និងជំនាញមេកាត្រូនិក ដោយទទួលជ័យលាភីមេដាយប្រាក់ចំនួន១ លើជំនាញរៀបឥដ្ឋ, មេដាយសំរឹទ្ធិចំនួន១ លើជំនាញផ្សារ និងមេដាយសំរឹទ្ធិចំនួន ២ លើជំនាញមេកាត្រូនិក

- បានបញ្ជូនបេក្ខជនចំនួន ១៩នាក់ លើ ១៣មុខជំនាញ ចូលរួមក្នុងការប្រកួតប្រជែងជំនាញអាស៊ានលើកទី១៤ នៅប្រទេសហ្វីលីពីន ដោយកម្ពុជាទទួលបានមេដាយសរុបចំនួន ៤ រួមមាន មេដាយសំរឹទ្ធិចំនួន ១, មេដាយឧត្តមភាពចំនួន ២, និងទទួលបានពានរង្វាន់ល្អផ្ទើមចំនួន ១ និងបានបញ្ជូនបេក្ខជនចំនួន ៩នាក់ លើ ៣ ជំនាញ ចូលរួមក្នុងកម្មវិធីប្រកួតប្រជែងសមត្ថភាពជំនាញមហាវិទ្យាល័យពិភពលោកឆ្នាំ២០២៥ ក្នុងតំបន់អាស៊ីអាគ្នេយ៍របស់សាកលវិទ្យាល័យបច្ចេកវិទ្យា និងវិទ្យាសាស្ត្រកម្ពុជា-ចិន ទទួលបានជ័យលាភីមេដាយប្រាក់ចំនួន ៣ លើជំនាញ Next Generation Information Technology Track ក្នុងប្រធានបទ Water Quality Monitoring System

- បានរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគលើកទី១ ឆ្នាំ២០២៥ នៅវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនស្វាយរៀង មានបេក្ខជនចូលរួម ៣៦នាក់ (ស្រី ១៦នាក់) លើ ៤ជំនាញ រួមមាន ជំនាញតបណ្តាញអគ្គិសនី, រចនាក្រាហ្វិក, រចនាគេហទំព័រ និងសរសេរកម្មវិធីកុំព្យូទ័រធុរកិច្ច ដោយទទួលបានជ័យលាភីមេដាយមាសចំនួន ៤, មេដាយប្រាក់ចំនួន ៥ និងមេដាយសំរឹទ្ធិចំនួន ៣ និងបានរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគលើកទី១ ឆ្នាំ២០២៥ នៅវិទ្យាស្ថានពហុបច្ចេកទេសភូមិភាគតេជោសែនតាកែវ មានបេក្ខជនចូលរួម ៣៥នាក់ (ស្រី ៨នាក់) លើ ៤ជំនាញ រួមមាន ជំនាញតបណ្តាញអគ្គិសនី, រចនាក្រាហ្វិក, រចនាគេហទំព័រ និងសរសេរកម្មវិធីកុំព្យូទ័រធុរកិច្ច ដោយទទួលបានជ័យលាភីមេដាយមាសចំនួន ៣, មេដាយប្រាក់ចំនួន៤ និងមេដាយសំរឹទ្ធិចំនួន ៦។

## ២.៣. ការអភិវឌ្ឍលក្ខខណ្ឌការងារ សុវត្ថិភាព និងសុខភាពការងារ និងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ

### ២.៣.១. ការពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច និងយន្តការអធិការកិច្ចការងារ

ក្រសួង បានពង្រឹងសមត្ថភាពមន្ត្រីអធិការកិច្ច និងយន្តការអធិការកិច្ចការងារ ដើម្បីបន្តលើកកម្ពស់វប្បធម៌អនុលោមភាពនៅកម្ពុជាឱ្យកាន់តែល្អប្រសើរ។ កម្មវិធីអាទិភាពនេះត្រូវបានជំរុញតាមរយៈការដាក់ឱ្យអនុវត្តរបបស្វ័យប្រកាសអធិការកិច្ចតាមប្រព័ន្ធស្វ័យប្រវត្តិកម្ម (SICMS) ការចាត់វិធានការច្បាប់យ៉ាងតឹងរ៉ឹងចំពោះសហគ្រាស រោងចក្រ ក្រុមហ៊ុន ដែលប្រព្រឹត្តល្មើសច្បាប់ ការរៀបចំក្រុមអធិការកិច្ចអន្តរក្រសួង និងការធ្វើបច្ចុប្បន្នភាពក្របខណ្ឌគតិយុត្ត សំដៅឆ្លើយតបទៅនឹងការវិវត្តនៃទម្រង់ការងារ ជាពិសេសការងារតាមថ្នាលឌីជីថល។ ជាលទ្ធផលឆ្នាំ២០២៥ នេះ ក្រសួងសម្រេចបាននូវសមិទ្ធផលសំខាន់ៗដូចខាងក្រោម៖

#### ក. ការចុះអធិការកិច្ចការងារ

- បានអនុវត្តប្រព័ន្ធស្វ័យប្រកាសអធិការកិច្ចការងារ ដោយចុះអធិការកិច្ចការងារសរុបចំនួន ១៣ ៥០០លើក ក្នុងនោះ អធិការកិច្ចការងារសាមញ្ញចំនួន ១២ ៩១០លើក, អធិការកិច្ចតាមដានការដាក់កំហិតចំនួន ៨៥លើក និងអធិការកិច្ចការងារពិសេសចំនួន ៥០៥លើក ព្រមទាំងបានដាក់កំហិតចំនួន ១ ០៨៣សហគ្រាស និងបានចេញលិខិតផាកពិន័យចំនួន ១០១សហគ្រាស។ តាមរយៈការចុះអធិការកិច្ចការងារពិនិត្យឃើញថាអត្រាសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលអនុលោមភាពតាមច្បាប់ និងលិខិតបទដ្ឋានពាក់ព័ន្ធនឹងវិស័យការងារមានចំនួន ៩៩,២៥%

- បានរៀបចំសម្របសម្រួលការចុះធ្វើអធិការកិច្ចអន្តរក្រសួងក្នុងវិស័យកម្មន្តសាលសរុបចំនួន ២៥០សហគ្រាស ដែលអនុវត្តចាប់ពីថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២៥ រហូតដល់ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ២០២៥ ក្នុងគោលដៅរាជធានីភ្នំពេញ ដោយមានក្រសួងពាក់ព័ន្ធចំនួន ៣ ចូលរួម ក្នុងនោះរួមមាន ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ, ក្រសួងបរិស្ថាន និងក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍

- បានចុះបញ្ជិកាលើសេចក្តីប្រកាសជូនដំណឹងបើកសហគ្រាស ក្រុមហ៊ុន រោងចក្រចំនួន ១ ១១៩សហគ្រាស, ការបំពេញទិន្នន័យធ្វើការបន្ថែមម៉ោងក្រៅពីថិរវេលាធ្វើការធម្មតាចំនួន ៩ ៦៤១សហគ្រាស, ការបំពេញទិន្នន័យធ្វើការនៅថ្ងៃឈប់សម្រាកប្រចាំសប្តាហ៍ចំនួន ៩ ០៩៩សហគ្រាស, ការបំពេញទិន្នន័យធ្វើការនៅថ្ងៃឈប់សម្រាកបុណ្យដែលមានប្រាក់ឈ្នួលចំនួន ៦ ១៨៦សហគ្រាស និងការធ្វើបច្ចុប្បន្នភាពព័ត៌មានសហគ្រាស ក្រុមហ៊ុន រោងចក្រចំនួន ១ ១៦៤សហគ្រាស។

**រូបភាព ២.៣.១៖ ការចុះធ្វើអធិការកិច្ចការងារ និងវិធានការចំពោះរោងចក្រដែលប្រព្រឹត្តល្មើសច្បាប់**




*ប្រភព៖ នាយកដ្ឋានអធិការកិច្ចការងារ*

## ខ. ស្ថានភាពសហគ្រាស គ្រឹះស្ថាន បើកថ្មី បិទ និងព្យួរកិច្ចសន្យាការងារ

- សហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលបើកថ្មីមានសរុបចំនួន ២ ០៣៤សហគ្រាស មានកម្មករនិយោជិតសរុបចំនួន ៣៩៦ ០៩៧នាក់ (ស្រី ១៨១ ៩៨០នាក់) ក្នុងនោះ វិស័យកាត់ដេរមានចំនួន ៣៣០សហគ្រាស មានកម្មករនិយោជិតចំនួន ២៤៤ ២៣៣នាក់ (ស្រី ១១៨ ៥០៥នាក់)

- សហគ្រាស ក្រុមហ៊ុន រោងចក្រ បិទសរុបចំនួន ១៨៣សហគ្រាស មានកម្មករនិយោជិតសរុបចំនួន ១៨ ១៨០នាក់ (ស្រី ១០ ៣៨២នាក់) ក្នុងនោះ វិស័យកាត់ដេរមានចំនួន ២៩សហគ្រាស មានកម្មករនិយោជិតចំនួន ៩ ៤៥៩នាក់ (ស្រី ៦ ៤៩៩នាក់)

- សហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលបានព្យួរកិច្ចសន្យាការងារសរុបចំនួន ២០សហគ្រាស មានកម្មករនិយោជិតចំនួន ៣ ៧៩១នាក់ (ស្រី ៣ ០៤២នាក់) ក្នុងនោះ វិស័យកាត់ដេរមានចំនួន ១៤សហគ្រាស មានកម្មករនិយោជិតចំនួន ២ ៩៤០នាក់ (ស្រី ២ ៤៣១នាក់)។ សហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលបានព្យួរកិច្ចសន្យាការងារសរុបចំនួន ៦០សហគ្រាស មានកម្មករនិយោជិតចំនួន ២២ ០២១នាក់ (ស្រី ១៦ ២៤១នាក់) ក្នុងនោះ វិស័យកាត់ដេរមានចំនួន ៣៩សហគ្រាស មានកម្មករនិយោជិតចំនួន ១៣ ២២៦នាក់ (ស្រី ១០ ១២៧នាក់)។

### ២.៣.២. ការលើកកម្ពស់លក្ខខណ្ឌ ស្ដីពីសុវត្ថិភាព និងសុខភាពការងារ

ក្រសួង បានលើកកម្ពស់លក្ខខណ្ឌស្ដីពីសុវត្ថិភាពនិងសុខភាពការងារ ដើម្បីធានាបាននូវសុខុមាលភាពពេញលេញរបស់កម្មករនិយោជិត និងសំដៅលើកកម្ពស់ផលិតភាពការងារ។ ជាលទ្ធផលឆ្នាំ២០២៥ នេះ ក្រសួង៖

- បានផ្ដល់សេវាពិនិត្យកាយសម្បទាជូនកម្មករនិយោជិតខ្មែរ និងបរទេស តាមរយៈនាយកដ្ឋានពេទ្យការងារផ្ទាល់, ការចុះពិនិត្យកាយសម្បទានៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ និងមន្ទីរពេទ្យជាដៃគូសរុបចំនួន ១ ០០២ ៤៤៧នាក់ (ស្រី ៤៦៦ ៣២៥នាក់)

- បានពង្រឹង និងពង្រីកកិច្ចព្រមព្រៀងមូលដ្ឋានសុខាភិបាលរដ្ឋ និងឯកជនចំនួន ១៤៩មន្ទីរពេទ្យ (នៅរាជធានីភ្នំពេញមានចំនួន ៥៩មន្ទីរពេទ្យ និងថ្នាក់ខេត្តមានចំនួន ៩០មន្ទីរពេទ្យ) ក្នុងនោះ មូលដ្ឋានសុខាភិបាលឯកជនចំនួន ១៤៧មន្ទីរពេទ្យ

- បានពិនិត្យសុខភាពពលករខ្មែរ ដែលទៅធ្វើការនៅប្រទេសជប៉ុនចំនួន ១២៩នាក់ (ស្រី ៤៦នាក់) និងសាធារណរដ្ឋកូរ៉េចំនួន ៤ ១៨០នាក់ (ស្រី ១ ២៣៧នាក់)

- បានបង្កើតគណៈកម្មការអេដស៍ និងបង្កើតគោលនយោបាយអេដស៍នៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រចំនួន ៥១៦សហគ្រាស មានសមាជិកសរុបចំនួន ៥ ០៥៤នាក់ (ស្រី ១ ២៤៧នាក់)

- បានរៀបចំបណ្ដុះបណ្ដាលស្ដីពីសុវត្ថិភាព និងសុខភាពការងារសម្រាប់និយោជក និងកម្មករនិយោជិតចំនួន ១៦២វគ្គ មានសិក្ខាកាមចូលរួមចំនួន ៣ ៣១០នាក់ (ស្រី ២ ០២៣នាក់)

- បានរៀបចំកម្មវិធីអប់រំផ្សព្វផ្សាយ និងបណ្ដុះបណ្ដាលស្ដីពីសុវត្ថិភាព និងសុខភាពការងារសរុបចំនួន ៥៦២លើក មានសិក្ខាកាមចូលរួមសរុបចំនួន ១០៩ ១៣៩នាក់ (ស្រី ៧០ ៦២៧នាក់) ក្នុងនោះ ផលប៉ះពាល់នៃគ្រឿងញៀន និងជំងឺអេដស៍ចំនួន ៣១០លើក មានអ្នកចូលរួមចំនួន ៥៦ ៧៤៦នាក់ (ស្រី ៣៦ ៦៧៣នាក់), ការបង្ការជំងឺមិនឆ្លងចំនួន ២៤៩លើក មានអ្នកចូលរួមចំនួន ៥០ ៣៨៣នាក់ (ស្រី ៣២ ៣៥៩នាក់) និងអំពើហិង្សា ការប្រទូស្ដកេរខ្មាសចំនួន ៣លើក មានអ្នកចូលរួមចំនួន ២ ០១០នាក់ (ស្រី ១ ០៥១នាក់)

- បានរៀបចំវគ្គបណ្ដុះបណ្ដាលគ្រូបង្គោល ស្ដីពីការកែលម្អរបៀបធ្វើការនៅក្នុងការដ្ឋានសំណង់ខ្នាតតូច (WISCON) ចំនួន ១វគ្គ មានសិក្ខាកាមចូលរួមចំនួន ៦០នាក់ (ស្រី ១១នាក់)

- បានរៀបចំការបណ្ដុះបណ្ដាលដល់កម្មករនិយោជិតនៃវិស័យសេដ្ឋកិច្ចក្រៅប្រព័ន្ធលើ ៖ ការកែលម្អការងារសម្រាប់សហគ្រាស ខ្នាតតូច (WISE), ការកែលម្អការងារសម្រាប់អ្នកប្រកបការងារតាមផ្ទះ (WISH), ការកែលម្អការងារ និងអភិវឌ្ឍន៍ភូមិដ្ឋានសម្រាប់កសិករ (WIND), ការកែលម្អរបៀបធ្វើការសម្រាប់យុវជន (WINDY), ការកែលម្អរបៀបធ្វើការសម្រាប់ការកែច្នៃ និងគ្រប់គ្រងកាកសំណល់ (WARM) និងការកែលម្អរបៀបធ្វើការនៅក្នុងការដ្ឋានសំណង់ខ្នាតតូច (WISCON) សរុបចំនួន ១៣៣វគ្គ មានសិក្ខាកាមចូលរួមសរុបចំនួន ៣ ៣៩៨នាក់ (ស្រី ១ ៨៩៥នាក់)

- បានរៀបចំទិវាពិភពលោកដើម្បីសុវត្ថិភាព និងសុខភាពការងារអ្នកចូលរួមសរុបចំនួន ១ ៣៩៣នាក់ (ស្រី ៧៩០នាក់)។

រូបភាព ២.៣.២៖ ចំនួនកម្មករនិយោជិតទទួលសេវាពិនិត្យ កាយសម្បទា ខ្មែរ និងបរទេស




*ប្រភព ៖ នាយកដ្ឋានពេទ្យការងារ*

## ២.៣.៣. ការលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារ

ក្រសួង បានដាក់ចេញ និងអនុវត្តវិធានការនានា សំដៅលុបបំបាត់ពលកម្មកុមារ និងទម្រង់ធ្ងន់ធ្ងរបំផុតនៃពលកម្មកុមារយ៉ាងមុតមាំបំផុត ដើម្បីគាំពារសិទ្ធិជាមូលដ្ឋានរបស់កុមារ និងធានាបាននូវការប្រើប្រាស់កម្លាំងពលកម្មប្រកបដោយភាពស្អាតស្អំ។ កម្មវិធីអាទិភាពនេះត្រូវបានអនុវត្តយ៉ាងម៉ឺងម៉ាត់តាមរយៈការធ្វើបច្ចុប្បន្នភាពផែនការសកម្មភាពជាតិ ការតម្រូវឱ្យនិយោជកក្នុងវិស័យដែលមានហានិភ័យចុះកិច្ចសន្យាទប់ស្កាត់ ការអន្តរាគមន៍បន្ទាន់ក្នុងរយៈពេល២៤ម៉ោងលើរាល់បណ្តឹង ការចាត់វិធានការច្បាប់យ៉ាងតឹងរ៉ឹងដោយគ្មានការលើកលែង ព្រមទាំងការផ្សព្វផ្សាយរបាយការណ៍ជាសាធារណៈប្រកបដោយតម្លាភាព។ ក្នុងន័យនេះ ក្រសួង៖

- បានចុះធ្វើអធិការកិច្ចការងារនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រសរុបចំនួន ៥៥៩លើក ក្នុងនោះ អធិការកិច្ចការងារសាមញ្ញចំនួន ២៧៦លើក (បានចុះធ្វើអធិការកិច្ចការងារនៅតាមសិប្បកម្មផលិតឥដ្ឋចំនួន ៩៦សិប្បកម្ម ព្រមទាំងបានធ្វើលិខិតធានាអះអាងស្តីពីការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ ក្នុងរាជធានីភ្នំពេញ ខេត្តកណ្តាល និងខេត្តព្រៃវែង និងធ្វើកិច្ចសន្យារវាងអាណាព្យាបាល និងនិយោជក ស្តីពីការយល់ព្រមទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារចំនួន ៤៦១) តាមដានការដាក់កំហិតចំនួន ៥៦លើក និងអធិការកិច្ចការងារពិសេសចំនួន ២២៧លើក
- បានអនុវត្តកិច្ចអន្តរាគមន៍ស្តូល ទប់ស្កាត់ ការពារការប្រើប្រាស់ពលកម្មកុមារចំនួន ៤០០នាក់ (ស្រី ១៨២នាក់) និងបន្តការគាំពារចំនួន ២០០នាក់ (ស្រី ១០១នាក់) ក្នុងវិស័យសិប្បកម្មផលិតឥដ្ឋ និងកសិ-ឧស្សាហកម្ម នៅខេត្តគោលដៅចំនួន ៧ រួមមាន ខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ ព្រមទាំងបានផ្សព្វផ្សាយស្តីពីការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារសរុបចំនួន ៤៤៧លើក/ទីតាំង មានអ្នកចូលរួមសរុបចំនួន ១២ ៩០០នាក់ (ស្រី ៥ ៣១៤នាក់)
- បានរៀបចំពិធីចែកសម្ភារសិក្សា និងមធ្យោបាយធ្វើដំណើរជូនកុមារដែលបានទប់ស្កាត់ពីការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាស ផលិតឥដ្ឋ ក្បឿង និងកសិ-ឧស្សាហកម្ម តាមរយៈកិច្ចអន្តរាគមន៍ស្តូល ឆ្នាំ២០២៥ ចំនួន៧ខេត្ត រួមមាន ខេត្តកំពង់ធំ ខេត្តព្រៃវែង ខេត្តសៀមរាប ខេត្តក្រចេះ ខេត្តកំពង់ចាម ខេត្តកណ្តាល និងខេត្តត្បូងឃ្មុំ ដែលមានអ្នកចូលរួមសរុប ១ ៦៤៣នាក់ (ស្រី ៧៤៧នាក់)

- បានរៀបចំវគ្គបណ្តុះបណ្តាលចំនួន ៦វគ្គ មានអ្នកចូលរួមសរុបចំនួន ៥៧៣នាក់ (ស្រី ១៣៥នាក់) ក្នុងនោះ វគ្គបណ្តុះបណ្តាលស្តីពីការបង្ការ និងទប់ស្កាត់ ការប្រើប្រាស់ពលកម្មកុមារ នៅតាមសហគ្រាស គ្រឹះស្ថានផលិតឥដ្ឋ ក្បឿងចំនួន ៤វគ្គ មានអ្នកចូលរួមចំនួន ៤៨៩នាក់ (ស្រី ១០៦នាក់), វគ្គបណ្តុះបណ្តាលស្តីពីលក្ខខណ្ឌការងារ សម្រាប់កម្មករនិយោជិតវ័យក្មេងចំនួន ១វគ្គ មានអ្នកចូលរួមចំនួន ៣៧នាក់ (ស្រី ២០នាក់) និងវគ្គបណ្តុះបណ្តាល ពង្រឹងសមត្ថភាពស្តីពីច្បាប់អនុសញ្ញាអន្តរជាតិខាងការងារ លក្ខខណ្ឌការងារសម្រាប់កម្មករនិយោជិតវ័យក្មេង មានអ្នកចូលរួមចំនួន ៤៧នាក់ (ស្រី ៩នាក់)

- បានសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ដើម្បីផ្សព្វផ្សាយសារអំពាវនាវក្នុងការទប់ស្កាត់ ការប្រើប្រាស់ពលកម្មកុមារ តាមរយៈការដាក់បញ្ចូលក្នុងប្រព័ន្ធនិយ័តករទូរគមនាគមន៍កម្ពុជា (TRC) សម្រាប់ ដាក់បញ្ចូលទៅក្នុងសារទូរសព្ទទូទាំងប្រទេស លើខ្លឹមសារ ៖ ១). ហាមឃាត់ដាច់ខាតរាល់ទម្រង់នៃការកេងប្រវ័ញ្ច កម្លាំងពលកម្ម ការងារដោយបង្ខំ និងទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ, ២). ហាមដាច់ខាតការប្រើប្រាស់ទាសភាព បំណុល ដើម្បីដាក់បន្ទុកសេរីភាពការងាររបស់កម្មករនិយោជិត និង ៣) ការប្រើប្រាស់ទម្រង់ធ្ងន់ធ្ងរនៃពលកម្មកុមារ អាចប្រឈមនឹងបទល្មើសព្រហ្មទណ្ឌ។ ករណីមានការសង្ស័យការប្រើប្រាស់ពលកម្មកុមារ សូមទាក់ទង ១២៩៧ ឬ ១២៨៦។

**រូបភាព ២.៣.៣៖ ចំនួនលើក/ទីតាំង និងអ្នកចូលរួមការផ្សព្វផ្សាយស្តីពីការទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារ**




*ប្រភព ៖ នាយកដ្ឋានការងារកុមារ*

## ២.៣.៤. ការពង្រឹងសមត្ថភាពស្ថាប័ន និងតួអង្គពាក់ព័ន្ធក្នុងការពិភាក្សា កំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត

ក្រសួង បានបន្តពង្រឹងសមត្ថភាពសមាជិកក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមាជាប្រចាំ សំដៅបង្កើន ប្រសិទ្ធភាពក្នុងការពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍របស់កម្មករនិយោជិត តាមការវិវត្ត ស្ថានភាពសេដ្ឋកិច្ច សង្គម សំដៅលើកកម្ពស់ជីវភាពរស់នៅរបស់កម្មករនិយោជិត និងគ្រួសារ ក៏ដូចជាបង្កើនភាព ប្រកួតប្រជែងរបស់ប្រទេស។ ជាលទ្ធផល ក្នុងឆ្នាំ២០២៥ នេះ ក្រសួង៖

- បានរៀបចំកិច្ចប្រជុំក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា ដើម្បីពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមា របស់ កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប សម្រាប់ ឆ្នាំ២០២៦ ចំនួន ២៣លើក។ ជាលទ្ធផល ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប ក្នុងឆ្នាំ២០២៦ បានកើនឡើងដល់ ២១០ដុល្លារ អាម៉េរិកក្នុងមួយខែ និងរក្សាប្រាក់អត្ថប្រយោជន៍ផ្សេងៗទៀត ដែលកម្មករនិយោជិតធ្លាប់ទទួលបានកន្លងមក។

ដូច្នេះ ឆ្នាំ២០២៦ ដោយបូករួមទាំងប្រាក់រង្វាន់អតីតភាពការងារ និងប្រាក់អត្ថប្រយោជន៍ផ្សេងៗ កម្មករនិយោជិតម្នាក់ៗទទួលបានប្រាក់ឈ្នួលជាមធ្យមចាប់ពី ២២៧ដុល្លារអាមេរិក ទៅ ២៣៨ដុល្លារអាមេរិកក្នុងមួយខែ។ បើធៀបជាមួយបណ្ដាប្រទេសប្រកួតប្រជែងនាំចេញផលិតផលដូចគ្នា ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជាមានភាពទាក់ទាញ និងរក្សាបានភាពប្រកួតប្រជែងខ្ពស់។

**រូបភាព ២.៣.៤៖ ការវិវត្តនៃប្រាក់ឈ្នួលអប្បបរមា និងអត្ថប្រយោជន៍ផ្សេងៗនៅកម្ពុជា (ជាដុល្លារអាមេរិក/ខែ)**




*ប្រភព៖ អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាជាតិប្រាក់ឈ្នួលអប្បបរមា*

**រូបភាព ២.៣.៥៖ អត្រាប្រាក់ឈ្នួលអប្បបរមារបស់ប្រទេសកម្ពុជា ធៀបបណ្ដាប្រទេសមួយចំនួន សម្រាប់ឆ្នាំ២០២៥**




*ប្រភព៖ ការចងក្រងរបស់ក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ដោយផ្អែកលើស្ថិតិជាតិ, អត្រាប្ដូរប្រាក់គឺជាអត្រាប្ដូរប្រាក់មធ្យមប្រចាំថ្ងៃនៃឆ្នាំ២០២៥ ទាញចេញពីធនាគារកណ្ដាលនៃប្រទេសនីមួយៗ។*

*សម្គាល់៖ ប្រាក់ឈ្នួលអប្បបរមានៃប្រទេសមួយចំនួនត្រូវបានគិតជារូបិយវត្ថុក្នុងស្រុក នៃប្រទេសរៀងៗខ្លួន។ ដូច្នេះ អត្រាប្រាក់ឈ្នួលអប្បបរមាគិតជាដុល្លារអាមេរិក អាចប្រែប្រួលពីមួយខែទៅមួយខែ អាស្រ័យលើគោលនយោបាយរូបិយវត្ថុនៃប្រទេសទាំងនោះ។*

- បានរៀបចំសិក្ខាសាលាត្រីភាគីស្ដីពីបច្ចុប្បន្នភាពសេដ្ឋកិច្ច និងសង្គម និងនិន្នាការប្រាក់ឈ្នួលអប្បបរមា នៅកម្ពុជា និងក្នុងតំបន់

- បានរៀបចំអង្កេត និងរបាយការណ៍លទ្ធផលស្ដីពីជីវភាពរស់នៅរបស់កម្មករនិយោជិត ការយល់ដឹង និងផ្ដត់គំនិតរបស់កម្មករនិយោជិត និយោជក លើការកំណត់ប្រាក់ឈ្នួលអប្បបរមា សម្រាប់ឆ្នាំ២០២៦

- បានរៀបចំអង្កេតរហ័ស និងរបាយការណ៍លទ្ធផលស្ដីពីការយល់ឃើញរបស់កម្មករនិយោជិតលើការកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២៥ និងឆ្នាំ២០២៦

- បានសហការជាមួយអង្គការ ILO ដើម្បីសិក្សាលទ្ធភាពក្នុងការពង្រីកវិសាលភាពនៃការអនុវត្តប្រាក់ឈ្នួលអប្បបរមាសម្រាប់វិស័យក្រៅពីវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប

- បានធ្វើបច្ចុប្បន្នភាពផ្ទាំងសូចនាករសេដ្ឋកិច្ច និងទីផ្សារការងារ (Dashboard) ប្រចាំខែស្ដីពី៖ ប្រាក់ឈ្នួលមធ្យម ប្រាក់ឈ្នួលអប្បបរមា និងប្រាក់ឈ្នួលអប្បបរមាបូករួមអត្ថប្រយោជន៍ផ្សេងៗ ក្នុងវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប, ការនាំចេញផលិតផលវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូបរបស់បណ្ដាប្រទេសរួមមាន វៀតណាម ឥណ្ឌូណេស៊ី បង់ក្លាដែស ប៉ាគីស្ថាន មីយ៉ាន់ម៉ា និងស្រីលង្កា គិតត្រឹមខែកុម្ភៈ ឆ្នាំ២០២៥ ទៅកាន់សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ប្រភពពីគណៈកម្មការពាណិជ្ជកម្មអន្តរជាតិអាម៉េរិក និង Eurostat និងតម្រូវការផលិតផលគ្រប់មុខ និងផលិតផលសម្លៀកបំពាក់ ស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប របស់សហរដ្ឋអាម៉េរិក និងសហភាពអឺរ៉ុប ៨ខែដើមឆ្នាំ២០២៥

- បានកំពុងសិក្សា និងធ្វើបច្ចុប្បន្នភាពតម្រូវការរបស់កម្មករ និងគ្រួសារស្របតាមវិធីសាស្ត្រគណនាថ្មីរបស់អង្គការ ILO ។

### ២.៣.៥. ការលើកកម្ពស់សុខដុមនីយកម្ម នៃទំនាក់ទំនងវិជ្ជាជីវៈ

ក្រសួង បានលើកកម្ពស់សុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ សំដៅប្រែក្លាយសហគ្រាសមួយជាសហគមន៍សុខសាន្តមួយ។ កម្មវិធីអាទិភាពនេះត្រូវបានជំរុញយ៉ាងសកម្មតាមរយៈការដាក់ចេញនូវកម្មវិធីប្រកួតប្រជែងជ្រើសរើស និងប្រគល់ពានរង្វាន់សហគ្រាសមួយជាសហគមន៍សុខសាន្តមួយប្រចាំឆ្នាំ ការរក្សាអត្រាសះជានៃការផ្សះផ្សាវិវាទការងារក្នុងកម្រិតខ្ពស់ ការធានាសេរីភាពអង្គការវិជ្ជាជីវៈ និងការអន្តរាគមន៍ដោះស្រាយកូដកម្ម បាតុកម្មប្រកបដោយប្រសិទ្ធភាពខ្ពស់។ ក្នុងន័យនេះ ក្រសួងសម្រេចបាននូវសមិទ្ធផលសំខាន់ៗជាច្រើន ដូចខាងក្រោម។

#### ក. ការចុះបញ្ជីអង្គការវិជ្ជាជីវៈ

- បានលើកកម្ពស់សិទ្ធិសេរីភាពអង្គការវិជ្ជាជីវៈ តាមរយៈការចុះបញ្ជីរបស់អង្គការវិជ្ជាជីវៈថ្មីសរុបចំនួន ៣៣៧ ក្នុងនោះ សហព័ន្ធសហជីពចំនួន ៤, សហជីពមូលដ្ឋានចំនួន ៣៣២ និងសមាគមនិយោជកចំនួន ១។ បើគិតត្រឹមឆ្នាំ២០២៥ នេះ អង្គការវិជ្ជាជីវៈសរុបមានចំនួន ៦ ៨៤៨ ក្នុងនោះ សហភាពសហជីពមានចំនួន ៤២, សហព័ន្ធសហជីពមានចំនួន ២៨៤, សហជីពមូលដ្ឋានមានចំនួន ៦ ៥០៩ និងសមាគមនិយោជកមានចំនួន ១៣។

## រូបភាពទី ២.៣.៦៖ បច្ចុប្បន្នភាពការចុះបញ្ជីអង្គការវិជ្ជាជីវៈ




*ប្រភព ៖ នាយកដ្ឋានវិវាទការងារ*

### ខ. ការដោះស្រាយវិវាទការងារ

- បានដោះស្រាយវិវាទការងារសរុបចំនួន ១ ៤៦១ករណី (មានវិវាទបុគ្គលចំនួន ១ ១៧២ករណី ស្មើនឹង ៨០,២២% និងវិវាទការងាររួមចំនួន ២៨៩ករណី ស្មើនឹង ១៩,៧៨%) លទ្ធផលសះជាចំនួន ១ ៣៣៣ករណី ស្មើនឹង ៩១,២៤%, មិនសះជាចំនួន ១១១ករណី ស្មើនឹង ៧,៦០% និងមោឃៈចំនួន ១៧ករណី ស្មើនឹង ១,១៦%

- អត្រាសះជានៃការដោះស្រាយវិវាទការងាររួម ទាំងនៅកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្តាល ចំនួន ៩៧,៩២% ដែលនេះបង្ហាញពីភាពល្អប្រសើរ នៃការកែសម្រួលយន្តការដោះស្រាយវិវាទការងាររបស់ក្រសួង ព្រមទាំងការយល់ដឹងរបស់អ្នកពាក់ព័ន្ធក្នុងការដោះស្រាយវិវាទ ដែលធ្វើឱ្យអត្រាសះជាមានកម្រិតខ្ពស់។

**រូបភាព ២.៣.៧៖ ចំនួនវិវាទបុគ្គល និងអត្រាសះជា នៅកម្រិតមន្ត្រីផ្សះផ្សា**




*ប្រភព ៖ នាយកដ្ឋានវិវាទការងារ*

**រូបភាព ២.៣.៨៖ ចំនួនវិវាទការងាររួម និងអត្រាសះជា នៅកម្រិតមន្ត្រីផ្សះផ្សា**




*ប្រភព ៖ នាយកដ្ឋានវិវាទការងារ*

រូបភាព ២.៣.៩៖ ចំនួនវិវាទការងារសរុប និងអត្រាសះជា នៅកម្រិតមន្ត្រីផ្សះផ្សា




ប្រភព ៖ នាយកដ្ឋានវិវាទការងារ

រូបភាព ២.៣.១០៖ អត្រាដោះស្រាយវិវាទការងាររួមសះជាទាំង នៅកម្រិតមន្ត្រីផ្សះផ្សា និងក្រុមប្រឹក្សាអាជ្ញាកណ្ដាល




ប្រភព ៖ នាយកដ្ឋានវិវាទការងារ

## គ. ការដោះស្រាយបញ្ហាកូដកម្ម បាតុកម្ម នៅតាមគ្រប់មុខសញ្ញា

- បានពង្រឹងយន្តការដោះស្រាយកូដកម្ម បាតុកម្មក្នុងវិស័យការងារ ដោយបានអន្តរាគមន៍ដោះស្រាយសរុប ចំនួន ១៣៣សហគ្រាស ស្មើនឹង ១៣៥ករណី ក្នុងនោះ កូដកម្មចំនួន ១២៤សហគ្រាស ស្មើនឹង ១២៦ករណី ដោះស្រាយសះជាចំនួន ១០០% និងបាតុកម្មចំនួន ៩សហគ្រាស ស្មើនឹង ៩ករណី ដោះស្រាយសះជាចំនួន ១០០%។

រូបភាព ២.៣.១១៖ ចំនួនករណីកូដកម្ម និង អត្រាដោះស្រាយសះជា




ប្រភព ៖ អ.គ.ក.ប.

រូបភាព ២.៣.១២៖ ចំនួនករណីបាតុកម្ម និង អត្រាដោះស្រាយសះជា




ប្រភព ៖ អ.គ.ក.ប.

### ២.៤. ការពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព

#### ២.៤.១. ការពង្រឹង និងពង្រីកទីផ្សារការងារនៅបរទេសដែលមានលក្ខខណ្ឌការងារល្អ

ក្រសួង បានបន្តពង្រីកទីផ្សារការងារនៅក្រៅប្រទេស ដើម្បីផ្តល់ជំរើស និងលទ្ធភាពឱ្យប្រជាជនកម្ពុជាអាចធ្វើការងារនៅក្រៅប្រទេស បន្ថែមលើឱកាសការងារ ដែលមានក្នុងស្រុក។ កម្មវិធីអាទិភាពនេះត្រូវបានអនុវត្តយ៉ាងសកម្មតាមរយៈការចុះកិច្ចព្រមព្រៀង សហប្រតិបត្តិការជាមួយប្រទេសទទួល ការវាយតម្លៃទីផ្សារការងារ ការបង្កើនការបញ្ជូនពលករជំនាញទៅកាន់ប្រទេសអភិវឌ្ឍន៍ និងការធ្វើបច្ចុប្បន្នភាពគោលនយោបាយជាតិ សំដៅធានាបាននូវការធ្វើទេសន្តរប្រវេសន៍ប្រកបដោយសុវត្ថិភាព និងទទួលបានប្រាក់ចំណូលខ្ពស់។ ក្នុងន័យនេះក្រសួងៈ

- បានតំណាងឱ្យរាជរដ្ឋាភិបាលចុះកិច្ចព្រមព្រៀងរវាងកម្ពុជា និងរដ្ឋអ៊ីស្រាអែល ស្តីពីការងារបណ្តោះអាសន្នរបស់ពលករខ្មែរក្នុងវិស័យទីផ្សារការងារជាក់លាក់នៅរដ្ឋអ៊ីស្រាអែល
- បានពង្រីកបន្ថែមប្រភេទការងារសម្រាប់ការបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសសិង្ហបុរី ក្នុងវិស័យកម្មន្តសាល សេវាកម្ម សំណង់ និងផលិតនាវា
- បានធ្វើវិសោធនកម្មអនុស្សរណៈ នៃការយោគយល់គ្នារវាង រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រថៃឡង់ដ៍ ស្តីពីកិច្ចសហប្រតិបត្តិការនៃវិស័យការងារ
- បានធ្វើវិសោធនកម្មកិច្ចព្រមព្រៀង ស្តីពីការប្រើប្រាស់កម្លាំងពលកម្ម រវាងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា និងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រថៃឡង់ដ៍
- បានជួបពិភាក្សាជាមួយស្ថានទូតរុស្ស៊ីដើម្បីចរចា និងរៀបចំផែនការក្នុងការចុះ MoU ជាមួយប្រទេសរុស្ស៊ី
- បានចូលរួមកិច្ចប្រជុំពិភាក្សាក្រុមការងាររួមដើម្បីពិនិត្យអនុវត្តនៃអនុស្សរណៈនៃកិច្ចសហប្រតិបត្តិការ (MOC) និងពិភាក្សាលើស្ថានភាពនៃបញ្ជូនពលករខ្មែរទៅក្រៅប្រទេស ជាមួយរដ្ឋបាលខេត្តមីយ៉ាហ្គិ នៃប្រទេសជប៉ុន។

#### ២.៤.២. ការពង្រឹងយន្តការ តម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពក្នុងការជ្រើសរើសការបណ្តុះបណ្តាល និងការបញ្ជូនពលករទៅធ្វើការនៅបរទេស

ក្រសួង បានពង្រឹងយន្តការជ្រើសរើស បណ្តុះបណ្តាល និងបញ្ជូនពលករទៅធ្វើការនៅបរទេស ប្រកបដោយតម្លាភាព គណនេយ្យភាព និងប្រសិទ្ធភាពខ្ពស់ ដើម្បីធានាសុវត្ថិភាពដល់កម្លាំងពលកម្ម តាមរយៈការកាត់បន្ថយថ្លៃសេវាបញ្ជូន ការចាត់វិធានការម៉ឺងម៉ាត់ចំពោះការជ្រើសរើសខុសច្បាប់ ការធានាអនុលោមភាពរបស់ទីភ្នាក់ងារជ្រើសរើសឯកជនតាមប្រព័ន្ធឌីជីថល និងការដាក់ឱ្យដំណើរការមជ្ឈមណ្ឌលរួមសម្រាប់ការបណ្តុះបណ្តាលនិងធ្វើតេស្តជំនាញ សំដៅលើកកម្ពស់គុណភាពនៃការផ្តល់សេវាជូនប្រជាពលរដ្ឋ។ ជាលទ្ធផលក្នុងឆ្នាំ២០២៥ នេះក្រសួងៈ

- បានចេញប្រកាសលេខ៣១២/២៥ក.ប/ប្រ.ក.ម.ហ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ ស្តីពីការវាយតម្លៃទីភ្នាក់ងារជ្រើសរើសឯកជន
- បានចេញលិខិតណែនាំដល់ទីភ្នាក់ងារជ្រើសរើសឯកជន ស្តីពីការពង្រឹងការអនុវត្តរបស់ទីភ្នាក់ងារជ្រើសរើសឯកជន ការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស

៣១

- បានផ្តល់ប្រកាសអនុញ្ញាតដល់ក្រុមហ៊ុនជាទីភ្នាក់ងារជ្រើសរើសឯកជនធ្វើការជ្រើសរើស បណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេស ដោយគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ មានចំនួន ១៤៩ ក្រុមហ៊ុន ក្នុងនោះកំពុងដំណើរការចំនួន ១១២ក្រុមហ៊ុន និងគណៈកម្មាធិការបណ្តុះបណ្តាល និងបញ្ជូនពលករទៅបរទេស (គ.ប.ប.ព.ប.) ចំនួន ១

- បានធ្វើបច្ចុប្បន្នភាព ផ្សព្វផ្សាយ និងផ្ទៀងផ្ទាត់តាមប្រព័ន្ធព័ត៌មានវិទ្យានូវបញ្ជីឈ្មោះទីភ្នាក់ងារជ្រើសរើសឯកជនបញ្ជូនពលករស្របច្បាប់ និងបានជូនដំណឹងដល់ក្រសួង ស្ថាប័នពាក់ព័ន្ធជាប្រចាំ

- បានធ្វើបទបង្ហាញស្តីពីយន្តការគ្រប់គ្រង និងនីតិវិធីនៃការជ្រើសរើសបណ្តុះបណ្តាល បញ្ជូន និងគ្រប់គ្រងពលករខ្មែរទៅធ្វើការនៅបរទេសប្រកបដោយក្រមសីលធម៌ ដល់ទីភ្នាក់ងារជ្រើសរើសឯកជន

- បានចេញលិខិតបញ្ជាក់កិរិយាមាយាទរបស់ពលករ/កម្មសិក្សាការី មុនចេញទៅធ្វើការនៅបរទេស

- បានបញ្ចូលកម្រៃសេវាអតិបរមាក្នុងប្រព័ន្ធគ្រប់គ្រងពលករទេសន្តរប្រវេសន៍ខ្មែរ ក្នុងការជ្រើសរើស និងបញ្ជូនកម្មសិក្សាការី និងពលករជំនាញ ទៅធ្វើការនៅប្រទេសជប៉ុន

- បានដាក់ឱ្យដំណើរការបញ្ជរសេវាសាធារណៈចល័ត (Mobile Public Service Counter) ឬកម្មវិធីក្នុងទូរសព្ទដៃដែលមានឈ្មោះ “MLVT Services” នៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ ដើម្បីបង្កើនភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានបំណងចង់ដាក់ពាក្យទៅធ្វើការនៅបរទេស ដែលមាននៅតាមទីតាំងមួយចំនួនដូចជា ទីស្តីការក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សាលារៀន TVET ផ្សារទំនើប បណ្តាសាកលវិទ្យាល័យមួយចំនួន ហាងកាហ្វេ

- បានបញ្ជូនពលករ ពលការិនីទៅធ្វើការនៅបរទេសសរុបចំនួន ២៣ ៤៣៥នាក់ (ស្រី ៨ ៩៥៩នាក់) តាមវិស័យដូចជា ឧស្សាហកម្ម, កសិកម្ម, សំណង់, ការងារផ្ទះ និងការងារផ្សេងៗ ក្នុងនោះ ៖

- ប្រទេសថៃចំនួន ១០ ៨០៣នាក់ (ស្រី ៤ ៧៤៥នាក់)
- សាធារណរដ្ឋកូរ៉េចំនួន ៥ ៨៨៥នាក់ (ស្រី ១ ៤៦០នាក់)
- ប្រទេសជប៉ុនចំនួន ៦ ៧២៧នាក់ (ស្រី ២ ៧៣៤នាក់)
- ប្រទេសសិង្ហបុរីមានពលការិនីចំនួន ២០នាក់។

- បើគិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥ នេះ មានពលករទេសន្តរប្រវេសន៍ខ្មែរកំពុងស្នាក់នៅ និងធ្វើការនៅក្រៅប្រទេសសរុបចំនួន ៤៣៣ ៥៩៤នាក់ (ស្រី ១៥០ ៣៩៣នាក់) ប្រាក់បញ្ញើដែលបានផ្ញើចូលក្នុងប្រទេសសម្រាប់ឆ្នាំ២០២៥ ចំនួន ១,៨៦ពាន់លានដុល្លារអាមេរិក ដែលបានចូលរួមចំណែកយ៉ាងសំខាន់ក្នុងការលើកកម្ពស់ជីវភាពគ្រួសាររបស់ប្រជាជន ព្រមទាំងចូលរួមចំណែកក្នុងការលើកកម្ពស់សុខភាព និងការអប់រំរបស់សមាជិកគ្រួសារនៃពលករទេសន្តរប្រវេសន៍កម្ពុជា

- បានផ្តល់ការណែនាំតម្រង់ទិសពលករមុនចេញដំណើរទៅធ្វើការនៅបរទេសចំនួន ៦២ទីភ្នាក់ងារ បានចំនួន ៦៧៥លើក មានពលករចំនួន ១៨ ៤៨៥នាក់ (ស្រី ៦ ៨៤០នាក់)

- បានទទួល និងដោះស្រាយពាក្យបណ្តឹងរបស់ពលករទេសន្តរប្រវេសន៍ខ្មែរចំនួន ២២សំណុំរឿង មានពលករចំនួន ៥០នាក់ (ស្រី ២៣នាក់) ដោះស្រាយសះជាទាំង ២២សំណុំរឿង មានពលករចំនួន ៥០នាក់ (ស្រី ២៣នាក់)។

តារាង ២.៤.១៖ ចំនួនពលករកម្ពុជា ដែលត្រូវបានបញ្ជូនទៅធ្វើការនៅបរទេសក្នុងឆ្នាំ២០២៤ និងឆ្នាំ២០២៥

| ល.រ | ប្រទេស | ២០២៤ | | ២០២៥ | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | |
| ១ | ប្រទេសថៃ | 30,590 | 13,430 | 10,803 | 4,745 | -64.68% |
| ២ | សាធារណរដ្ឋកូរ៉េ | 9,036 | 1,645 | 5,885 | 1,460 | -34.87% |
| ៣ | ប្រទេសជប៉ុន | 5,093 | 2,052 | 6,727 | 2,734 | 32.08% |
| ៤ | ប្រទេសសិង្ហបុរី | 34 | 34 | 20 | 20 | -41.18% |
| ៥ | តំបន់រដ្ឋបាលពិសេសហុងកុង | 31 | 31 | 0 | 0 | -100.00% |
| ៦ | ប្រទេសម៉ាឡេស៊ី | 0 | 0 | 0 | 0 | - |
| ៧ | ប្រទេសអារ៉ាប៊ីសាអូឌីត | 78 | 78 | 0 | 0 | -100.00% |
| | **សរុបរួម** | **44,862** | **17,270** | **23,435** | **8,959** | **-47.76%** |

*ប្រភព៖ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងគណៈកម្មាធិការបណ្ដុះបណ្ដាល និងបញ្ជូនពលករទៅបរទេស*

រូបភាព ២.៤.១៖ ពលករទេសន្តរប្រវេសន៍កម្ពុជាកំពុងស្នាក់នៅ និងធ្វើការនៅបរទេស គិតត្រឹមឆ្នាំ២០២៥




*ប្រភព៖ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងគណៈកម្មាធិការបណ្ដុះបណ្ដាល និងបញ្ជូនពលករទៅបរទេស_គិតត្រឹម ៣១ ធ្នូ ២០២៥*

### ២.៤.៣. ការពង្រឹងយន្តការគ្រប់គ្រង និងសេវាគាំពារនៅតាមប្រទេសទទួល ដល់ពលករទេសន្តរប្រវេសន៍កម្ពុជា

ក្រសួងបានពង្រឹងយន្តការគ្រប់គ្រង និងសេវាគាំពារនៅតាមប្រទេសទទួលដល់ពលករទេសន្តរប្រវេសន៍កម្ពុជា តាមរយៈការចាត់តាំងអនុព័ន្ធការងារអមស្ថានឯកអគ្គរាជទូត/ស្ថានអគ្គកុងស៊ុល/ស្ថានកុងស៊ុល នៅប្រទេសដែលមានពលករកម្ពុជាធ្វើការមានចំនួន ៤ប្រទេស ដូចជា សាធារណរដ្ឋកូរ៉េ ២រូប ប្រទេសថៃ ៣រូប ប្រទេសម៉ាឡេស៊ី ២រូប និងប្រទេសជប៉ុន ១រូប ដើម្បីសម្របសម្រួលអន្តរាគមន៍ដោះស្រាយបញ្ហានានារបស់ពលករដែលកើតមានឡើងក្នុងពេលបំពេញការងារ ការពារផលប្រយោជន៍ពលករកម្ពុជា លើកកម្ពស់ និងស្វែងរកឱកាសការងារ សម្រាប់ពលករនៅប្រទេសទទួល។ ក្នុងឆ្នាំ២០២៥ នេះ ក្រសួង៖

- បានចុះសួរសុខទុក្ខ និងសំណេះសំណាលជាមួយនិស្សិតសហគមន៍ខ្មែរ និងពលករខ្មែរចំនួន ២៧៤កន្លែង មានអ្នកចូលរួមចំនួន ៣១ ៣៥៥នាក់ (ស្រី ៩ ៥២៥នាក់) និងបានចុះចែកស្បៀងអាហារជូនពលករខ្មែរ ដែលខ្វះខាត ពិការ ជំងឺរ៉ាំរ៉ៃ ជួបគ្រោះថ្នាក់ចរាចរណ៍ ស្លាប់ និងជួបទុក្ខលំបាកដែលកំពុងស្វែងរកការងារថ្មីចំនួន ២៩កន្លែង ចំនួន ១ ៤១៩នាក់

- បានសម្របសម្រួល និងដោះស្រាយវិវាទការងារ និងបញ្ហាផ្សេងៗ របស់ពលករខ្មែរ និងទីភ្នាក់ងារជ្រើសរើសឯកជនចំនួន ៤៦២ករណី ដែលមានពលករពាក់ព័ន្ធចំនួន ៧០៧នាក់ (ស្រី ១៥៩នាក់) ទទួលបានសះជា ១០០%

- បានចេញសេចក្តីអំពាវនាវស្តីពីការរក្សាសុវត្ថិភាព ក្នុងការធ្វើដំណើរវិលត្រឡប់របស់ពលករខ្មែរមកពីប្រទេសថៃ

- បានចេញលិខិតចំហអំពាវនាវដល់ម្ចាស់ម៉ាក និងអ្នកបញ្ជាទិញដែលទិញទំនិញពីប្រទេសថៃ និងអ្នកប្រើប្រាស់ផលិតផលនិងសេវារបស់ថៃ ឱ្យចូលរួមតាមដានស្ថានភាពនៃការរំលោភបំពានសិទ្ធិពលករទេសន្តប្រវេសន៍នៅប្រទេសថៃ

- បានប្រើប្រាស់យន្តការនានា ដើម្បីធានាបាននូវការការពារពលករខ្មែរកំពុងស្នាក់នៅ និងធ្វើការនៅប្រទេសថៃ ពីការរើសអើស, ការប្រើហិង្សា, ការគំរាមកំហែង និងការធ្វើទុក្ខបុកម្នេញនានា ដោយបានចេញលិខិតស្នើសុំកិច្ចសហការផ្តល់ការការពារ ទៅអង្គការ ILO នៅទីក្រុងហ្សឺណែវ និងទីក្រុងបាងកក និងអង្គការអន្តរជាតិទេសន្តប្រវេសន៍នៅទីក្រុងហ្សឺណែវ រាជធានីភ្នំពេញ និងទីក្រុងបាងកក

- បានចេញសេចក្តីអំពាវនាវ ស្តីពីការរក្សាសុវត្ថិភាពការធ្វើដំណើរវិលត្រឡប់របស់ពលករខ្មែរមកពីប្រទេសថៃ។

### ២.៤.៤. ការពង្រឹងយន្តការ នៃការធ្វើសមាហរណកម្មពលករទេសន្តប្រវេសន៍កម្ពុជា ដែលធ្វើមាតុភូមិនិវត្តន៍

ក្រសួងបានជំរុញការធ្វើសមាហរណកម្មពលករខ្មែរ ដែលធ្វើមាតុភូមិនិវត្តន៍ចូលទីផ្សារការងារក្នុងស្រុក ដោយបានចុះឈ្មោះធ្វើតេស្តវាយតម្លៃផ្អែកលើសមត្ថភាព ដើម្បីទទួលបានគុណវុឌ្ឍិ និងរៀបចំយន្តការទំនាក់ទំនងជាប្រចាំជាមួយគ្រួសាររបស់ពលករទេសន្តប្រវេសន៍ ដើម្បីផ្តល់ព័ត៌មាន និងអន្តរាគមន៍នៅពេលមានអាសន្ន ព្រមទាំងបានចងក្រងបណ្តាញ និងផ្សព្វផ្សាយបទពិសោធនៃភាពជោគជ័យរបស់ពលករខ្មែរ។ ក្នុងឆ្នាំ២០២៥នេះ ពលករខ្មែរបានធ្វើមាតុភូមិនិវត្តន៍សរុបចំនួន ៩៧២ ៧៥៨នាក់ (ស្រី ៤២១ ៧៥៣នាក់)។ ដើម្បីជួយគាំទ្រពលករ ដែលធ្វើមាតុភូមិនិវត្តន៍វិញ ក្រសួងបាន៖

- បានធ្វើបុរេសកម្ម ដោយសហការជាមួយរដ្ឋបាលខេត្តនៅជាប់ព្រំដែន ដើម្បីរៀបចំ និងដាក់ឱ្យដំណើរការមណ្ឌលសំចត នៅតាមច្រកព្រំដែនអន្តរជាតិសំខាន់ៗ ចំនួន ៦ រួមមាន ច្រកចាំយាម ខេត្តកោះកុង, ច្រកព្រំ ខេត្តប៉ៃលិន, ច្រកដូង និងច្រកភ្នំដី ខេត្តបាត់ដំបង, ច្រកប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ និងច្រកអូរស្មាច់ ខេត្តឧត្តរមានជ័យចាប់ពីសប្តាហ៍ទី១ ខែមិថុនា ឆ្នាំ២០២៥ និងបានចាត់មន្ត្រីមកពីអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួង សហការជាមួយរដ្ឋបាលខេត្ត អាជ្ញាធរពាក់ព័ន្ធ សហភាពសហព័ន្ធយុវជនកម្ពុជា និងម្ចាស់សហគ្រាសក្រុមហ៊ុន និងរោងចក្រ ដើម្បីការសម្រួលនីតិវិធីឯកសារឱ្យប្រជាពលរដ្ឋ និងពលករអាចឆ្លងកាត់ព្រំដែនមានលក្ខណៈងាយស្រួលនិងឆាប់រហ័ស ជួយលើកសម្ភារ ជួយផ្តល់អាហារ និងភេសជ្ជៈជូនដល់ពលករ ដែលមានកុមារតូចៗមកជាមួយ ជួយចុះឈ្មោះ និងផ្តល់បញ្ជីឈ្មោះរោងចក្រដែលកំពុងមានតម្រូវការជ្រើសរើសបុគ្គលិកនិង បញ្ជីឈ្មោះគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ មុនពេលពលករឡើងរថយន្ត ដែលផ្តល់ដោយរាជរដ្ឋាភិបាលដោយមិនគិតថ្លៃឆ្ពោះទៅស្រុកកំណើត

- បានដាក់ឱ្យដំណើរការប្រព័ន្ធ Hotline ១២៩៧ ដោយបន្ថែមកម្លាំង មន្ត្រីប្រចាំការ ៧ថ្ងៃ/សប្តាហ៍ ដែលអាចទទួលការហៅចូលដល់ ៣០នាក់ ក្នុងពេលតែមួយ ដើម្បីផ្តល់ការងារទៅសហគ្រាស ក្រុមហ៊ុន និងរោងចក្រ និងរៀបចំយុទ្ធនាការផ្សព្វផ្សាយនៅតាមទីសាធារណៈ និងធ្វើការផ្សព្វផ្សាយតាម Billboard LED ចំនួន ២៩ទីតាំង និង Billboard PVC ចំនួន ១៧ទីតាំង នៅទូទាំងប្រទេស

- បានរៀបចំវេទិកាការងារ និងរៀបចំពិព័រណ៍ការងារតាមបណ្តាខេត្តសរុបបានចំនួន ៥៧៩លើក និងបន្តរៀបចំពិព័រណ៍នេះបន្ថែមនៅតាមបណ្តាខេត្តនានាជាប់ព្រំដែន និងខេត្តដែលមានពលករវិលត្រឡប់មកវិញច្រើន

- កំណត់យកសាខាបេឡាជាតិសន្តិសុខសង្គម និងគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈនៅតាមរាជធានី ខេត្ត ជាទីតាំងដែលបងប្អូនពលករអាចទៅចុះឈ្មោះស្វែងរកការងារ និងសម្ភាសការងារដោយផ្ទាល់ និងតាមប្រព័ន្ធហ្សូម ជាមួយសហគ្រាស ក្រុមហ៊ុន និងរោងចក្រនានា

- បានសហការជាមួយសហភាពសហព័ន្ធយុវជនកម្ពុជា (ស.ស.យ.ក.) រៀបចំឱ្យមានយុវជនស្ម័គ្រចិត្តឃុំ-សង្កាត់ជាភ្នាក់ងារព័ត៌មានទីផ្សារការងារ ដើម្បីជួយផ្សព្វផ្សាយឱកាសការងារ និងចុះឈ្មោះជូនអ្នកស្វែងរកការងារនៅតាមឃុំ-សង្កាត់

- បានចេញសេចក្តីជូនដំណឹងលើកលែងលក្ខខណ្ឌ តម្រូវឱ្យភ្ជាប់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរក្នុងការដាក់ពាក្យធ្វើការ ដើម្បីសម្រួលដល់បងប្អូនដែលទើបវិលត្រឡប់ ហើយពុំមានឯកសារ បាត់ឯកសារ ឯកសារផុតសុពលភាព អាចចូលធ្វើការបាន និងបានចេញសេចក្តីជូនដំណឹង និងអនុវត្តវិធានការផាកពិន័យចំពោះសហគ្រាស ក្រុមហ៊ុន និងរោងចក្រ ដែលតម្រូវឱ្យភ្ជាប់អត្តសញ្ញាណបណ្ណសញ្ជាតិខ្មែរ ក្នុងការដាក់ពាក្យធ្វើការ ដើម្បីសម្រួលការចូលធ្វើការរបស់ពលករដែលមិនមានឯកសារសម្គាល់ខ្លួន

- បានចុះតាមរោងចក្រចំនួន ១ ៦០៤រោងចក្រ ដើម្បីផ្សព្វផ្សាយ ជួយពន្យល់ដោយផ្ទាល់ដល់អ្នកគ្រប់គ្រងរោងចក្រឱ្យមានការយោគយល់ចំពោះបងប្អូនពលករ និងឱ្យជួយបង្ហាត់បង្រៀនបងប្អូនពលករដែលទើបចូលធ្វើការថ្មីចំនួន ១សប្តាហ៍

- បានត្រៀមវិធានការអន្តរាគមន៍បន្ថែមមួយចំនួនទៀតដូចជា ការផ្តល់ការបណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1) នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ, ការបើកវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ក្នុងវិស័យកសិកម្ម និងសេវាកម្ម តាមលិខិតបញ្ជាក់ (Voucher Skills Training Programme), ការពង្រីកការចុះឈ្មោះ និងផ្តល់ការងារ និងការអនុវត្តការវាយតម្លៃផ្អែកលើសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន (RPL)

- **ជាលទ្ធផល គិតត្រឹមខែធ្នូ ឆ្នាំ២០២៥ នេះ** មានអតីតពលករប្រមាណ ៦២ម៉ឺននាក់ ទទួលបានការងារធ្វើ ដែលក្នុងនោះ ប្រមាណ ៣១ម៉ឺននាក់ បានចូលធ្វើការនៅក្នុងសហគ្រាស ក្រុមហ៊ុន និងរោងចក្រ ហើយប្រមាណ ៣១ម៉ឺននាក់ ផ្សេងទៀត បានទទួលការងារនៅតាមសហគ្រាសធុនតូចនិងមធ្យម ជាសិប្បកម្ម កោដនីយដ្ឋាន និងនៅតាមការដ្ឋានសំណង់ជាដើម។

### តារាង ២.៤.២៖ ពលករទេសន្តរប្រវេសន៍កម្ពុជាដែលធ្វើមាតុភូមិនិវត្តន៍

| ល.រ | ប្រទេស | ២០២៤ | | ២០២៥ | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | |
| ១ | ប្រទេសថៃ | 468 | 214 | 957,888 | 416,615 | 204,576.92% |
| ២ | សាធារណរដ្ឋកូរ៉េ | 12,992 | 3,508 | 8,308 | 2,004 | -36.05% |
| ៣ | ប្រទេសជប៉ុន | 4,096 | 2,207 | 6,185 | 2,771 | 51.00% |
| ៤ | ប្រទេសសិង្ហបុរី | 472 | 472 | 250 | 250 | -47.03% |
| ៥ | តំបន់រដ្ឋបាលពិសេសហុងកុង | 125 | 125 | 88 | 88 | -29.60% |
| ៦ | ប្រទេសម៉ាឡេស៊ី | 280 | 280 | 34 | 20 | -87.86% |
| ៧ | ប្រទេសអាប៊ីសាអូឌីត | 128 | 128 | 5 | 5 | -96.09% |
| **សរុបរួម** | | **18,561** | **6,934** | **972,758** | **421,753** | **5,140.87%** |

*ប្រភព៖ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម និងគណៈកម្មាធិការបណ្តុះបណ្តាលនិងបញ្ជូនពលករទៅបរទេស*

### ២.៤.៥. ការពង្រឹងការគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជា

ក្រសួង បានពង្រឹងការគ្រប់គ្រងហត្ថពលកម្មបរទេសនៅកម្ពុជាប្រកបដោយប្រសិទ្ធភាពខ្ពស់ ដើម្បីបំពេញតម្រូវការជំនាញក្នុងស្រុក និងកសាងភាពធន់នៃកម្លាំងពលកម្មជាតិ។ កម្មវិធីអាទិភាពនេះត្រូវបានអនុវត្ត តាមរយៈការធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រង ការជំរុញអនុលោមភាពរបស់សហគ្រាស ក្រុមហ៊ុន រោងចក្រ ការវាយតម្លៃពីតម្រូវការហត្ថពលកម្មបរទេសជាក់ស្តែង សំដៅទាញយកអត្ថប្រយោជន៍ជាអតិបរមាសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ក៏ដូចជារក្សាបាននូវការងារជូនកម្លាំងពលកម្មក្នុងស្រុក។ ក្នុងន័យនេះ ក្រសួង៖

- បានចេញលិខិតអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស (កូតា) ចំនួន ៧ ៨៥៥ក្រុមហ៊ុន និងបានចុះបញ្ជិកាលើកិច្ចសន្យាការងារជនបរទេសចំនួន ៥៩ ៦២៦នាក់ (ស្រី ១៦ ៧៧៧នាក់)
- បានផ្តល់បណ្ណ/សៀវភៅការងារថ្មី ដល់ហត្ថពលកម្មបរទេសចំនួន ៨៣ ១៧៩នាក់ (ស្រី ១៨ ៨៨៦នាក់) និងបានពន្យារសុពលភាពលើបណ្ណ/សៀវភៅការងារ ដល់ហត្ថពលកម្មបរទេសចំនួន ១៩៤ ៩០១នាក់ (ស្រី ៤៧ ៧៨៨នាក់)
- បានចេញសេចក្តីជូនដំណឹង ស្តីពីការស្នើសុំពន្យាសុពលភាពបណ្ណការងារ និងសៀវភៅការងារជនបរទេស ឆ្នាំ២០២៥, សេចក្តីជូនដំណឹង ស្តីពីការស្នើសុំការអនុញ្ញាតប្រើប្រាស់ហត្ថពលកម្មបរទេស ឆ្នាំ២០២៦ និងសេចក្តីជូនដំណឹង ស្តីពីការស្នើសុំបណ្ណការងារ និងសៀវភៅការងារជនបរទេស ឆ្នាំ២០២៦
- បានរៀបចំសេចក្តីព្រាងសេចក្តីណែនាំ ស្តីពីសុពលភាពនៃការចុះបញ្ជិកាកិច្ចសន្យាការងារជនបរទេស និងសេចក្តីព្រាងប្រកាស ស្តីពីការផ្ទេរជំនាញពីកម្មករនិយោជិតបរទេសជំនាញមកយុវជនខ្មែរក្នុងព្រះរាជាណាចក្រកម្ពុជា។

## ២.៥. ការអភិវឌ្ឍរបបសន្តិសុខសង្គមស្របតាមការវិវត្ត នៃស្ថានភាពសង្គម-សេដ្ឋកិច្ច

### ២.៥.១. ការពង្រឹង និងពង្រីកវិសាលភាពនៃការអនុវត្តរបបសន្តិសុខសង្គម

បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) នៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានពង្រីក និងបង្កើនសមត្ថភាពរបស់ខ្លួនក្នុងការផ្តល់សេវាជូនសមាជិក ដោយក្នុងនោះបានបង្កើនទីតាំងស្នាក់ការកណ្តាល និងសាខាចំនួនសរុប ៣៨ទីតាំង (ផ្សារទំនើបអ៊ីអន១, ២ និង៣)។ ទន្ទឹមនឹងនេះ បានកែសម្រួលប្រតិបត្តិការការងារ និងបម្រើសេវាកម្មផ្ទាល់ជារៀងរាល់ថ្ងៃចាប់ពីថ្ងៃចន្ទ ដល់ថ្ងៃអាទិត្យ ពីម៉ោង ៨:៣០នាទីព្រឹក ដល់ម៉ោង ១៧:៣០នាទីល្ងាច លើកលែងស្នាក់ការកណ្តាល ដែលបម្រើសេវាកម្មផ្ទាល់ចាប់ពីម៉ោង ៧:០០នាទីព្រឹក ដល់ម៉ោង ២២:០០នាទីយប់

និងមានបម្រើសេវាអតិថិជនពេញ ២៤ម៉ោង លើ ៧ថ្ងៃ តាមរយៈបណ្ដាញទូរសព្ទឥតគិតថ្លៃលេខ ១២៩៧ និង ១២៨៦ សម្រាប់ទទួលការហៅចូលដើម្បីសាកសួរព័ត៌មានអំពីរបបសន្តិសុខសង្គម ការឆ្លើយតបនូវសំណួររបស់សាធារណជន រួមទាំងទទួលបណ្ដឹងតវ៉ាផ្សេងៗ។ ជាលទ្ធផលឆ្នាំ២០២៥នេះ ប.ស.ស. នៃក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ សម្រេចបាននូវសមិទ្ធផលជាច្រើន ដូចខាងក្រោម៖

**ក. ផ្នែកហានិភ័យការងារ**

- បានពង្រីកវិសាលភាពចុះបញ្ជិកាក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថានថ្មីចំនួន ៤ ២៧៧សហគ្រាស និងសមាជិកចំនួន ៤០៣ ១៦៧នាក់ (ស្រី ១៨៤ ៩៤៥នាក់)។ គិតត្រឹមឆ្នាំ២០២៥ នេះ ក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថានសរុបមានចំនួន ២៩ ៣៣៣សហគ្រាស និងសមាជិកសរុបចំនួន ២ ៤៦៦ ០៥៧នាក់ (ស្រី ១ ៣៩៦ ៤២២នាក់) ក្នុងនោះ សមាជិក ប.ស.ស. ជាបុគ្គលដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ មានចំនួន ២ ១៤៥ ៩៧០នាក់ (ស្រី ១ ២៦៦ ៣៨១នាក់) និងបុគ្គលដែលស្ថិតនៅក្នុងវិស័យសាធារណៈមានចំនួន ៣២០ ០៨៧នាក់ (ស្រី ១៣០ ០៤១នាក់)។

**តារាង ២.៥.១៖ ក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថាន និងសមាជិកចុះបញ្ជិកាថ្មី ផ្នែកហានិភ័យការងារ**

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ១ | បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ | ស្ថាប័ន | 5 | 1 | -80.00% |
| | | សមាជិក | 57,396 | 6,272 | -89.07% |
| | | ស្រី | 17,578 | 2,892 | -83.55% |
| ២ | បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្ដីពីការងារ | សហគ្រាស | 6,700 | 4,276 | -36.18% |
| | | សមាជិក | 282,413 | 396,895 | 40.54% |
| | | ស្រី | 132,017 | 182,053 | 37.90% |
| សរុប | | **ស.គ** | **6,705** | **4,277** | **-36.21%** |
| | | **សមាជិក** | **339,809** | **403,167** | **18.65%** |
| | | **ស្រី** | **149,595** | **184,945** | **23.63%** |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

**រូបភាព ២.៥.១៖ ក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថាន និងសមាជិក ផ្នែកហានិភ័យការងារ**




*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

**រូបភាព ២.៥.២៖ ក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថាន និងសមាជិក ផ្នែកហានិភ័យការងារ តាមវិស័យ**




*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

## ខ. ផ្នែកថែទាំសុខភាព

- បានពង្រីកវិសាលភាពចុះបញ្ជិកាក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថានថ្មីសរុបចំនួន ៤ ២៧៨ និងសមាជិកសរុបចំនួន ៧៣៦ ៧៥៩នាក់ (ស្រី ៣៧៩ ៨៣៣នាក់) ក្នុងនោះ សមាជិកតាមរបបភាគទានជាកាតព្វកិច្ចមានចំនួន ៤១១ ០៦៩នាក់ (ស្រី ១៨៦ ០៥៩នាក់) និងសមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្តចំនួន ៣២៥ ៦៩០នាក់ (ស្រី ១៩៣ ៧៧៤នាក់)។ គិតត្រឹមឆ្នាំ២០២៥ នេះ មានក្រសួង ស្ថាប័ន សហគ្រាស គ្រឹះស្ថានសរុបចំនួន ២៩ ៣៣៨ និងសមាជិក ប.ស.ស. ចំនួន ៣ ៥៣៦ ៥០៩នាក់ (ស្រី ១ ៩៤២ ១២០នាក់) ក្នុងនោះ សមាជិកតាមរបបភាគទានជាកាតព្វកិច្ចមានចំនួន ២ ៦៧៦ ៧៨៣នាក់ (ស្រី ១ ៤២៦ ៦០៧នាក់) និងសមាជិកតាមរបបភាគទានដោយស្ម័គ្រចិត្តមានចំនួន ៨៥៩ ៧២៦នាក់ (ស្រី ៥១៥ ៥១៣នាក់)។

### តារាង ២.៥.២៖ ការចុះបញ្ជិកាសមាជិកថ្មីផ្នែកថែទាំសុខភាព

| ល.រ | បរិយាយ | ២០២៤ | | | ២០២៥ | | | បម្រែបម្រួល |
|---|---|---|---|---|---|---|---|---|
| | | ស.គ* | សមាជិក | ស្រី | ស.គ | សមាជិក | ស្រី | (%)** |
| **សមាជិកសរុប (១+២)** | | **6,705** | **880,236** | **470,021** | **4,278** | **736,759** | **379,833** | **-16.30%** |
| **១** | **តាមរបបភាគទានជាកាតព្វកិច្ច** | **6,705** | **347,767** | **150,979** | **4,278** | **411,069** | **186,059** | **18.20%** |
| ១.១ | បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈ | 5 | 65,354 | 18,962 | 2 | 14,174 | 4,006 | -78.31% |
| ១.២ | បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារ | 6,700 | 282,413 | 132,017 | 4,276 | 396,895 | 182,053 | 40.54% |
| **២** | **តាមរបបភាគទានដោយស្ម័គ្រចិត្ត** | - | **532,469** | **319,042** | - | **325,690** | **193,774** | **-38.83%** |
| ២.១ | បុគ្គលស្វ័យនិយោជន៍ | - | 389,855 | 237,160 | - | 204,979 | 124,957 | -47.42% |
| ២.២ | អ្នកក្នុងបន្ទុកសមាជិក ប.ស.ស. | - | 142,614 | 81,882 | - | 120,711 | 68,817 | -15.36% |
| ២.២.១ | សហព័ទ្ធ (ប្តី ឬប្រពន្ធ) | - | 38,401 | 31,169 | - | 34,363 | 26,739 | -10.52% |
| ២.២.២ | កូនក្នុងបន្ទុក | - | 104,213 | 50,713 | - | 86,348 | 42,078 | -17.14% |

*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

*សម្គាល់ ៖ * ស.គ (ក្រសួង ស្ថាប័ន សហគ្រាស ឬគ្រឹះស្ថាន), ** ជាការគណនាបម្រែបម្រួលសមាជិក ប.ស.ស.។*

### រូបភាព ២.៥.៣៖ សមាជិក ប.ស.ស. ផ្នែកថែទាំសុខភាព




*ប្រភព ៖ បេឡាជាតិសន្តិសុខសង្គម*

### រូបភាព ២.៥.៤៖ សមាជិក ប.ស.ស. ផ្នែកថែទាំសុខភាព បែងចែកតាមរបបភាគទាន




*ប្រភព ៖ បេឡាជាតិសន្តិសុខសង្គម*

## គ. ផ្នែកប្រាក់សោធន

- បានពង្រីកវិសាលភាពចុះបញ្ជិកាសមាជិកថ្មីតាមរបបភាគទានជាកាតព្វកិច្ចចំនួន ៤ ២៧៦សហគ្រាស មានសមាជិកចំនួន ៣៩៦ ៨៩៥នាក់ (ស្រី ១៨២ ០៥៣នាក់) និងសមាជិកថ្មីតាមរបបភាគទានដោយស្ម័គ្រចិត្ត មានចំនួន ១ ៩៣៩នាក់ (ស្រី ៩៩៩នាក់)។ គិតត្រឹមឆ្នាំ២០២៥ នេះ តាមរបបភាគទានជាកាតព្វកិច្ចមានចំនួន ២៩ ០៦៣សហគ្រាស មានសមាជិកចំនួន ២ ៦២០ ១៥៤នាក់ (ស្រី ១ ៥៤២ ២៧៤នាក់) និងតាមរបបភាគទាន ដោយស្ម័គ្រចិត្ត មានសមាជិកចំនួន ១ ៩៩៩នាក់ (ស្រី ១ ០៥១នាក់)។

រូបភាព ២.៥.៥៖
សមាជិក ផ្នែកប្រាក់សោធន តាមរបបភាគទានជាកាតព្វកិច្ច




ប្រភព៖ បេឡាជាតិសន្តិសុខសង្គម

រូបភាព ២.៥.៦៖
សមាជិក ផ្នែកប្រាក់សោធន តាមរបបភាគទានដោយស្ម័គ្រចិត្ត




ប្រភព៖ បេឡាជាតិសន្តិសុខសង្គម

## ឃ. ការចូលរួមអនុវត្តកម្មវិធីថែទាំសុខភាពតាមប្រព័ន្ធមូលនិធិសមធម៌សុខាភិបាល សម្រាប់កម្មករនិយោជិតក្រៅប្រព័ន្ធ

- បានបោះពុម្ពបណ្ណមូលនិធិសមធម៌សុខាភិបាលសម្រាប់ក្រុមគោលដៅ រួមមាន កម្មករនិយោជិតក្រៅប្រព័ន្ធ, សិល្បករ, សិល្បការិនី, កីឡាករ, កីឡាការិនី, សមាគម, កម្មករស៊ីក្លូ, អ្នករត់ម៉ូតូឌុប និងម៉ូតូកង់បី និងបុគ្គលបម្រើការ ក្នុងសេវាកម្សាន្តទេសចរណ៍នៃសេដ្ឋកិច្ចក្រៅប្រព័ន្ធចំនួន ១៣៨ ៦១១នាក់ (ស្រី ៧៧ ៤៨២នាក់)។

តារាង ២.៥.៣៖ ការចេញបណ្ណមូលនិធិសមធម៌សុខាភិបាល

| បរិយាយ | បច្ចុប្បន្នភាពបញ្ជិកាសហគ្រាស គ្រឹះស្ថាន និងសមាជិក | | | | | | | | |
|---|---|---|---|---|---|---|---|---|---|
| | សរុប | | | ថ្នាក់កណ្ដាល | | | ថ្នាក់ខេត្ត | | |
| | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី | សហគ្រាស | សមាជិក | ស្រី |
| គិតត្រឹមឆ្នាំ២០២៤ | **37** | **135,002** | **74,509** | 28 | 81,199 | 58,922 | 9 | 53,803 | 15,587 |
| គិតត្រឹមឆ្នាំ២០២៥ | **40** | **138,611** | **77,482** | 28 | 85,852 | 62,389 | 12 | 52,759 | 15,093 |
| បម្រែបម្រួល(%) | **8.11%** | **2.67%** | **3.99%** | 0.00% | 5.73% | 5.88% | 33.33% | -1.94% | -3.17% |

ប្រភព៖ បេឡាជាតិសន្តិសុខសង្គម

## ២.៥.២. ការពង្រឹង និងបង្កើនគុណភាពនិងសមត្ថភាពផ្តល់សេវាសន្តិសុខសង្គម

- បានចុះកិច្ចព្រមព្រៀងជាមួយមូលដ្ឋានសុខាភិបាលជាដៃគូរបស់ ប.ស.ស. ទូទាំងរាជធានី ខេត្ត សរុបចំនួន ៣៣មូលដ្ឋាន ដែលនាំឱ្យមូលដ្ឋានសុខាភិបាលជាដៃគូរបស់ ប.ស.ស. ទូទាំងរាជធានី ខេត្ត សរុបចំនួន ១ ៦១៧ ក្នុងនោះ មូលដ្ឋានសុខាភិបាលសាធារណៈចំនួន ១ ៤៤២ និងមូលដ្ឋានសុខាភិបាលឯកជនចំនួន ១៧៥

- បានផ្តល់តាវកាលិកផ្នែកហានិភ័យការងារដល់បុគ្គលទាំងឡាយ ដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារចំនួន ១១ ០០៥នាក់ (ស្រី ៥ ១៩៦នាក់) និងចំណាយតាវកាលិកប្រមាណ ៣១ ១៩៦លានរៀល ព្រមទាំងបានផ្តល់សេវាស្តារនីតិសម្បទាផ្នែកហានិភ័យការងារចំនួន ១៧៣ករណី (ស្រី ៦៦ករណី)

- បានទទួលរបាយការណ៍ហានិភ័យការងារពីសហគ្រាស គ្រឹះស្ថាននៅតាមបណ្តារាជធានី ខេត្ត សរុបចំនួន ១៨ ៥១៩នាក់ (ស្រី ៩ ៥៨០នាក់) ដែលតាមលទ្ធផលអង្កេតហានិភ័យការងារឃើញថា មានកម្មករនិយោជិតចំនួន ១៨ ៤៨៦នាក់ (ស្រី ៩ ៥៨៦នាក់) ជាគ្រោះថ្នាក់ការងារ និងមានកម្មករនិយោជិតចំនួន ៧៣៥នាក់ (ស្រី ២៩២នាក់) មិនមែនជាហានិភ័យការងារ

- បានផ្តល់សេវាតាវកាលិកហានិភ័យការងារដល់បុគ្គល ដែលស្ថិតក្នុងវិស័យសាធារណៈចំនួន ១៤៩នាក់ (ស្រី ៤៩នាក់) និងបានចំណាយតាវកាលិកប្រមាណ ៩០០លានរៀល ព្រមទាំងបានផ្តល់សេវាស្តារនីតិសម្បទាផ្នែកហានិភ័យការងារចំនួន ៩ករណី (ស្រី ៥ករណី)

- សមាជិក ប.ស.ស. ជាបុគ្គលទាំងឡាយដែលស្ថិតក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារបានប្រើប្រាស់សេវាផ្នែកថែទាំសុខភាពតាមមូលដ្ឋានសុខាភិបាលចំនួន ៤ ៩៩៤ ៥៤៦ដង (ស្រី ៣ ៨១៥ ៤៤៦ដង) និងបានចំណាយតាវកាលិកប្រមាណ ៤៦៨ ៧៦០លានរៀល ព្រមទាំងផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រចំនួន ៥២ករណី (ស្រី ២៥ករណី)

- សមាជិក ប.ស.ស. ជាបុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈបានទៅប្រើប្រាស់សេវាផ្នែកថែទាំសុខភាពតាមមូលដ្ឋានសុខាភិបាលចំនួន ១ ០៥៥ ០៤៤ដង (ស្រី ៤០៣ ៧៧៨ដង) និងបានចំណាយតាវកាលិកប្រមាណ ១២៥ ០៥៣លានរៀល ព្រមទាំងបានផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រចំនួន ៨៤ករណី (ស្រី ៥ករណី)

- សមាជិក ប.ស.ស. តាមរបបភាគទានដោយស្ម័គ្រចិត្ត បានទៅប្រើប្រាស់សេវាផ្នែកថែទាំសុខភាពតាមមូលដ្ឋានសុខាភិបាលចំនួន ២ ០៥៣ ៩៩៥ដង (ស្រី ១ ៣៦៣ ៦៧៣ដង) និងចំណាយតាវកាលិកអស់ប្រមាណ ២០៧ ៣០៩លានរៀល ព្រមទាំងបានផ្តល់សេវាស្តារនីតិសម្បទាផ្នែកវេជ្ជសាស្ត្រចំនួន ២៧ករណី (ស្រី ១៤ករណី)

- បានផ្តល់តាវកាលិកផ្នែកប្រាក់សោធនចំនួន ៤ ៤៤០នាក់ (ស្រី ១ ៩២៥នាក់) និងបានចំណាយតាវកាលិកប្រមាណ ៧២៦,១០លានរៀល។ គិតត្រឹមឆ្នាំ២០២៥ បានបើកផ្តល់តាវកាលិករបបសន្តិសុខសង្គមផ្នែកប្រាក់សោធនដល់សមាជិកសរុបចំនួន ៧ ៥៩៦នាក់ (ស្រី ៣ ១១៩នាក់) និងចំណាយតាវកាលិកស្មើនឹងថវិកាសរុបប្រមាណ ១៦,៧៩ប៊ីលានរៀល

- បានចំណាយទូទាត់តាវកាលិកសរុប ៨៥០ ០០៧លានរៀល ដោយក្នុងនោះ៖ ផ្នែកហានិភ័យការងារប្រមាណ ៣២ ០៩៥លានរៀល, ផ្នែកថែទាំសុខភាពប្រមាណ ៨០១ ១២២លានរៀល និងផ្នែកប្រាក់សោធនប្រមាណ ១៦ ៧៩០លានរៀល

- រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ចំនួន ១២២ ៨៦២នាក់ ជាស្ត្រីមានផ្ទៃពោះ និងចំនួន ១៧០ ០៦៣នាក់ ជាកុមារអាយុក្រោម ២ឆ្នាំ ព្រមទាំងបានចំណាយថវិកាប្រមាណ ១១៣ ៣៩៧លានរៀល។ បើគិតត្រឹមឆ្នាំ២០២៥ នេះ រាជរដ្ឋាភិបាលបានឧបត្ថម្ភសាច់ប្រាក់ដល់សមាជិក ប.ស.ស. ចំនួន ៦៩៦ ៧៥១នាក់ ជាស្ត្រីមានផ្ទៃពោះ និងចំនួន ៧៣២ ១២៣នាក់ ជាកុមារអាយុក្រោម ២ឆ្នាំ ព្រមទាំងបានចំណាយថវិកាសរុបប្រមាណ ៤០៩ ៩៦៤លានរៀល។

## តារាង ២.៥.៤៖ បច្ចុប្បន្នភាពមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស.

| បរិយាយ | មូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងថ្មីជាមួយ ប.ស.ស. | | | | | |
|---|---|---|---|---|---|---|
| | សរុបរួម | មន្ទីរពេទ្យសាធារណៈ | | | | មន្ទីរពេទ្យឯកជន |
| | | សរុប | ថ្នាក់ជាតិ | មន្ទីរពេទ្យបង្អែក | មណ្ឌលសុខភាព | |
| ២០២៤ | **66** | 36 | 4 | 2 | 30 | 30 |
| ២០២៥ | **33** | 11 | 0 | 0 | 11 | 22 |
| បម្រែបម្រួល (%) | **-50.00%** | -69.44% | -100.00% | -100.00% | -63.33% | -26.67% |
| បច្ចុប្បន្នភាពមូលដ្ឋានសុខាភិបាលចុះកិច្ចព្រមព្រៀងជាមួយ ប.ស.ស. | | | | | | |
| គិតត្រឹមឆ្នាំ២០២៤ | **1,595** | 1,431 | 14 | 126 | 1,291 | 164 |
| គិតត្រឹមឆ្នាំ២០២៥ | **1,617** | 1,442 | 14 | 126 | 1,302 | 175 |
| បម្រែបម្រួល (%) | **1.38%** | 0.77% | 0.00% | 0.00% | 0.85% | 6.71% |

*ប្រភព ៖ បេឡាជាតិសន្តិសុខសង្គម*

## រូបភាព ២.៥.៧៖ សមាជិកប្រើប្រាស់សេវា និងការចំណាយតាវកាលិក ផ្នែកថែទាំសុខភាព




*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

## រូបភាព ២.៥.៨៖ ការបើកប្រាក់ឧបត្ថម្ភដល់ស្ត្រីមានផ្ទៃពោះ និងកូនអាយុក្រោម ២ឆ្នាំ




*ប្រភព៖ បេឡាជាតិសន្តិសុខសង្គម*

### ២.៥.៣. ការលើកកម្ពស់ការយល់ដឹង និងពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គម

- បានផ្សព្វផ្សាយការអនុវត្តរបបសន្តិសុខសង្គមសរុប ៣ ០៩៣លើក មានអ្នកចូលរួមចំនួន ៤៤៨ ៥៤០នាក់ (ស្រី ៣២៨ ៨៨៤នាក់)

- បានផ្សព្វផ្សាយគោលនយោបាយអភិវឌ្ឍន៍វិស័យការងារសរុប ៦៦លើក ស្មើនឹង ៦៦សហគ្រាស បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ២៣សហគ្រាស ស្មើនឹង ៥៣,៤៩% ដែលមានអ្នកចូលរួមចំនួន ៤ ២៥០នាក់ បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ១ ០៧៤នាក់ ស្មើនឹង ៣៣,៨២%

- បានផ្សព្វផ្សាយអំពីលក្ខខណ្ឌអនាម័យ សុវត្ថិភាពការងារ លក្ខខណ្ឌការងារ និងអត្ថប្រយោជន៍របបសន្តិសុខសង្គមសរុប ២២៥លើក ស្មើនឹង ២២៥សហគ្រាស បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ១៦០សហគ្រាស ស្មើនឹង ២៤៦,១៥% ដែលមានអ្នកចូលរួមចំនួន ៥៣ ៤៦៣នាក់ បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ៤៦ ៩២៤នាក់ ស្មើនឹង ៧១៧,៦០%

- បានផ្សព្វផ្សាយអប់រំច្បាប់ស្តីពីចរាចរណ៍ផ្លូវគោកសរុប ៤០៧លើក ស្មើនឹង ៤០៧សហគ្រាស បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ១៤៨សហគ្រាស ស្មើនឹង ៥៧,១៤% មានអ្នកចូលរួមចំនួន ១១៤ ៨០០នាក់ បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ៧៣ ៨១៩នាក់ ស្មើនឹង ១៨០,១៣%

- បានផ្សព្វផ្សាយតាមបណ្តាញសង្គម និងសារព័ត៌មានសរុបចំនួន ២ ០៧០លើក បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ៤៣២លើក ស្មើនឹង ២៦,៣៧% ក្នុងនោះ ផ្សព្វផ្សាយតាមបណ្តាញសង្គម ១ ៤២១លើក បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ៤៨៨លើក ស្មើនឹង ៥២,៣០% និងសារព័ត៌មាន ៦៤៩លើក បើធៀបជាមួយឆ្នាំ២០២៤ មានការថយចុះ ៥៦លើក ស្មើនឹង ៧,៩៤%

- បានផលិតខិត្តប័ណ្ណ ផ្ទាំងរូបភាព បទយកការណ៍ និងការផលិតវីដេអូផ្សព្វផ្សាយរបស់ ប.ស.ស. ចំនួន ៦៤៥ខិត្តប័ណ្ណ/វីដេអូ បើធៀបជាមួយឆ្នាំ២០២៤ មានការកើនឡើង ១២៧ខិត្តប័ណ្ណ/វីដេអូ ស្មើនឹង ២៤,៥២%

- បានទទួលពាក្យបណ្តឹងចំនួន ១ ០៧០ពាក្យបណ្តឹង និងដោះស្រាយចំនួន ៩៦៧ពាក្យបណ្តឹង។

### ២.៥.៤. ការពង្រឹងការគ្រប់គ្រង និងចាត់ចែងមូលនិធិសន្តិសុខសង្គម

- ផ្នែកហានិភ័យការងារប្រមូលភាគទានសរុបប្រមាណ ១៩៣ ៣៨២លានរៀល ក្នុងនោះ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប្រមាណ ១៨៦ ៨៨៤លានរៀល និងបុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈប្រមាណ ៦ ៤៩៨លានរៀល

- ផ្នែកថែទាំសុខភាពប្រមូលភាគទានសរុបប្រមាណ ៨២៦ ៩៨២លានរៀល ក្នុងនោះ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារប្រមាណ ៦០៣ ៥០៤លានរៀល, បុគ្គលដែលស្ថិតក្នុងវិស័យសាធារណៈប្រមាណ ៧៦ ០២៤លានរៀល និងបុគ្គលស្វ័យនិយោជន៍ និងអ្នកក្នុងបន្ទុកនៃសមាជិក ប.ស.ស. ប្រមាណ ១៤៧ ៤៥៤លានរៀល

- ផ្នែកប្រាក់សោធនប្រមូលភាគទានសរុបប្រមាណ ៩២៣ ៣៩៦លានរៀល ក្នុងនោះ បុគ្គលទាំងឡាយដែលស្ថិតនៅក្រោមបទប្បញ្ញត្តិនៃច្បាប់ស្តីពីការងារបង់ភាគទានជាកាតព្វកិច្ចប្រមាណ ៩២២ ១៨៩លានរៀល និងភាគទានដោយស្ម័គ្រចិត្តប្រមាណ ១ ២០៧លានរៀល។

### ២.៥.៥. ការអភិវឌ្ឍសមត្ថភាពបេឡាជាតិសន្តិសុខសង្គម

- បានចូលរួមវគ្គបណ្តុះបណ្តាល សិក្ខាសាលា និងទស្សនកិច្ចសិក្សា ដើម្បីពង្រឹងសមត្ថភាពដល់មន្ត្រី និងបុគ្គលិក ទាំងក្នុង និងក្រៅប្រទេសបានចំនួន ១៧១វគ្គ មានមន្ត្រីចូលរួមចំនួន ២ ៥៦៧នាក់ (ស្រី ១ ០១០នាក់)

- បានបន្តកិច្ចសហប្រតិបត្តិការជាមួយដៃគូជាតិ និងអន្តរជាតិលើគម្រោងអភិវឌ្ឍន៍របបសន្តិសុខសង្គម រួមមាន ១) កិច្ចសហប្រតិបត្តិការជាមួយអង្គការហ្គ្រេត (GRET), ២) កិច្ចសហការជាមួយកិច្ចសហប្រតិបត្តិការអាល្លឺម៉ង់ (GIZ), ៣) កិច្ចសហប្រតិបត្តិការជាមួយអង្គការអន្តរជាតិខាងការងារ (ILO), ៤) កិច្ចសហប្រតិបត្តិការជាមួយអង្គការសុខុមាលភាព និងសំណងគ្រោះថ្នាក់ការងារ (COMWEL) និង៥) កិច្ចសហប្រតិបត្តិការជាមួយទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិនៃប្រទេសជប៉ុន (JICA) និងក្រុមហ៊ុន HITACHI។

## ២.៦. ការធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅ

### ២.៦.១. ពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក

ក្រសួង បានពង្រឹងការគ្រប់គ្រងរដ្ឋបាល និងបុគ្គលិក ស្របតាមកម្មវិធីជាតិកែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីកសាងធនធានមនុស្សប្រកបដោយគុណាធិបតេយ្យ និងមានភាពជន់ក្នុងការបម្រើសេវាសាធារណៈ។ បន្ថែមលើនេះ ក្នុងស្មារតីបុរេសកម្ម សំដៅកែលម្អរបៀបរបបការងារ ពង្រឹងក្រមសីលធម៌វិជ្ជាជីវៈ ព្រមទាំងគាំទ្រដល់ការធ្វើបរិវត្តកម្មឌីជីថលលើប្រព័ន្ធអភិបាលកិច្ច ក្រសួង៖

- បានលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងមន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យា តាមរយៈដាក់ឱ្យដំណើរការប្រព័ន្ធគ្រប់គ្រងវត្តមានមន្ត្រីរាជការតាមរយៈការស្កេនមុខ (Face Recognition) និងបានអនុវត្តកាតព្វកិច្ចគោរពទង់ជាតិជារៀងរាល់សប្តាហ៍ (ព្រឹកថ្ងៃចន្ទ និងល្ងាចថ្ងៃសុក្រ)

- បានកែសម្រួលកម្រងសេវាសាធារណៈរបស់ក្រសួងតាមរយៈប្រកាសអន្តរក្រសួងលេខ១៩៣ សហវ.ប្រក.អទប ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០២៥ ស្តីពីការផ្តល់សេវាសាធារណៈរបស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ផ្អែកតាមសំណូមពររបស់វិស័យឯកជននៅក្នុងកិច្ចប្រជុំនៃក្រុមការងារផ្នែកទំនាក់ទំនងវិជ្ជាជីវៈ ដោយបានកែសម្រួល និងលុបចោលសេវាសាធារណៈមួយចំនួនដែលមានលក្ខណៈមិនសមស្របនឹងស្ថានភាពជាក់ស្តែង នៃការវិវត្តនៃបច្ចេកវិទ្យា និងវិស័យធនាគារ និងហិរញ្ញវត្ថុ

- បានវិភាគមុខងារ និងរចនាសម្ព័ន្ធឡើងវិញ ស្របតាមវិធានការគន្លឹះក្នុងការជំរុញកំណែទម្រង់រដ្ឋបាលសាធារណៈរបស់រាជរដ្ឋាភិបាល និងបានជំរុញបរិវត្តកម្មឌីជីថល ដើម្បីធ្វើទំនើបកម្មស្ថាប័ន និងការផ្តល់សេវាសាធារណៈ និងសេវាគាំទ្រទូទៅតាមរយៈការដាក់ឱ្យអនុវត្តនូវប្រព័ន្ធគ្រប់គ្រងឯកសាររដ្ឋបាល Document Management System (DMS) នៅថ្នាក់កណ្តាលចំនួន ៤១អង្គភាព ការដាក់ឱ្យអនុវត្តសាធារណៈតាមថ្នាលបច្ចេកវិទ្យាឌីជីថល ការដាក់ឱ្យដំណើរការបញ្ជរសេវាសាធារណៈចល័ត (Mobile Public Service Counter) និងកិច្ចសហការជាមួយក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ ក្នុងការបញ្ជូនសារខ្លីពាក់ព័ន្ធ (Push Message) (១). កម្មវិធីអប់រំបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេស, (២). បេឡាជាតិសន្តិសុខសង្គម, (៣). ឱកាសការងារ, (៤). ការហាមឃាត់ការប្រើប្រាស់ពលកម្មកុមារ និង (៥). ទេសន្តរប្រវេសន៍ការងារទៅលេខទូរសព្ទ

- បានដាក់ឱ្យដំណើរការបញ្ជរសេវាសាធារណៈចល័ត (Mobile Public Service Counter) ឬកម្មវិធីក្នុងទូរសព្ទដៃដែលមានឈ្មោះ "MLVT Services" នៅដើមឆ្នាំ២០២៥ ដើម្បីបង្កើនភាពងាយស្រួលសម្រាប់ប្រជាពលរដ្ឋខ្មែរដែលមានបំណងចង់ដាក់ពាក្យទៅធ្វើការនៅបរទេស ដែលមាននៅតាមទីតាំងមួយចំនួន ដូចជា ទីស្តីការក្រសួង សាលារៀន TVET បណ្តាសាកលវិទ្យាល័យមួយចំនួន ផ្សារទំនើប ហាងកាហ្វេ និងទីតាំងមួយចំនួនទៀត និងព្រមទាំងបានផលិតវីដេអូអំពីនីតិវិធីដាក់ពាក្យទៅធ្វើការនៅប្រទេសថៃ តាមរយៈបញ្ជរសេវាសាធារណៈចល័តចំនួន ១៣វីដេអូ

- បានទទួលលិខិតចូល និងលិខិតចេញសរុបចំនួន ១៧ ៩៧០លេខ ក្នុងនោះ លិខិតចូលចំនួន ៨ ៦២៧លេខ និងលិខិតចេញចំនួន ៩ ៣៤៣លេខ

- បានធ្វើបច្ចុប្បន្នភាពមន្ត្រីរាជការកំពុងបម្រើការងារនៅក្រោមឱវាទក្រសួងគិតត្រឹមឆ្នាំ២០២៥ នេះ មានមន្ត្រីរាជការសរុបចំនួន ៤ ៤៦៤នាក់ (ស្រី ១ ២៣៩នាក់) ក្នុងនោះ ថ្នាក់កណ្តាលចំនួន ៣ ៧២៨នាក់ (ស្រី ១ ០២១នាក់) និងថ្នាក់រាជធានី ខេត្តចំនួន ៧៣៦នាក់ (ស្រី ២១៨នាក់)

- បានបើកផ្តល់ប្រាក់បៀវត្សជូនមន្ត្រីរាជការបានទៀងទាត់ និងទាន់ពេលវេលា និងបានរៀបចំការផ្លាស់ប្តូរស្ថានភាពរដ្ឋបាល និងស្ថានភាពគ្រួសាររបស់មន្ត្រីរាជការស៊ីវិលចំនួន ២ ៤២៦ករណី

- មានសេចក្តីណែនាំស្តីពីការតាក់តែងលិខិតបទដ្ឋានគតិយុត្ត និងលិខិតរដ្ឋបាលសម្រាប់ប្រើប្រាស់ផ្ទៃក្នុងក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងឯកសារណែនាំស្តីពីនិតិវិធីគ្រប់គ្រងមន្ត្រី

- បានកែសម្រួលភារកិច្ចមន្ត្រីរាជការសរុបចំនួន ១៩នាក់ (ស្រី ៦នាក់), បានបញ្ចប់មុខដំណែងមន្ត្រីរាជការចំនួន ៦នាក់, បានផ្លាស់ប្តូរកន្លែងធ្វើការមន្ត្រីរាជការចំនួន ៤៨នាក់ (ស្រី ១៥នាក់), បានលុបឈ្មោះដោយស្ម័គ្រចិត្តចំនួន ៣៣នាក់ (ស្រី ៩នាក់), បានលុបឈ្មោះដោយបោះបង់ចំនួន ៦នាក់, បានដាក់ឱ្យស្ថិតក្នុងភាពទំនេរគ្មានបៀវត្សចំនួន ៤៦នាក់ (ស្រី ១៦នាក់), បានដាក់ទណ្ឌកម្មមន្ត្រីរាជការចំនួន ៥នាក់ និងបានដាក់ទណ្ឌកម្មមន្ត្រីជាប់កិច្ចសន្យាចំនួន ១នាក់។

**រូបភាព ២.៦.១៖**
**បច្ចុប្បន្នភាពស្ថិតិមន្ត្រីរាជការក្រោមឱវាទក្រសួង**




*ប្រភព៖ នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក*

**រូបភាព ២.៦.២៖**
**បច្ចុប្បន្នភាពស្ថិតិមន្ត្រីរាជការក្រោមឱវាទក្រសួង តាមក្របខណ្ឌ**




*ប្រភព៖ នាយកដ្ឋានរដ្ឋបាល និងបុគ្គលិក*

## ២.៦.២. ពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព

ដើម្បីឆ្លើយតបទៅនឹងគោលដៅក្នុងការពង្រឹងការគ្រប់គ្រងហិរញ្ញវត្ថុ និងធនធានឱ្យកាន់តែមានប្រសិទ្ធភាព ស័ក្តិសិទ្ធិភាព និងគណនេយ្យភាព ក្រសួងបានដាក់ចេញ និងអនុវត្តនូវវិធានការគន្លឹះជាបន្តបន្ទាប់ ដោយសម្រេចបានលទ្ធផលគួរជាទីមោទនៈ ទាំងលើការអនុវត្តថវិកា ការគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ និងការអភិវឌ្ឍធនធានមនុស្សក្នុងវិស័យហិរញ្ញវត្ថុសាធារណៈ ដែលមានដូចខាងក្រោម៖

- បានដាក់ឱ្យអនុវត្តអង្គភាពថវិកាអាណាប័កផ្ទេរសិទ្ធពេញលេញបន្ថែមចំនួន ២អង្គភាព សម្រាប់អនុវត្តចាប់ពីខែមករា ឆ្នាំ២០២៦ ក្នុងនោះ អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ និងអគ្គនាយកដ្ឋានការងារ

- បានបណ្តុះបណ្តាល ការប្រើប្រាស់ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មានគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋជំនាន់ថ្មី (SARMIS-V2) ឱ្យកាន់តែមានប្រសិទ្ធភាពជាងមុនជូនដល់អង្គភាពប្រើប្រាស់ចំនួន ៦៨ អង្គភាពប្រើប្រាស់

- មានសៀវភៅបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋឆ្នាំគោល របស់អង្គភាពប្រើប្រាស់ចំនួន ៦៨អង្គភាពប្រើប្រាស់

- បានបញ្ជូនមន្ត្រីជំនាញហិរញ្ញវត្ថុសាធារណៈ ដើម្បីចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង នៅវិទ្យាស្ថានសេដ្ឋកិច្ច និងហិរញ្ញវត្ថុចំនួន ១៣នាក់

- បានបើកវគ្គបណ្តុះបណ្តាលមន្ត្រីទទួលបន្ទុកហិរញ្ញវត្ថុដល់អង្គភាពក្រោមឱវាទ ទទួលបានចំណេះដឹងបន្ថែមតាមរយៈសិក្ខាសាលាស្តីពីរបាយការណ៍បូកសរុបលទ្ធផលការអនុវត្តថវិកាឆ្នាំ២០២៥ និងរៀបចំផែនការតាមដានសមិទ្ធកម្មឆ្នាំ២០២៦ របស់កម្មវិធីទាំង ៥

- មានផែនការយុទ្ធសាស្ត្រថវិកាឆ្នាំ២០២៦-២០២៨ ផែនការថវិកាប្រចាំឆ្នាំ២០២៦ និងផែនការសមិទ្ធកម្មនៃការអនុវត្តថវិកាឆ្នាំ២០២៦

- បានដាក់ចេញប្រកាសអន្តរក្រសួងស្តីពីការផ្តល់សេវាសាធារណៈ និងការបែងចែកចំណូលពីសេវាសាធារណៈ និងបានសហការក្នុងការប្រមូលចំណូលមិនមែនសារពើពន្ធពីសេវាសាធារណៈគិតជាភាគរយចំនួន ១៣៣,២៤% និងបានអនុវត្តទូទាត់ចំណាយថ្នាក់កណ្តាលគិតជាភាគរយចំនួន ៩៩,៥៦%។

**រូបភាព ២.៦.៣៖ គ្រប់គ្រងចំណូល និងចំណាយ (គិតជាលានរៀល)**




ប្រភព៖ នាយកដ្ឋានហិរញ្ញវត្ថុ និងទ្រព្យសម្បត្តិរដ្ឋ

### ២.៦.៣. អភិវឌ្ឍសមត្ថភាពមន្ត្រី គ្រប់គ្រងចំណេះដឹង គ្រប់គ្រងស្ថិតិ និងកសាងលិខិតបទដ្ឋានគតិយុត្ត

ក្រសួងបាន និងកំពុងអនុវត្តយ៉ាងហ្មត់ចត់ នូវយន្តការបណ្តុះបណ្តាលទាំងក្នុង និងក្រៅប្រទេស ព្រមទាំងការបញ្ជូនមន្ត្រីសិក្សានៅសាលាភូមិន្ទរដ្ឋបាល និងវគ្គជំនាញនៅវិទ្យាស្ថានជាតិការងារជាដើម។ ក្រៅពីនេះ ការងារប្រមូល និងគ្រប់គ្រងទិន្នន័យ ស្ថិតិ ការរៀបចំរបាយការណ៍វឌ្ឍនភាពជូនរាជរដ្ឋាភិបាល និងការផ្សព្វផ្សាយច្បាប់ក៏សម្រេចបាននូវផ្លែផ្កាជាវិជ្ជមានគួរកត់សម្គាល់។ លទ្ធផលសម្រេចបានសំខាន់ៗរបស់ ក្រសួងក្នុងការអភិវឌ្ឍសមត្ថភាពមន្ត្រី គ្រប់គ្រងចំណេះដឹង គ្រប់គ្រងស្ថិតិ និងកសាងលិខិតបទដ្ឋានគតិយុត្តមានដូចតទៅ៖

## ក. ការអភិវឌ្ឍសមត្ថភាពមន្ត្រី

- បានបញ្ជូនមន្ត្រីរាជការទៅចូលរួមវគ្គបណ្តុះបណ្តាល ទស្សនកិច្ចសិក្សា ក្នុងប្រទេស និងក្រៅប្រទេស និងបញ្ជូនមន្ត្រីចូលរៀនវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលសរុបចំនួន ៧ ៣៤២នាក់ (ស្រី ១ ៦៨២នាក់) បើធៀបរយៈពេលដូចគ្នាក្នុងឆ្នាំ២០២៤ មានការកើនឡើងចំនួន ១ ៧៦៨នាក់ (ស្រី ៣៥២នាក់) ស្មើនឹង ៣២% ក្នុងនោះ វគ្គបណ្តុះបណ្តាល និងជំនាញរដ្ឋបាល និងបុគ្គលិកទាំងក្នុង និងក្រៅប្រទេសសរុបចំនួន ៧ ២២៧នាក់ (ស្រី ១ ៦៥៦នាក់), បានបញ្ជូនមន្ត្រីចូលរួមទស្សនកិច្ចសិក្សាក្នុង និងក្រៅប្រទេសសរុបចំនួន ១០០នាក់ (ស្រី ២០នាក់) និងបានបញ្ជូនមន្ត្រីចូលរួមវគ្គបណ្តុះបណ្តាលនៅសាលាភូមិន្ទរដ្ឋបាលចំនួន ១៥នាក់ (ស្រី ៦នាក់)។

## ខ. ការគ្រប់គ្រងស្ថិតិ និងឯកសារលិខិតបទដ្ឋានគតិយុត្ត

- បានប្រមូលបូកសរុបរបាយការណ៍លទ្ធផលការងារប្រចាំខែ ត្រីមាស ឆមាស ៩ខែ និងប្រចាំឆ្នាំពីគ្រប់អង្គភាពថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត ព្រមទាំងបានធ្វើការចងក្រង និងផ្សព្វផ្សាយជូនថ្នាក់ដឹកនាំ និងគ្រប់អង្គភាព និងបានបញ្ជូនរបាយការណ៍ទៅស្ថាប័នពាក់ព័ន្ធ

- បានបូកសរុបរបាយការណ៍ Dashboard ប្រចាំសប្តាហ៍ ប្រចាំខែ ត្រីមាស ឆមាស ៩ខែ ប្រចាំឆ្នាំពាក់ព័ន្ធនឹងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ទាំងថ្នាក់កណ្តាល និងថ្នាក់រាជធានី ខេត្ត

- បានផលិតសូចនាករសំខាន់ៗប្រចាំខែពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានចេញផ្សព្វផ្សាយក្នុងគេហទំព័រផ្លូវការក្រសួង

- បានរៀបចំរបាយការណ៍លទ្ធផលការងាររយៈពេល ២ឆ្នាំ នៃដំណើរចាប់ផ្តើមរបស់រាជរដ្ឋាភិបាលក្នុងនីតិកាលទី៧ នៃរដ្ឋសភារបស់ក្រសួង

- បានរៀបចំទិន្នន័យសូចនាករគន្លឹះការប្រៀបធៀបបង្គោលចរពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានរៀបចំរបាយការណ៍សង្ខេបពាក់ព័ន្ធនឹងសមិទ្ធផលវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងវឌ្ឍនភាពនៃការអនុវត្តយុទ្ធសាស្ត្របញ្ចកោណ ដំណាក់កាលទី១ សម្រាប់ឆ្នាំ២០២៥ និងទិសដៅសម្រាប់ឆ្នាំ២០២៦ ផ្ញើជូនទៅខុទ្ទកាល័យ **សម្តេចធិបតីនាយករដ្ឋមន្ត្រី**

- បានចងក្រងកម្រងច្បាប់ពាក់ព័ន្ធវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងបានចេញផ្សាយផ្លូវការក្នុងគេហទំព័រក្រសួង ដើម្បីចែកជូនថ្នាក់ដឹកនាំ សិស្ស និស្សិត និងសាធារណជន។

## គ. វិទ្យាស្ថានជាតិការងារ

- បានរៀបចំវគ្គបណ្តុះបណ្តាលមន្ត្រីរាជការ អធិការការងារ មន្ត្រីផ្សះផ្សាវិវាទការងារ រដ្ឋបាលរោងចក្រ សហជីពមូលដ្ឋានសរុបចំនួន ៤៥វគ្គ មានសិក្ខាកាមសរុបចំនួន ៣ ២៧០នាក់ (ស្រី ១ ១៩៣នាក់) ក្នុងនោះ ៖

- ការបណ្តុះបណ្តាលថ្នាក់ដឹកនាំ និងមន្ត្រីរាជការ ស្តីពីការបង្កើតគោលនយោបាយផ្តែកលើភស្តុតាងសម្រាប់ការងារសមរម្យ និងភាពជាអ្នកដឹកនាំលើកិច្ចការរដ្ឋបាល ការតាក់តែងលិខិតរដ្ឋបាល ពិធីការ ហិរញ្ញវត្ថុ សវនកម្ម និងភាពជាអ្នកដឹកនាំអង្គភាពចំនួន ៣វគ្គ សិក្ខាកាមសរុបចំនួន ១០៧នាក់ (ស្រី ១៩នាក់)

៤៧

- ការបណ្តុះបណ្តាលមន្ត្រីអធិការកិច្ចការងារ អធិការពេទ្យការងារ អធិការសន្តិសុខសង្គម និងមន្ត្រីផ្សះផ្សាវិវាទការងារ ស្តីពីជំនាញ និងបេសកកម្មរបស់នគរបាលយុត្តិធម៌, ការគ្រប់គ្រងហានិភ័យនៅថ្នាក់សហគ្រាស ក្រុមហ៊ុន រោងចក្រ, បច្ចេកទេសអធិការកិច្ចសន្តិសុខសង្គម និងសេវាមូលដ្ឋានសុខាភិបាល, ការបង្ការ និងទប់ស្កាត់ការប្រើប្រាស់ពលកម្មកុមារនៅតាមសហគ្រាស គ្រឹះស្ថានផលិតឥដ្ឋ ក្បឿង, បច្ចេកទេសក្នុងការដោះស្រាយវិវាទការងារចំនួន ២០វគ្គ សិក្ខាកាមសរុបចំនួន ១ ៤៣៤នាក់ (ស្រី ២៩២នាក់)
- ការបណ្តុះបណ្តាលរដ្ឋបាលរោងចក្រ សហជីព និងប្រតិភូបុគ្គលិក ស្តីពីបទប្បញ្ញត្តិច្បាប់ស្តីពីការងារ និងលិខិតបទដ្ឋានគតិយុត្តក្នុងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈចំនួន ២២វគ្គ សិក្ខាកាមសរុបចំនួន ១ ៧២៩នាក់ (ស្រី ៨៨២នាក់)។

**រូបភាព ២.៦.៤៖ ការងារបណ្តុះបណ្តាលអភិវឌ្ឍសមត្ថភាព**




ប្រភព ៖ វិទ្យាស្ថានជាតិការងារ

## ២.៦.៤. ពង្រឹងភាពជាម្ចាស់ក្នុងកិច្ចសហប្រតិបត្តិការអន្តរជាតិ សមភាពយេនឌ័រ និងសេវាសង្គម

ក្រសួងបាន និងកំពុងដើរតួនាទីយ៉ាងសកម្មក្នុងការពង្រឹងកិច្ចសហប្រតិបត្តិការ និងភាពជាដៃគូជាមួយក្រសួង ស្ថាប័ន ដៃគូជាតិ អន្តរជាតិ សំដៅចូលរួមធ្វើឱ្យប្រសើរឡើងនូវវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅកម្ពុជា។ ទន្ទឹមនឹងនេះ ការងារសមភាពយេនឌ័រ និងសុខុមាលភាពសង្គម ក៏ត្រូវបានយកចិត្តទុកដាក់ខ្ពស់ ដោយផ្តោតលើការផ្តល់សិទ្ធិអំណាចដល់ស្ត្រី និងការការពារសុខភាពកម្មករនិយោជិតពីគ្រោះថ្នាក់នៃគ្រឿងញៀន និងជំងឺឆ្លង។ លទ្ធផល ដែលសម្រេចបានជាក់ស្តែងសំខាន់ៗមានដូចខាងក្រោម៖

### ក. ការពង្រឹងកិច្ចសហប្រតិបត្តិការ

ក្នុងបេសកកម្មជំរុញការអភិវឌ្ឍវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងដើម្បីបង្ហាញគោលជំហរកម្ពុជា និងពង្រឹងទំនាក់ទំនងកិច្ចសហប្រតិបត្តិការទាំងក្នុងតំបន់ និងលើឆាកអន្តរជាតិ ក្រសួងសម្រេចបាននូវសមិទ្ធផលដូចខាងក្រោម៖

- បានចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាក្រៅប្រទេសសរុបចំនួន ១៨២លើក មានអ្នកចូលរួមសរុបចំនួន ៥៣៥នាក់ (តំបន់អាស៊ានចំនួន ៧៩លើក អឺរ៉ុបចំនួន ២៥លើក និងតំបន់ផ្សេងៗ ចំនួន ៧៨លើក) ព្រមទាំងបានចូលរួមកិច្ចប្រជុំ និងសិក្ខាសាលាក្នុងប្រទេសផ្សេងៗចំនួន ២៦៣លើក និងបានរៀបចំឯកសារជំនួយស្មារតី របាយការណ៍ និងសុន្ទរកថាជូនថ្នាក់ដឹកនាំចំនួន ១៥៣ឯកសារ

- បានឆ្លើយតបទៅនឹងរបាយការណ៍នានាពីក្រសួង ស្ថាប័ន និងដៃគូជាតិ-អន្តរជាតិចំនួន ២៩៤ករណី និងបានបង់វិភាគទានសមាជិកភាពបានចំនួន ២ដៃគូ ដើម្បីបំពេញកាតព្វកិច្ចក្នុងនាមជារដ្ឋសមាជិកក្នុងក្របខណ្ឌអង្គការអន្តរជាតិខាងការងារ

- បានពិនិត្យសង្គតិភាពអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងៗទៀតចំនួន ៣៤ច្បាប់ និងបានប្រមូលចងក្រងអនុស្សរណៈនៃការយោគយល់គ្នា (MoU) និងកិច្ចព្រមព្រៀងនានាចំនួន ៤៥ច្បាប់ ព្រមទាំងបានប្រមូលចងក្រងរបាយការណ៍វឌ្ឍនភាព អនុស្សរណៈនៃការយោគយល់គ្នា និងឯកសារកិច្ចព្រមព្រៀងផ្សេងៗទៀតចំនួន ៤៨ច្បាប់ ដើម្បីពង្រឹង និងពង្រីកកិច្ចសហប្រតិបត្តិការ រវាងក្រសួងជាមួយដៃគូជាតិ និងអន្តរជាតិ

- បានរៀបចំលិខិតស្នើសុំនានាទៅអង្គភាព ក្រសួង ស្ថាប័ន និងដៃគូជាតិ-អន្តរជាតិចំនួន ២៧៤ករណី ដើម្បីប្រមូលធាតុចូល និងជាមូលដ្ឋានក្នុងការឆ្លើយតបទៅកាន់ដៃគូអន្តរជាតិនានា និងបានរៀបចំឯកសារសំណើគម្រោងនានា និងសំណើសុំជំនួយបច្ចេកទេសពីដៃគូអភិវឌ្ឍន៍ចំនួន ៤គម្រោង ដើម្បីជំរុញការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បានទទួលបដិសណ្ឋារកិច្ចភ្ញៀវអន្តរជាតិចំនួន ២លើក ដើម្បីបង្កើនកិច្ចសហប្រតិបត្តិការជាមួយនឹងដៃគូពាក់ព័ន្ធក្នុងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ខ. ការពង្រឹងសមភាពយេនឌ័រ និងសេវាសង្គម

- បានផ្សព្វផ្សាយព្រះរាជសារសម្តេចព្រះមហាក្សត្រី **នរោត្តម មុនីនាថ សីហនុ** ព្រះវររាជមាតាជាតិខ្មែរ ក្នុងសេរីភាព សេចក្តីថ្លៃថ្នូរ និងសុភមង្គលព្រះប្រធានកិត្តិយសនៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ក្នុងឱកាសប្រារព្ធពិធីអបអរសាទរទិវាអន្តរជាតិនារី៨មីនា ឆ្នាំ២០២៥ ខួបលើកទី១១៤ ក្រោមប្រធានបទ **"សិទ្ធិ សមភាព និងភាពអង់អាចចំពោះស្ត្រី និងក្មេងស្រីគ្រប់រូប"** ដោយមានអ្នកចូលរួមសរុបចំនួន ១ ០៦០នាក់ (ស្រី ១ ០១០នាក់)

- បានផ្តល់ឱកាស និងជំរុញលើកទឹកចិត្តនារីមានលទ្ធភាពទទួលបានការបណ្តុះបណ្តាលពង្រឹងសមត្ថភាព និងផ្តល់អាទិភាពឱ្យទទួលបានការដំឡើងតួនាទីសមស្របដល់មន្ត្រីរាជការជាស្ត្រីទៅតាមឋានានុក្រម ទាំងថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ

- បានផ្សព្វផ្សាយអនុសាសន៍គន្លឹះ ១២ចំណុចរបស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** និងជាអនុប្រធានកិត្តិយសទី២នៃក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ព្រមទាំងបានផ្សព្វផ្សាយគោលនយោបាយជាតិ វិធានការណ៍នានា ក្នុងការលើកកម្ពស់សមភាពយេនឌ័រ ក៏ដូចជាការធ្វើបរិវត្តកម្មយេនឌ័រតាមវិស័យ តាមរយៈវគ្គបណ្តុះបណ្តាលជនបង្គោលយេនឌ័រឆ្នាំ២០២៥ មានសិក្ខាកាមចូលរួមសរុប ២៥០នាក់(ស្រី ១៩៤នាក់)

- បានចូលរួមកិច្ចប្រជុំ និងផ្តល់របាយការណ៍វឌ្ឍនភាពក្នុងការអនុវត្តផែនការសកម្មភាព ឆ្នាំ២០២០-២០២៣/២៤ ឆ្លើយតបទៅនឹងសេចក្តីសង្កេតសន្និដ្ឋាន (COB) ៥៧ចំណុច របស់គណៈកម្មាធិការ CEDAW នៃអង្គការសហប្រជាជាតិ

៧

- បានរៀបចំយុទ្ធនាការ ១៦ថ្ងៃ ប្រយុទ្ធប្រឆាំងអំពើហិង្សាផ្អែកលើយេនឌ័រ ក្រោមប្រធានបទ **រួមគ្នាលើកកម្ពស់សុវត្ថិភាព និងការគោរពសិទ្ធិគ្នានៅកន្លែងការងារ** ដើម្បីលើកកម្ពស់ការយល់ដឹង ពង្រឹងកិច្ចខិតខំប្រឹងប្រែងក្នុងការទប់ស្កាត់ និងជំរុញវិធានការ ដើម្បីឆ្លើយតបទៅនឹងអំពើហិង្សា និងការបៀតបៀននៅកន្លែងធ្វើការ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព តម្លាភាព សមភាព និងសមធម៌ មានអ្នកចូលរួមសរុបប្រមាណ ១ ៨៣០នាក់

- បានអប់រំពលករខ្មែរស្តីពីការបង្ការ និងទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ គ្រឿងញៀន និងសុខភាពបន្តពូជ ដែលត្រៀមទៅធ្វើការនៅក្រៅប្រទេសចំនួន ២៥វគ្គ មានអ្នកចូលរួមសរុប ៤ ៤២៣នាក់ (ស្រី ១ ១៥៩នាក់) និងបានអប់រំផ្សព្វផ្សាយស្តីពីការបង្ការ ទប់ស្កាត់ការរាលដាលមេរោគអេដស៍/ជំងឺអេដស៍ និងគ្រឿងញៀនដល់សិស្ស និស្សិត កម្មករនិយោជិតនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រក្រោមឱវាទក្រសួងចំនួន ៨៥៤លើក មានអ្នកចូលរួមសរុប ៦៧ ៩៤៥នាក់ (ស្រី ៣៦ ៥០៦នាក់)

- បានធ្វើតេស្តស្វែងរកសារធាតុញៀនដល់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងមន្ត្រីជាប់កិច្ចសន្យានៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឆ្នាំ២០២៥ សរុបចំនួន ៤ ៥៧៨នាក់ (ស្រី ១ ៧៦០នាក់)

- បានទទួលពាក្យស្នើសុំបណ្ណសរសើរសហគ្រាស ក្រុមហ៊ុន រោងចក្រដែលមានស្នាដៃល្អក្នុងការអនុវត្តការងារប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការប្រចាំឆ្នាំ២០២៥ ចំនួន ៤៩៧សហគ្រាស

- គណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀនក្រសួង បានបើកវគ្គបណ្តុះបណ្តាលជនបង្គោលស្តីពី "ការបង្ការ និងទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងគ្រឿងញៀន" នៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ដែលមានសិក្ខាកាមជាជនបង្គោលនៅតាមគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈទាំង៣៧ ជនបង្គោលនៅតាមមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈរាជធានី ខេត្ត និងសមាជិក សមាជិកានៃគណៈកម្មការប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀនក្រសួង សរុបចំនួន ១១៤នាក់ (ស្រី ៤៩នាក់)

- គណៈកម្មការសម្របសម្រួលត្រីភាគីប្រយុទ្ធនឹងជំងឺអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ បានរៀបចំកិច្ចប្រជុំលើកទី២ ស្តីពី "ការពិនិត្យលើវឌ្ឍនភាពការងារទប់ស្កាត់ការរាលដាលមេរោគអេដស៍ និងគ្រឿងញៀននៅកន្លែងធ្វើការ និងវាយតម្លៃលើការផ្តល់បណ្ណសរសើរ ជូនសហគ្រាស ក្រុមហ៊ុន រោងចក្រ ដែលអនុវត្តបានល្អតាមប្រកាសលេខ០៨៦ ស្តីពី ការបង្កើតគណៈកម្មការអេដស៍នៅតាមសហគ្រាស គ្រឹះស្ថាន សម្រាប់ឆ្នាំ២០២៥" ដែលមានអ្នកចូលរួមសរុបចំនួន ៥៩នាក់ (ស្រី ១៩នាក់)។

### ២.៦.៥. ពង្រឹងការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងផែនការយុទ្ធសាស្ត្រ

ដើម្បីធានាឱ្យបាននូវប្រសិទ្ធភាព និងស័ក្តិសិទ្ធិភាពនៃការអនុវត្តការងារ ក្រសួងបានដាក់ចេញ និងអនុវត្តយន្តការ តាមដាន ត្រួតពិនិត្យ និងវាយតម្លៃ (M&E) ដ៏រឹងមាំ ព្រមទាំងបានចូលរួមយ៉ាងសកម្មក្នុងការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងកម្មវិធីអទិភាពនានារបស់រាជរដ្ឋាភិបាលកម្ពុជា។ លទ្ធផលជាក់ស្តែងសំខាន់ៗមួយចំនួនឆ្លើយតបនឹងគោលដៅខាងលើមានដូចតទៅ៖

- បានរៀបចំរបាយការណ៍វឌ្ឍនភាព នៃការតាមដាននិងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ប្រចាំឆ្នាំ២០២៤ និងប្រចាំឆមាសទី១ ឆ្នាំ២០២៥

- បានរៀបចំសិក្ខាសាលាស្តីពីការបូកសរុបរបាយការណ៍វឌ្ឍនភាព នៃការតាមដាននិងត្រួតពិនិត្យការអនុវត្តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ ២០២៤-២០២៨ ប្រចាំឆមាសទី១ ឆ្នាំ២០២៥

- បានដាក់ឱ្យដំណើរការប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ (M&E) នៃការអនុវត្ត ផ.យ.អ.-ក.ស.ប. ២០២៤-២០២៨ របស់ក្រសួង

- បានរៀបចំកម្មវិធីវគ្គបណ្តុះបណ្តាលស្តីពីការប្រើប្រាស់ស្តីពីការប្រើប្រាស់ប្រព័ន្ធតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ (M&E) នៃការអនុវត្ត ផ.យ.អ.-ក.ប.ស.ប ២០២៤-២០២៨

- បានតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពការងារតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ (M&E) និងការអនុវត្តអនុសាសន៍ទាំង ១០ចំណុច របស់ **សម្តេចធិបតី**

- បានរៀបចំផែនការសកម្មភាព ឆ្នាំ២០២៥-២០២៧ នៃការអនុវត្តគោលនយោបាយជាតិប្រជាជន ២០១៦-២០៣០ ផ្ញើជូនក្រសួងផែនការ

- បានរៀបចំរបាយការណ៍វឌ្ឍនភាពប្រចាំឆ្នាំ២០២៤ នៃការអនុវត្តផែនការសកម្មភាព ឆ្នាំ២០២១-២០២៥ របស់គោលនយោបាយជាតិស្តីពីមនុស្សវ័យចាស់២០២៧-២០៣០ និងផ្តល់យោបល់លើសេចក្តីព្រាងសៀវភៅ ស សង្គមកិច្ច ផ្ញើជូនក្រសួងសង្គមកិច្ច អតីតយុវជន និងយុវនីតិសម្បទា

- បានរៀបចំរបាយការណ៍វឌ្ឍនភាពឆ្នាំ២០២៤ នៃការអនុវត្តផែនការសកម្មភាព ២០២២-២០២៤ នៃគោលនយោបាយជាតិប្រជាជន២០១៦-២០៣០ ផ្ញើជូនក្រសួងផែនការ។

## ៣. បញ្ហាប្រឈម

ជាមួយលទ្ធផលការងារសម្រេចបានខាងលើ ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក៏បានជួបបញ្ហាប្រឈមសំខាន់ៗមួយចំនួនដែលត្រូវយកចិត្តទុកដាក់ និងបន្តដោះស្រាយ រួមមាន៖

- ប្រព័ន្ធគ្រប់គ្រងការផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារមិនទាន់ទូលំទូលាយដែលទាមទារឱ្យពង្រីកមជ្ឈមណ្ឌលការងារបន្ថែម

- មន្ត្រីផ្តល់សេវាមានតម្រូវការចាំបាច់ក្នុងពង្រឹងសមត្ថភាពផ្នែកប្រឹក្សាយោបល់ និងមគ្គុទេសក៍អាជីពការងារ និងវិជ្ជាជីវៈ និងការប្រើប្រាស់ប្រព័ន្ធឌីជីថលនៃសេវាការងារសាធារណៈ

- បញ្ហាដែលមានលក្ខណៈជារចនាសម្ព័ន្ធមួយចំនួន បាននឹងកំពុងរាំងស្ទះដល់ការរីកចម្រើននៃអនុវិស័យកម្មន្តសាល ដោយបញ្ហាទាំងនោះ រួមមាន កង្វះវត្ថុធាតុដើមក្នុងស្រុក, កង្វះជំនាញបច្ចេកទេស, ការកើនឡើងនៃភាពប្រកួតប្រជែងពីប្រទេសជិតខាង និងការប្រើប្រាស់បច្ចេកវិទ្យាក្នុងផលិតកម្មនៅមានកម្រិតទាប

- ទីផ្សារការងារមិនទាន់ដំណើរការបានល្អ ដោយសាររបាយកម្លាំងពលកម្មមិនស្មើគ្នា (រវាងទីប្រជុំជន និងជនបទ), សេវាអន្តរកម្មការងារ និងការបែងចែកព័ត៌មានមិនទាន់ដំណើរការពេញលេញ, បញ្ហាភាពមិនបន្សុីគ្នានៃជំនាញ និងប្រព័ន្ធព្យាករណ៍និងប៉ាន់ស្មានទៅអនាគតអំពីតម្រូវការ និងការផ្គត់ផ្គង់កម្លាំងពលកម្មនិងជំនាញមិនទាន់អភិវឌ្ឍបានពេញលេញ

- ការចុះឈ្មោះចូលរៀនកម្មវិធីជីវិត និងការផ្សព្វផ្សាយអំពីការអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជាពិសេស ក្រុមគោលដៅក្នុងកម្មវិធី ១,៥លាន នៅមានកម្រិត

- គ្រឹះស្ថានជីវិត ធំៗ ប្រមូលផ្តុំនៅរាជធានីភ្នំពេញ និងស្ថិតនៅទីរួមខេត្ត ខណៈក្រុមគោលដៅស្ថិតនៅឆ្ងាយ និងកំពុងធ្វើការនៅតាមសហគ្រាស ក្រុមហ៊ុន រោងចក្រ

- កញ្ចប់ស្តង់ដាបណ្តុះបណ្តាល នៅមិនទាន់មានគ្រប់ជំនាញ ឬមុខរបរ ដែលចាំបាច់ត្រូវអភិវឌ្ឍបន្ថែមតាមការវិវត្តរបស់តម្រូវការជំនាញក្នុងទីផ្សារការងារ

- ការអនុវត្តក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជា (CQF) ពុំទាន់បានទូលំទូលាយ ហើយការបង្រៀន និងរៀន នៅតាមគ្រឹះស្ថាន អ.ប.វ. មួយចំនួនមិនបានអនុវត្តទៅតាមក្របខណ្ឌគុណវុឌ្ឍិជាតិកម្ពុជាពេញលេញ ហើយមិន បានអនុវត្តតាមការបង្រៀនផ្អែកទៅលើសមត្ថភាព (CBT)

- កម្មវិធី និងគុណភាពជីវេត នៅមិនទាន់ឆ្លើយតបទៅនឹងតម្រូវការទីផ្សារការងារដោយសារកង្វះខាតគ្រូ បច្ចេកទេស និងសមត្ថភាពគ្រូមានកម្រិត ឬខុសជំនាញ, គុណភាពកញ្ចប់ស្តង់ដាបណ្តុះបណ្តាលពុំទាន់បានល្អ ប្រសើរ និងការបណ្តុះបណ្តាលផ្អែកលើសមត្ថភាពមិនទាន់បានអនុវត្តពេញលេញ

- កង្វះយន្តការលើកទឹកចិត្តឱ្យវិស័យឯកជនចូលរួមគាំទ្រដល់ការអភិវឌ្ឍវិស័យជីវេត

- ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងបរិក្ខារបច្ចេកទេសមិនទាន់ឆ្លើយតបទៅនឹងតម្រូវការបណ្តុះបណ្តាលតាម វិស័យ និងជំនាញអាទិភាព

- សហគ្រាស ក្រុមហ៊ុន រោងចក្រមួយចំនួន មិនទាន់មានការសហការល្អជាមួយក្រសួង ក្នុងការតាមដាន ការអនុវត្តច្បាប់ស្តីពីការងារ ប្រកាស និងបទប្បញ្ញត្តិស្តីពីសុវត្ថិភាព និងសុខភាពការងារ

- កម្មករនិយោជិត និងសាធារណជនមួយចំនួន នៅមិនទាន់បានយល់ដឹងច្បាស់អំពីនិយមន័យ យន្តការ និងលក្ខណៈវិនិច្ឆ័យនៃការកំណត់ប្រាក់ឈ្នួលអប្បបរមានៅកម្ពុជា

- សហជីព កម្មករនិយោជិត និងនិយោជកមួយចំនួនមានការយល់ដឹងផ្នែកច្បាប់ និងបទប្បញ្ញត្តិពាក់ព័ន្ធ នៅពុំទាន់បានស៊ីជម្រៅ ហើយការអនុវត្តនូវលក្ខខណ្ឌការងារតាមច្បាប់ស្តីពីការងារ, ច្បាប់ស្តីពីសហជីព និង បទប្បញ្ញត្តិពាក់ព័ន្ធ នៅពុំទាន់បានត្រឹមត្រូវនៅឡើយ

- បញ្ហាវិបត្តិសេដ្ឋកិច្ចសកលធ្វើឱ្យសហគ្រាស គ្រឹះស្ថានមួយចំនួនបានព្យួរកិច្ចសន្យាការងារ បិទទ្វារដោយ ម្ចាស់រត់ចោល និងក្ស័យធនជាហេតុធ្វើឱ្យកម្មករនិយោជិត ធ្វើការតវ៉ាកើតចេញជាបញ្ហាកូដកម្ម បាតុកម្ម ទាមទារ ប្រាក់ឈ្នួល និងអត្ថប្រយោជន៍ផ្សេងៗ

- ការវិលត្រឡប់ជាគំហុករបស់បងប្អូនពលករខ្មែរពីប្រទេសថៃ បានដាក់សម្ពាធលើទីផ្សារការងារកម្ពុជាក្នុង រយៈពេលខ្លី ដែលទាមទារការដាក់ចេញនូវវិធានការអន្តរាគមន៍ជាបន្តបន្ទាប់ក្នុងការស្វែងរកការងារ បង្កើតការងារ ក៏ដូចជាផ្តល់ការបណ្តុះបណ្តាលជំនាញជូនបងប្អូនពលករ

- ទីផ្សារការងារសម្រាប់ជនទេសន្តរប្រវេសន៍ការងារខ្មែរនៅមានចំនួនតិច និងការបញ្ជូនជនទេសន្តរប្រវេសន៍ ការងារខ្មែរជំនាញទៅធ្វើការនៅតាមបណ្តាប្រទេសទទួលនៅមានចំនួនតិចដោយជំនាញ និងភាសារបស់ជនទេសន្តរ ប្រវេសន៍ការងារខ្មែរនៅមានកម្រិត

- ពលករ និងប្រជាពលរដ្ឋមួយចំនួន នៅតែខ្វះការយល់ដឹងអំពីនីតិវិធី និងអត្ថប្រយោជន៍នៃការធ្វើទេសន្តរ ប្រវេសន៍ការងារដោយស្របច្បាប់

- វិសាលភាពនៃរបបសន្តិសុខសង្គមផ្នែកថែទាំសុខភាព មិនទាន់បានគ្របដណ្តប់គ្រប់ក្រុមគោលដៅនៅឡើយ ដែល ប.ស.ស. បាននឹងកំពុងបន្តសិក្សាពង្រីកបន្ថែមដល់ក្រុមគោលដៅផ្សេងទៀតជាបន្តបន្ទាប់តាមលំដាប់អាទិភាព ប្រកបដោយភាពប្រុងប្រយ័ត្ន ដើម្បីធានាបាននូវនិរន្តរភាពនៃមូលនិធិសន្តិសុខសង្គម

- សហគ្រាស គ្រឹះស្ថាន និងសមាជិកមួយចំនួននៅមិនទាន់យល់ដឹងអំពីកាតព្វកិច្ចនៃការបង់ភាគទាន និង ការអនុវត្តរបបសន្តិសុខសង្គមឱ្យបានត្រឹមត្រូវ ខណៈសហគ្រាស គ្រឹះស្ថាន និងសមាជិកមួយចំនួនទៀត បាន យល់ដឹងរួចហើយ ប៉ុន្តែបែរជាមានគោលបំណងគេចវេះពីការអនុវត្តកាតព្វកិច្ចទាំងនេះទៅវិញ

- ការយល់ដឹងពីផលវិបាកនៃការប្រើប្រាស់សេវាសុខាភិបាល ខុសគោលដៅរបស់សមាជិក ប.ស.ស. នៅមានកម្រិត ដែលជាហេតុធ្វើឱ្យមានភាពខ្វះខាតនូវមូលនិធិសន្តិសុខសង្គម

- ការទាមទារឱ្យ ប.ស.ស. បង់ថ្លៃសេវាព្យាបាលបន្ថែមខុសគោលការណ៍ច្បាប់ដោយមូលដ្ឋានសុខាភិបាលមួយចំនួននៅតែជាបញ្ហាប្រឈមនៅឡើយ ការបាត់បង់សុពលភាពសមាជិក គុណភាពសេវាព្យាបាល និងបញ្ហាប្រឈមផ្នែកសមត្ថភាពស្ថាប័ននិងធនធានមនុស្សចាំបាច់ដែលត្រូវដោះស្រាយ

- មន្ត្រីមួយចំនួនមិនទាន់យល់ច្បាស់ពីការប្រើប្រាស់ប្រព័ន្ធគ្រប់គ្រងមន្ត្រីតាមប្រព័ន្ធព័ត៌មានវិទ្យា (HRM)

- ការរៀបចំបំពេញផែនការសកម្មភាព និងរបាយការណ៍វឌ្ឍនភាពនៅក្នុងប្រព័ន្ធបរិវត្តកម្មឌីជីថលលើការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ ការបំពេញចូលប្រព័ន្ធមិនទាន់បានពេញលេញ

- មិនទាន់មានបន្ទប់ដើម្បីបម្រើដល់ការបណ្តុះបណ្តាលរបស់វិទ្យាស្ថានជាតិការងារ

- សមត្ថភាពមន្ត្រីរាជការពាក់ព័ន្ធជំនាញសវនកម្មសមិទ្ធកម្ម និងសវនកម្មបច្ចេកវិទ្យាព័ត៌មាន នៅមានកម្រិត

- ការធ្វើអធិការកិច្ចផ្អែកលើហានិភ័យ និងករណីសង្ស័យ គឺជារបត់ការងារថ្មីមួយសម្រាប់មន្ត្រីអធិការកិច្ចដែលនៅមានភាពស្រពេចស្រពិលនៅឡើយ

- ចំណតរថយន្ត ម៉ូតូសម្រាប់មន្ត្រីរាជការ និងភ្ញៀវអញ្ជើញចូលរួមប្រជុំនៅក្នុងបរិវេណទីស្តីការក្រសួងមិនទាន់រៀបចំសមស្របតាមតម្រូវការ។

## ៤. ទិសដៅអនុវត្តការងារបន្ត

- បន្តអនុវត្តឱ្យមានប្រសិទ្ធភាពខ្ពស់នូវអនុសាសន៍ដ៏ខ្ពង់ខ្ពស់ទាំង ១០ចំណុច របស់ **សម្តេចធិបតី**

- បន្តពង្រឹង និងពង្រីកវិសាលភាពក្នុងការផ្តល់សេវាការងារ និងបន្តយុទ្ធនាការផ្សព្វផ្សាយអំពីព័ត៌មានទីផ្សារការងារទាំងក្នុងស្រុក និងក្រៅស្រុកដល់ទីជនបទ

- បន្តជំរុញការធ្វើការអង្កេត សិក្សា និងស្រាវជ្រាវអំពីជំនាញរបស់សិស្ស និស្សិត តម្រូវការជំនាញ និងទីផ្សារការងារ ដែលគាំទ្រដល់ការរៀបចំ និងអនុវត្តគោលនយោបាយទីផ្សារការងារសកម្ម សំដៅបង្កើតទីផ្សារការងារមួយដែលមានភាពរឹងមាំ និងជវភាព

- បន្តអនុវត្តកម្មវិធីបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ ជូនដល់យុវជនគោលដៅមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ១,៥លាននាក់ និងបន្តអនុវត្តការពង្រីកក្រុមគោលដៅ នៃការបណ្តុះបណ្តាលជូនដល់កម្មករនិយោជិតទាំងក្នុង និងក្រៅប្រព័ន្ធ ស្ត្រី ជនមានពិការភាព ជនជាតិដើមភាគតិច និងសិស្សដែលបោះបង់ការសិក្សា

- បន្តផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ ជូនដល់ពលករ ដើម្បីផ្លាស់ប្តូរជំនាញឱ្យស្របតាមតម្រូវការកម្លាំងពលកម្មក្នុងប្រទេស

- បន្តផ្តល់ការទទួលស្គាល់ និងផ្តល់គុណវុឌ្ឍិ ដល់អតីតពលករ ជាពិសេសអតីតពលករដែលធ្វើការផ្នែកសំណង់ តាមរយៈការវាយតម្លៃផ្អែកលើសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន (RPL) ដើម្បីគាត់អាចបានវិញ្ញាបនបត្របញ្ជាក់ជំនាញ សម្រាប់ធ្វើការនៅតាមការដ្ឋានសំណង់ធំៗ

- បន្តជំរុញការអនុវត្តជម្រើសវិធានការអន្តរាគមន៍ជូនប្រជាពលរដ្ឋ និងពលករខ្មែរត្រឡប់ពីប្រទេសថៃចំនួន ៤បន្ថែមទៀត ដូចខាងក្រោម ៖

- ទី១. រៀបចំ និងអនុវត្តកញ្ចប់អន្តរាគមន៍ក្នុងការបណ្តុះបណ្តាលកម្រិតសញ្ញាបត្របច្ចេកទេស និងវិជ្ជាជីវៈ១ (C1) នៅតាមគ្រឹះស្ថានជីវិត
- ទី២. រៀបចំ និងផ្តល់កម្មវិធីបណ្តុះបណ្តាលតាមលិខិតបញ្ជាក់ (Voucher Skills Training Programme) ដែលបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ រយៈពេលខ្លី ១សប្តាហ៍ និង ១ខែ ក្នុងវិស័យកសិកម្ម និងសេវាកម្ម តាមតម្រូវការជាក់ស្តែង នៅក្នុងសហគមន៍ ដោយគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ សហការជាមួយអាជ្ញាធរមូលដ្ឋាន
- ទី៣. ជំរុញការអនុវត្តការវាយតម្លៃផ្អែកលើសមត្ថភាពទទួលស្គាល់ការសិក្សា ដែលមានពីមុន (RPL) ដោយឥតគិតថ្លៃដល់ពលករខ្មែរដែលទើបត្រឡប់ពីប្រទេសថៃ ដើម្បីទទួលបានវិញ្ញាបនបត្រគុណវុឌ្ឍិផ្លូវការ ក្នុងការបង្កើនលទ្ធភាពជូនពលករឱ្យឆាប់ទទួលបានការងារធ្វើសមស្របទៅនឹងជំនាញ និងបទពិសោធរបស់ពួកគាត់
- ទី៤. បន្តរៀបចំពិព័ណ៌ការងារ និងវេទិកាការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈនៅតាមបណ្តាខេត្តសំខាន់ៗ ដោយសហការជាមួយក្រសួង ស្ថាប័ន អាជ្ញាធរមូលដ្ឋាន ដៃគូជាតិ និងអន្តរជាតិ

- បន្តពង្រឹង និងពង្រីកកម្មវិធីហ្វឹកហ្វឺនកូនជាង កម្មវិធីបណ្តុះបណ្តាលផ្លាស់ប្តូរជំនាញ កម្មវិធីបណ្តុះបណ្តាលបង្កើនជំនាញ និងកម្មវិធីសិក្សាផ្អែកលើការងារ និងកម្មវិធីបណ្តុះបណ្តាលតាមបច្ចេកវិទ្យាឌីជីថល, ពង្រឹងនិងពង្រីកការធ្វើតេស្តវាយតម្លៃសមត្ថភាពទទួលស្គាល់ការសិក្សាដែលមានពីមុន និងសមត្ថភាពបច្ចុប្បន្ន និងជំរុញការទទួលស្គាល់ជំនាញគ្នាទៅវិញទៅមកក្នុងតំបន់អាស៊ាន

- បន្តពង្រឹងភាពជាដៃគូរវាងរដ្ឋ ឯកជន និងដៃគូអភិវឌ្ឍន៍ ដើម្បីធានានិរន្តរភាពនៃកម្មវិធីបណ្តុះបណ្តាលតាមរយៈការបន្តរៀបចំ និងជំរុញការអនុវត្តកម្មវិធីភាពជាដៃគូរវាងរដ្ឋ និងឯកជន ក្នុងការអភិវឌ្ឍវិស័យ អ.ប.វ. និងផ្តល់ឱកាសដល់សិស្ស និស្សិត ចុះកម្មសិក្សា ទស្សនកិច្ចសិក្សា, បន្តបង្កើនកិច្ចសហប្រតិបត្តិការរវាងរដ្ឋ និងឯកជន, ជំរុញវិស័យឯកជនឱ្យប្រើប្រាស់កម្លាំងពលកម្មជំនាញដែលបានឆ្លងកាត់កម្មវិធី អ.ប.វ. និងរៀបចំយន្តការផ្តល់កម្ចីសិក្សាដល់សិក្ខាកាម សិស្ស និស្សិត, រៀបចំយន្តការក្នុងការប្រើប្រាស់អ្នកបច្ចេកទេស និងវិស្វករសម្រាប់ផ្តល់ការបណ្តុះបណ្តាលជំនាញបច្ចេកទេស និងវិជ្ជាជីវៈ និងបង្កើនចំនួន និងពង្រឹងតួនាទីក្រុមប្រឹក្សាជំនាញតាមវិស័យ

- បន្តជំរុញការស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ តាមរយៈការបង្កើនចំនួនមជ្ឈមណ្ឌលស្រាវជ្រាវនវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ពាក់ព័ន្ធនឹងផ្នែកឧស្សាហកម្មស្វ័យប្រវត្តិកម្ម ឬរ៉ូបូត, ជំរុញនិងលើកទឹកចិត្តដល់សិស្ស និស្សិត ឱ្យរៀបចំគម្រោងសិក្សាស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ សម្រាប់បញ្ចប់ការសិក្សា, រៀបចំពិព័រណ៍តាំងបង្ហាញសមិទ្ធផលគម្រោងស្រាវជ្រាវ នវានុវត្តន៍ និងបច្ចេកវិទ្យាអនុវត្តន៍ និងបន្តជំរុញការរៀបចំការប្រកួតប្រជែងជំនាញថ្នាក់ភូមិភាគ ថ្នាក់ជាតិ និងបង្កើនការចូលរួមការប្រកួតប្រជែងជំនាញថ្នាក់អាស៊ាន និងថ្នាក់អន្តរជាតិ

- បន្តពង្រឹងការអនុវត្តច្បាប់ និងលើកកម្ពស់អត្រាអនុលោមភាពតាមច្បាប់ តាមរយៈការពង្រឹងយន្តការអធិការកិច្ចការងារតាមប្រព័ន្ធស្វ័យអធិការកិច្ចការងារ និងក្រុមអធិការកិច្ចអន្តរក្រសួង

- បន្តពង្រឹងការអនុវត្តច្បាប់ និងបទប្បញ្ញត្តិនានាពាក់ព័ន្ធនឹងសុវត្ថិភាព និងសុខភាពការងារតាមរយៈការចុះធ្វើអធិការកិច្ចការងារ

- បន្តពង្រឹងទំនាក់ទំនងវិជ្ជាជីវៈ ដោយបន្តប្រែក្លាយសហគ្រាសមួយជាសហគមន៍សុខសាន្តមួយតាមរយៈការកសាង និងអភិវឌ្ឍសមត្ថភាពថ្នាក់ដឹកនាំអង្គការវិជ្ជាជីវៈ (សហជីព និងសមាគមនិយោជក) អំពីការកសាងសុខដុមនីយកម្មនៃទំនាក់ទំនងវិជ្ជាជីវៈ យន្តការដោះស្រាយវិវាទការងារនិងសិល្បៈនៃការចរចា និងធ្វើការងារជាក្រុមដល់បុគ្គលិកជាន់ខ្ពស់ទទួលបន្ទុកផ្នែកធនធានមនុស្សនៃសហគ្រាស ក្រុមហ៊ុន និងរោងចក្រ និងតំណាងកម្មករនិយោជិត

- បន្តការពង្រឹងយន្តការបង្ការ ទប់ស្កាត់ និងដោះស្រាយវិវាទការងារនៅគ្រប់ដំណាក់កាល ព្រមទាំងជំរុញកិច្ចសហការរបស់ភាគីវិវាទក្នុងដំណើរការផ្សះផ្សាវិវាទការងារ

- បន្តសម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់ភាគីពាក់ព័ន្ធក្នុងការសិក្សាស្រាវជ្រាវ និងការប្រជុំពិភាក្សាកំណត់ប្រាក់ឈ្នួលអប្បបរមាសម្រាប់កម្មករនិយោជិតផ្នែកវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលិតផលធ្វើដំណើរនិងកាបូប សម្រាប់ឆ្នាំ២០២៧

- បន្តពង្រឹងការគ្រប់គ្រងទេសន្តរប្រវេសន៍ការងារប្រកបដោយសុវត្ថិភាព គុណភាព និងប្រសិទ្ធភាព

- បន្តសហការជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន វិស័យឯកជន និងភាគីពាក់ព័ន្ធទាំងអស់ដើម្បីពង្រឹងប្រសិទ្ធភាពអន្តរាគមន៍ ដែលបានដាក់ចេញកន្លងមកសម្រាប់បងប្អូនពលករខ្មែរ និងត្រៀមដាក់ចេញនូវអន្តរាគមន៍មួយចំនួនក្នុងការប្រមូលព័ត៌មានឱកាសការងារ, ផ្សព្វផ្សាយព័ត៌មានឱកាសការងារ និងការផ្គូផ្គងការងារជូនដល់បងប្អូនពលករ ដែលបានវិលត្រឡប់ពីប្រទេសថៃ

- បន្តធ្វើការសិក្សាសមិទ្ធលទ្ធភាពនៃការពង្រីកវិសាលភាពដល់ក្រុមគោលដៅ (ផលិតផលថ្មី) ដែលមិនទាន់គ្របដណ្តប់នៅក្នុងរបបសន្តិសុខសង្គម (Missing-Middle) ជាបន្តបន្ទាប់តាមលំដាប់អាទិភាពដោយអភិក្រមប្រុងប្រយ័ត្ន គ្រប់ជ្រុងជ្រោយ និងធានាបាននូវនិរន្តរភាពនៃមូលនិធិសន្តិសុខសង្គម

- បន្តសិក្សាលទ្ធភាពពង្រីកវិសាលភាពការអនុវត្តរបបសន្តិសុខសង្គម ផ្នែកប្រាក់សោធនដល់មន្ត្រីសាធារណៈសំដៅជួយកាត់បន្ថយបន្ទុកថវិកាជាតិ

- បន្តពង្រឹងការអនុវត្តច្បាប់ស្តីពីរបបសន្តិសុខសង្គមសំដៅពង្រឹង និងបង្កើនការចុះបញ្ជិកា សហគ្រាសគ្រឹះស្ថាន ព្រមទាំងធ្វើការពង្រីកការគ្របដណ្តប់ដល់ក្រុមគោលដៅដទៃផ្សេងទៀត តាមរយៈយន្តការចុះអធិការកិច្ច និងសហការចែករំលែកទិន្នន័យជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធ និងអាជ្ញាធរមូលដ្ឋាន

- បន្តបង្កើន និងបន្តជំរុញការផ្សព្វផ្សាយ ដើម្បីបញ្ជ្រាបការយល់ដឹងអំពីរបបសន្តិសុខសង្គម និងលើកកម្ពស់ការយល់ដឹងអំពីនីតិវិធីនៃការប្រើប្រាស់សេវារបស់ ប.ស.ស. តាមគ្រប់រូបភាព និងគ្រប់ទម្រង់ដោយភាពប្រទាក់ក្រឡាគ្នា

- បន្តរៀបចំត្រៀមការពង្រីកវិសាលភាពកម្មវិធីផ្តល់ប្រាក់ឧបត្ថម្ភរបស់រាជរដ្ឋាភិបាល សម្រាប់ស្ត្រីមានផ្ទៃពោះ និងកុមារអាយុក្រោម ២ឆ្នាំ ទៅដល់សមាជិកក្រុមប្រឹក្សារាជធានី ខេត្ត ក្រុង ស្រុក ខណ្ឌ ឃុំ សង្កាត់ ចាប់ពីខែមករា ឆ្នាំ២០២៦

- ប.ស.ស. និង ន.ស.ស. នឹងបន្តសហការរៀបចំយន្តការដោះស្រាយបញ្ហាដែលពាក់ព័ន្ធការគ្រប់គ្រងចំណាយឱ្យមានប្រសិទ្ធភាព និងពង្រឹងនិរន្តរភាពមូលនិធិដែលមូលដ្ឋានសុខាភិបាលអនុវត្តខុសកិច្ចព្រមព្រៀងកន្លងមករួមមាន ទី១). ការបន្តទូទាត់ជូនមូលដ្ឋានសុខាភិបាលឯកជនដែលមានអាជ្ញាប័ណ្ណផុតសុពលភាព ទី២). ការទូទាត់ស្ទួនលើឱសថ ទី៣). ការបំបែកការទូទាត់តាមប្រភេទករណី ទៅជាការទូទាត់តាមប្រភេទថ្លៃសេវា និងទី៤). ការទូទាត់ថ្លៃសេវាដែលផ្តល់ក្នុងអំឡុងកិច្ចព្រមព្រៀងមិនមានសុពលភាព និងការកំណត់ថ្លៃទូទាត់លើសពីបទប្បញ្ញត្តិជាធរមាន

- បន្តពង្រឹងប្រសិទ្ធភាពការងារ តាមរយៈការធ្វើឌីជីថលូបនីយកម្ម និងពង្រីកទីតាំងនៃការផ្តល់សេវាសាធារណៈរបស់ក្រសួង តាមរយៈការបន្ថែមបញ្ជរសេវាសាធារណៈចល័តនៅតាមផ្សារទំនើប និងទីប្រជុំជនផ្សេងទៀត

- បន្តកែលម្អគុណភាពនៃការផ្តល់សេវាសាធារណៈ ដើម្បីឆ្លើយតបនឹងតម្រូវការអ្នកទទួលសេវានៅទីស្តីការក្រសួង ដោយសហការ និងតាមដាននីតិវិធីនៃការសិក្សាសេវាសាធារណៈ ដើម្បីដាក់បញ្ចូលទៅក្នុងប្រព័ន្ធ Online និងតាមដានការសិក្សាសេវាសាធារណៈថ្មីៗ និងដាក់បញ្ចូលទៅច្រកទ្វារអេឡិចត្រូនិកផ្តល់ព័ត៌មានសេវាសាធារណៈ

- ពង្រឹងយន្តការច្រកចេញចូលតែមួយលើការងារសម្របសម្រួលកិច្ចសហប្រតិបត្តិការ និងគ្រប់គ្រងអនុស្សរណៈនៃការយោគយល់គ្នា និងកិច្ចព្រមព្រៀងផ្សេងៗ ដើម្បីធានាបាននូវសង្គតិភាព វឌ្ឍនភាព និងអត្ថប្រយោជន៍អតិបរមាសម្រាប់កម្ពុជា ដោយផ្អែកលើទិដ្ឋភាពនយោបាយ សេដ្ឋកិច្ច និងច្បាប់

- បន្តពង្រឹងការផ្សព្វផ្សាយ និងការអនុវត្តតាមអនុសាសន៍ទាំង ១២ចំណុច របស់ **សម្តេចធិបតី** ដើម្បីលើកកម្ពស់សមភាពយេនឌ័រក្នុងវិស័យការងារ សន្តិសុខសង្គម និងបណ្តុះបណ្តាលវិជ្ជាជីវៈ

- បន្តរៀបចំឱ្យមានការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើការអនុវត្តការងាររបស់គ្រប់អង្គភាពក្រោមឱវាទក្រសួង ដោយរៀបចំរបាយការណ៍វឌ្ឍនភាពរបស់ក្រសួងឱ្យកាន់តែល្អប្រសើរ និងគោលនយោបាយផែនការយុទ្ធសាស្ត្រផែនការសកម្មភាព

- បន្តអនុវត្តឱ្យមានប្រសិទ្ធភាពនូវអភិក្រមទាំង៥ គឺ "**ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់**" និងបាវចនា ២ "**កែទម្រង់ផ្ទៃក្នុង និងបង្កើនមិត្តខាងក្រៅក្នុងស្មារតីឯករាជ្យ**" របស់ **សម្តេចតេជោ**។

៦៧

## ៥. សេចក្តីសន្និដ្ឋាន

ជារួម ឆ្នាំ២០២៥ គឺជាឆ្នាំដែលពោរពេញទៅដោយបញ្ហាប្រឈម និងការសាកល្បងដ៏ស្មុគស្មាញ ប៉ុន្តែក៏ជាឆ្នាំដែលបង្ហាញយ៉ាងច្បាស់នូវភាពរឹងមាំ និងភាពធន់នៃទីផ្សារការងារនៅកម្ពុជាផងដែរ។ ក្រោមការតម្រង់ទិសដ៏ត្រឹមត្រូវតាម **យុទ្ធសាស្ត្របញ្ចកោណ-ដំណាក់កាលទី១** របស់រាជរដ្ឋាភិបាល ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ មិនត្រឹមតែរក្សាបាននូវស្ថិរភាពការងារប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបានបំពេញតួនាទីយ៉ាងសកម្មក្នុងការដោះស្រាយផលប៉ះពាល់ដែលកើតចេញពីវិបត្តិសន្តិសុខនៅតាមបណ្តោយព្រំដែនបានយ៉ាងជោគជ័យ។ វឌ្ឍនភាពនេះ សបញ្ជាក់ឱ្យឃើញពីសមត្ថភាពគ្រប់គ្រងវិបត្តិ និងភាពបុរេសកម្មរបស់ក្រសួង ក្នុងការធានានូវសន្តិសុខចំណូល និងសេចក្តីថ្លៃថ្នូររបស់កម្មករនិយោជិត តាមរយៈការធ្វើសមាហរណកម្មពលករដែលបានធ្វើមាតុភូមិនិវត្តន៍ចូលក្នុងទីផ្សារការងារ ដើម្បីគាំទ្រវិស័យឧស្សាហកម្មក្នុងស្រុក និងការរក្សានូវសុខដុមនីយកម្មទំនាក់ទំនងវិជ្ជាជីវៈ ទោះបីជាស្ថិតក្នុងកាលៈទេសៈដ៏លំបាកយ៉ាងណាក្តី។

បន្ថែមពីលើការឆ្លើយតបនឹងវិបត្តិ ក្រសួងបានបន្តពង្រឹងមូលដ្ឋានគ្រឹះនៃការអភិវឌ្ឍប្រកបដោយបរិយាបន្ន ដោយសម្រេចបាននូវសមិទ្ធផលយ៉ាងប្រសើរក្នុងការអនុវត្តកម្មវិធីបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបច្ចេកទេសដល់យុវជនមកពីគ្រួសារក្រីក្រ និងគ្រួសារងាយរងហានិភ័យ ១,៥លាននាក់ ដែលបានក្លាយជាកម្លាំងចលករមិនអាចខ្វះបានក្នុងការផ្គត់ផ្គង់មូលធនមនុស្សជំនាញសម្រាប់ទីផ្សារការងារ និងការទាក់ទាញវិនិយោគថ្មីៗ។ ទន្ទឹមនឹងនេះ របបសន្តិសុខសង្គមត្រូវបានពង្រីកវិសាលភាពយ៉ាងទូលំទូលាយទៅដល់ប្រជាពលរដ្ឋក្នុងសេដ្ឋកិច្ចក្រៅប្រព័ន្ធ និងបុគ្គលស្វ័យនិយោជន៍ ដែលជាការកសាងសំណាញ់សុវត្ថិភាពសង្គមដ៏រឹងមាំ និងបានផ្តល់ការជឿទុកចិត្តកាន់តែខ្លាំងពីសំណាក់សាធារណជន តាមរយៈការលើកកម្ពស់គុណភាពសេវា និងការផ្តល់របបថែទាំសុខភាពប្រកបដោយប្រសិទ្ធភាព។

ទោះបីជាសម្រេចបាននូវវឌ្ឍនភាពគួរជាទីមោទនៈយ៉ាងណាក្តី ក្រសួងក៏ទទួលស្គាល់ថា បរិបទនៃបម្រែបម្រួលរចនាសម្ព័ន្ធសេដ្ឋកិច្ច ការវិវត្តនៃបច្ចេកវិទ្យាឌីជីថល និងការអនុលោមតាមស្តង់ដារអន្តរជាតិ នៅតែបន្តជាបញ្ហាប្រឈមដែលតម្រូវឱ្យមានការយកចិត្តទុកដាក់ខ្ពស់។ សរុបសេចក្តីមក លទ្ធផលការងារឆ្នាំ២០២៥ គឺជាកញ្ចក់ឆ្លុះបញ្ចាំងយ៉ាងប្រចក្សនូវការប្តេជ្ញាចិត្ត និងឆន្ទៈមោះមុតរបស់ថ្នាក់ដឹកនាំ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដោយក្រសួងប្តេជ្ញាបន្តអនុវត្តបេសកកម្មរបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ និងបន្តធ្វើទំនើបកម្មស្ថាប័ន ដើម្បីប្រែក្លាយបញ្ហាប្រឈមឱ្យទៅជាឱកាស និងបន្តកសាងមូលដ្ឋានគ្រឹះដ៏រឹងមាំសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ច-សង្គម ស្របតាមចក្ខុវិស័យរបស់រាជរដ្ឋាភិបាល ក្នុងការនាំកម្ពុជាឆ្ពោះទៅជាប្រទេសដែលមានចំណូលខ្ពស់នៅឆ្នាំ២០៥០។

ថ្ងៃ ចន្ទ ៧កើត ខែផល្គុន ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែកុម្ភៈ ឆ្នាំ២០២៦

**រដ្ឋមន្ត្រី**

**ហេង សួរ**

# តារាងឧបសម្ព័ន្ធ

# ឧបសម្ព័ន្ធ ១.
# ការរៀបចំ និងអនុវត្តគោលនយោបាយ ទីផ្សារការងារសកម្ម

## តារាង ១.១ ការជ្រើសរើសកម្លាំងពលកម្ម តាមវិស័យ

| ល.រ | បរិយាយ | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|
| ១ | សេវាកម្ម | 4,004 | 2,553 | -36.24% |
| ២ | ឧស្សាហកម្ម | 33,851 | 75,469 | 122.94% |
| ២.១ | កាត់ដេរ | 29,713 | 64,939 | 118.55% |
| ២.១.១ | កាត់ដេរសម្លៀកបំពាក់ | 23,731 | 54,349 | 129.03% |
| ២.១.២ | ផលិតស្បែកជើង | 3,728 | 3,008 | -19.32% |
| ២.១.៣ | ផលិតផលិតផលធ្វើដំណើរនិងកាបូប | 2,254 | 7,582 | 236.35% |
| ២.២ | ឧស្សាហកម្មផ្សេងទៀត | 4,138 | 10,530 | 154.45% |
| ៣ | កសិកម្ម | 9,044 | 3,685 | -59.26% |
| សរុប | | **46,899** | **81,707** | **74.22%** |

ប្រភព៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## តារាង ១.២ ការជ្រើសរើសកម្លាំងពលកម្ម តាមមុខរបរ

| ល.រ | ២០២៤ | | ២០២៥ | |
|---|---|---|---|---|
| | មុខរបរ | ចំនួន | មុខរបរ | ចំនួន |
| ១ | អ្នកបញ្ជាម៉ាស៊ីនដេរ | 25,221 | អ្នកបញ្ជាម៉ាស៊ីនដេរ | 58,376 |
| ២ | កម្មករចម្ការដំណាំ | 8,766 | កម្មករក្នុងផលិតកម្ម | 8,067 |
| ២.១ | កម្មករក្នុងផលិតកម្ម | 2,812 | កម្មករចម្ការដំណាំ | 3,644 |
| ២.១.១ | មន្ត្រីឥណទាន និងប្រាក់កម្ចី | 824 | យន្តការី និងអ្នកជំឡើងអគ្គិសនី | 3,130 |
| ២.១.២ | កម្មករខ្ចប់វេចដោយដៃ | 505 | អ្នកបញ្ជាម៉ាស៊ីនធ្វើស្បែកជើង | 2,988 |
| ២.១.៣ | អ្នកធ្វើការក្នុងកាស៊ីណូ | 448 | បុគ្គលិកការិយាល័យទូទៅ | 621 |
| ២.២ | អ្នកត្រួតពិនិត្យដំណើរការផលិតលោហធាតុ | 338 | កម្មករខ្ចប់វេចដោយដៃ | 472 |
| ៣ | មុខរបរផ្សេងៗ | 7,985 | មុខរបរផ្សេងៗ | 4,409 |
| | សរុប | **46,899** | សរុប | **81,707** |

ប្រភព៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## តារាង ១.៣ បច្ចុប្បន្នភាពចំនួនសហគ្រាស ក្រុមហ៊ុន រោងចក្រ និងកម្មករនិយោជិត

| ល.រ | បរិយាយ | ឯកតា | គិតត្រឹមឆ្នាំ២០២៤ | | | គិតត្រឹមឆ្នាំ២០២៥ * | | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ថ្នាក់កណ្ដាល | រាជធានីខេត្ត | សរុប | ថ្នាក់កណ្ដាល | រាជធានីខេត្ត | |
| ១ | វិស័យកាត់ដេរ | សហគ្រាស | 1,566 | 719 | 847 | 1,867 | 807 | 1,060 | 19.22% |
| | | កម្មករនិយោជិត | 924,045 | 325,276 | 598,769 | 1,134,091 | 377,431 | 756,660 | 22.73% |
| | | ស្រី | 691,423 | 245,340 | 446,083 | 822,605 | 283,353 | 539,252 | 18.97% |
| ២ | វិស័យក្រៅពីកាត់ដេរ | សហគ្រាស | 43,232 | 24,100 | 19,132 | 44,782 | 24,950 | 19,832 | 3.59% |
| | | កម្មករនិយោជិត | 892,001 | 418,488 | 473,513 | 1,083,434 | 561,159 | 522,275 | 21.46% |
| | | ស្រី | 373,258 | 167,773 | 205,485 | 462,367 | 236,104 | 226,263 | 23.87% |
| សរុប | | **សហគ្រាស** | **44,798** | **24,819** | **19,979** | **46,649** | **25,757** | **20,892** | **4.13%** |
| | | **កម្មករនិយោជិត** | **1,816,046** | **743,764** | **1,072,282** | **2,217,525** | **938,590** | **1,278,935** | **22.11%** |
| | | **ស្រី** | **1,064,681** | **413,113** | **651,568** | **1,284,972** | **519,457** | **765,515** | **20.69%** |

ប្រភព ៖ នាយកដ្ឋានអធិការកិច្ចការងារ

សម្គាល់ ៖ * តួលេខទាញចេញពីប្រព័ន្ធ (ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៥)។

# តារាង ១.៤ បច្ចុប្បន្នភាពស្ថិតិស្ដីពីចំនួនសហគ្រាស ក្រុមហ៊ុន រោងចក្រ និងចំនួនកម្មករនិយោជិតបែងចែកតាមរាជធានី ខេត្ត

| ល.រ | រាជធានី ខេត្ត | គិតត្រឹមឆ្នាំ២០២៤ | | | | | | | | | គិតត្រឹមឆ្នាំ២០២៥ | | | | | | | | | បម្រែបម្រួល (%) កម្មករ |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | សរុប | | | កាត់ដេរ | | | ក្រៅពីកាត់ដេរ | | | សរុប | | | កាត់ដេរ | | | ក្រៅពីកាត់ដេរ | | | |
| | | សហ | កម្មករ | ស្រី | សហ | កម្មករ | ស្រី | សហ | កម្មករ | ស្រី | សហ | កម្មករ | ស្រី | សហ | កម្មករ | ស្រី | សហ | កម្មករ | ស្រី | |
| ១ | បន្ទាយមានជ័យ | **948** | **21,870** | **11,036** | 6 | 4,942 | 3,491 | 942 | 16,928 | 7,545 | **962** | **20,717** | **10,583** | 6 | 5,114 | 3,593 | 956 | 15,603 | 6,990 | -5.27% |
| ២ | បាត់ដំបង | **1,271** | **15,569** | **6,126** | 1 | 20 | 14 | 1,270 | 15,549 | 6,112 | **1,293** | **14,059** | **5,973** | 1 | 17 | 10 | 1,292 | 14,042 | 5,963 | -9.70% |
| ៣ | កំពង់ចាម | **620** | **44,021** | **30,597** | 24 | 30,180 | 25,154 | 596 | 13,841 | 5,443 | **634** | **49,416** | **38,014** | 31 | 34,469 | 30,452 | 603 | 14,947 | 7,562 | 12.26% |
| ៤ | កំពង់ឆ្នាំង | **400** | **56,111** | **43,776** | 23 | 51,453 | 42,134 | 377 | 4,658 | 1,642 | **412** | **59,243** | **43,579** | 28 | 53,864 | 41,647 | 384 | 5,379 | 1,932 | 5.58% |
| ៥ | កំពង់ស្ពឺ | **1,359** | **223,315** | **145,818** | 318 | 184,939 | 129,397 | 1,041 | 38,376 | 16,421 | **1,575** | **311,608** | **191,516** | 418 | 266,390 | 173,098 | 1,157 | 45,218 | 18,418 | 39.54% |
| ៦ | កំពង់ធំ | **578** | **14,661** | **5,753** | 0 | 0 | 0 | 578 | 14,661 | 5,753 | **593** | **17,025** | **6,955** | 0 | 0 | 0 | 593 | 17,025 | 6,955 | 16.12% |
| ៧ | កំពត | **845** | **21,749** | **12,565** | 7 | 10,391 | 8,686 | 838 | 11,358 | 3,879 | **862** | **27,580** | **15,561** | 7 | 12,355 | 10,367 | 855 | 15,225 | 5,194 | 26.81% |
| ៨ | កណ្ដាល | **1,971** | **199,836** | **137,711** | 261 | 163,656 | 122,750 | 1,710 | 36,180 | 14,961 | **2,074** | **227,680** | **150,566** | 299 | 188,128 | 135,633 | 1,775 | 39,552 | 14,933 | 13.93% |
| ៩ | កោះកុង | **226** | **19,989** | **9,852** | 2 | 5,334 | 3,404 | 224 | 14,655 | 6,448 | **251** | **18,494** | **9,826** | 2 | 7,043 | 4,402 | 249 | 11,451 | 5,424 | -7.48% |
| ១០ | ក្រចេះ | **278** | **13,957** | **5,608** | 0 | 0 | 0 | 278 | 13,957 | 5,608 | **282** | **23,650** | **9,039** | 0 | 0 | 0 | 282 | 23,650 | 9,039 | 69.45% |
| ១១ | មណ្ឌលគិរី | **219** | **4,500** | **1,584** | 0 | 0 | 0 | 219 | 4,500 | 1,584 | **223** | **4,676** | **1,651** | 0 | 0 | 0 | 223 | 4,676 | 1,651 | 3.91% |
| ១២ | រាជធានីភ្នំពេញ | **24,819** | **743,764** | **413,113** | 719 | 325,276 | 245,340 | 24,100 | 418,488 | 167,773 | **25,757** | **938,590** | **519,457** | 807 | 377,431 | 283,353 | 24,950 | 561,159 | 236,104 | 26.19% |
| ១៣ | ព្រះវិហារ | **182** | **2,023** | **542** | 0 | 0 | 0 | 182 | 2,023 | 542 | **192** | **2,340** | **607** | 0 | 0 | 0 | 192 | 2,340 | 607 | 15.67% |
| ១៤ | ព្រៃវែង | **411** | **7,968** | **3,803** | 3 | 2,455 | 2,147 | 408 | 5,513 | 1,656 | **418** | **7,530** | **3,670** | 3 | 2,298 | 2,057 | 415 | 5,232 | 1,613 | -5.50% |
| ១៥ | ពោធិ៍សាត់ | **400** | **15,034** | **10,779** | 4 | 7,905 | 7,262 | 396 | 7,129 | 3,517 | **414** | **11,179** | **7,679** | 4 | 5,977 | 5,422 | 410 | 5,202 | 2,257 | -25.64% |
| ១៦ | រតនគិរី | **162** | **10,672** | **3,919** | 0 | 0 | 0 | 162 | 10,672 | 3,919 | **181** | **17,815** | **7,319** | 0 | 0 | 0 | 181 | 17,815 | 7,319 | 66.93% |
| ១៧ | សៀមរាប | **3,267** | **33,420** | **15,499** | 5 | 644 | 500 | 3,262 | 32,776 | 14,999 | **3,372** | **37,294** | **17,834** | 5 | 877 | 665 | 3,367 | 36,417 | 17,169 | 11.59% |
| ១៨ | ព្រះសីហនុ | **3,806** | **119,766** | **59,179** | 49 | 20,485 | 12,993 | 3,757 | 99,281 | 46,186 | **3,912** | **125,698** | **63,175** | 52 | 23,557 | 16,044 | 3,860 | 102,141 | 47,131 | 4.95% |
| ១៩ | ស្ទឹងត្រែង | **109** | **1,881** | **647** | 0 | 0 | 0 | 109 | 1,881 | 647 | **114** | **3,170** | **1,213** | 0 | 0 | 0 | 114 | 3,170 | 1,213 | 68.53% |
| ២០ | ស្វាយរៀង | **1,007** | **140,038** | **80,564** | 50 | 49,978 | 37,716 | 957 | 90,060 | 42,848 | **1,088** | **153,663** | **88,763** | 60 | 56,068 | 43,653 | 1,028 | 97,595 | 45,110 | 9.73% |
| ២១ | តាកែវ | **761** | **83,869** | **57,947** | 91 | 64,741 | 48,942 | 670 | 19,128 | 9,005 | **857** | **123,403** | **82,133** | 140 | 98,339 | 70,246 | 717 | 25,064 | 11,887 | 47.14% |
| ២២ | កែប | **95** | **1,117** | **632** | 1 | 353 | 321 | 94 | 764 | 311 | **102** | **1,508** | **956** | 1 | 686 | 607 | 101 | 822 | 349 | 35.00% |
| ២៣ | ប៉ៃលិន | **256** | **2,705** | **1,242** | 0 | 0 | 0 | 256 | 2,705 | 1,242 | **261** | **2,275** | **997** | 0 | 0 | 0 | 261 | 2,275 | 997 | -15.90% |
| ២៤ | ឧត្ដរមានជ័យ | **423** | **4,613** | **1,364** | 0 | 0 | 0 | 423 | 4,613 | 1,364 | **430** | **5,455** | **1,883** | 0 | 0 | 0 | 430 | 5,455 | 1,883 | 18.25% |
| ២៥ | ត្បូងឃ្មុំ | **385** | **13,598** | **5,025** | 2 | 1,293 | 1,172 | 383 | 12,305 | 3,853 | **390** | **13,457** | **6,023** | 3 | 1,478 | 1,356 | 387 | 11,979 | 4,667 | -1.04% |
| | សរុបរួម | **44,798** | **1,816,046** | **1,064,681** | **1,566** | **924,045** | **691,423** | **43,232** | **892,001** | **373,258** | **46,649** | **2,217,525** | **1,284,972** | **1,867** | **1,134,091** | **822,605** | **44,782** | **1,083,434** | **462,367** | **22.11%** |

ប្រភព ៖ នាយកដ្ឋានអធិការកិច្ចការងារ

## តារាង ១.៥ ការផ្ដល់សេវាមុខរបរ និងការងារឱ្យធ្វើ តាមរយៈសេវាការងារសាធារណៈ (NEA)

| ល.រ | បរិយាយ | ឯកតា | ២០២៤ | | ២០២៥ | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|---|
| | | | សរុប | ស្រី | សរុប | ស្រី | |
| ១ | អ្នកចុះឈ្មោះស្វែងរកការងារ | កម្រិតឧត្ដមសិក្សា | 25,272 | 13,709 | 8,849 | 4,962 | -64.98% |
| | | កម្រិតទុតិយភូមិ | 25,222 | 12,130 | 166,520 | 58,192 | 560.22% |
| | | កម្រិត (C1) | 7,275 | 2,550 | 2,985 | 1,946 | -58.97% |
| | | ជនពិការ | 277 | 117 | 256 | 204 | -7.58% |
| | | **សរុបរួម** | **50,494** | **25,839** | **175,369** | **63,154** | **247.31%** |
| ២ | ផ្គូផ្គងអ្នកស្វែងរកការងារទៅឱ្យនិយោជក | កម្រិតឧត្ដមសិក្សា | 78,748 | 48,234 | 12,396 | 7,034 | -84.26% |
| | | កម្រិតទុតិយភូមិ | 12,608 | 7,449 | 225,202 | 88,227 | 1,686.18% |
| | | កម្រិត (C1) | 3,544 | 741 | 2,922 | 1,189 | -17.55% |
| | | ជនពិការ | 28 | 18 | 58 | 4 | 107.14% |
| | | **សរុបរួម (ដង/នាក់)** | **94,900** | **56,424** | **240,520** | **96,450** | **153.45%** |
| ៣ | អ្នកទទួលបានការងារធ្វើ * | កម្រិតឧត្ដមសិក្សា | 4,799 | 2,666 | 1,227 | 648 | -74.43% |
| | | កម្រិតមធ្យមសិក្សា | 4,200 | 2,490 | 182,554 | 65,958 | 4,246.52% |
| | | កម្រិត (C1) | 789 | 162 | 1,462 | 88 | 85.30% |
| | | ជនពិការ | 24 | 12 | 16 | 0 | -33.33% |
| | | **សរុបរួម** | **9,788** | **5,318** | **185,243** | **66,694** | **1,792.55%** |

ប្រភព៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ

សម្គាល់៖ * អ្នកទទួលបានការងារធ្វើ គឺទទួលបានពីការបូកសរុបពីទិន្នន័យរដ្ឋបាលពីប្រភព NEA និងពីមន្ទីរ ក.ប. រាជធានី ខេត្ត។

## តារាង ១.៦ សិស្ស និស្សិត កម្មករនិយោជិត ទទួលបានកន្លែងកម្មសិក្សាការងារ

| ល.រ | បរិយាយ | | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| កម្មសិក្សាការងារសម្រាប់សិស្ស និស្សិត និងកម្មករនិយោជិត | | | | | | |
| ១ | ចុះឈ្មោះស្វែងរកកម្មសិក្សា | វេទិកាកម្មសិក្សា | ដង | 12 | 73 | 508.33% |
| | | | អ្នកចូលរួម | 1,584 | 14,123 | 791.60% |
| | | | អ្នកចុះឈ្មោះ | 86 | 3,672 | 4,169.77% |
| | | | ទទួលបានកម្មសិក្សា (បបម) | 0 | 787 | 100.00% |
| | | ទូទៅ | ជនពិការ | 2 | 0 | -100.00% |
| | | | សរុប | 19 | 406 | 2,036.84% |
| | | សរុប | ជនពិការ | 2 | 0 | -100.00% |
| | | | សរុប | 105 | 4,078 | 3,783.81% |
| ២ | ផ្គូផ្គងឱកាសកម្មសិក្សា | | ជនពិការ | 0 | 0 | - |
| | | | សរុប | 2,622 | 1,480 | -43.55% |
| ៣ | ទទួលបានកម្មសិក្សា | | ជនពិការ | 0 | 0 | - |
| | | | សរុប | 1,577 | 970 | -38.49% |

ប្រភព ៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## តារាង ១.៧ ពង្រីកវិសាលភាពសេវាការងារតាមរយៈមជ្ឈមណ្ឌលការងារចល័តនៅតាមគ្រឹះស្ថានសិក្សា និងតាមមូលដ្ឋាន/ទីប្រជុំជន

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ចុះផ្តល់សេវាការងារ និងព័ត៌មានទីផ្សារការងារដោយមជ្ឈមណ្ឌលការងារចល័ត (រថយន្ត) | | | | | |
| ១ | គ្រឹះស្ថានសិក្សា | ដង | 1,446 | 639 | -55.81% |
| | | ស្រី | 67,284 | 22,913 | -65.95% |
| | | អ្នកចូលរួម | 112,140 | 42,261 | -62.31% |
| ២ | មូលដ្ឋាន/ទីប្រជុំជន | ដង | 578 | 701 | 21.28% |
| | | ស្រី | 32,518 | 83,377 | 156.40% |
| | | អ្នកចូលរួម | 56,881 | 152,604 | 168.29% |
| សរុបរួម | | **ដង** | **2,024** | **1,340** | **-33.79%** |
| | | **ស្រី** | **99,802** | **106,290** | **6.50%** |
| | | **អ្នកចូលរួម** | **169,021** | **194,865** | **15.29%** |

ប្រភព ៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## តារាង ១.៨ ការលើកកម្ពស់យន្តការផ្សព្វផ្សាយ ដើម្បីជំរុញការប្រើប្រាស់សេវាការងារ និងព័ត៌មានទីផ្សារការងារ

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល(%) |
|---|---|---|---|---|---|
| ១ | ចុះជួបសហគ្រាសថ្មី និងបញ្ចូលព័ត៌មានក្រុមហ៊ុនទៅក្នុងប្រព័ន្ធផ្តល់សេវាការងារសាធារណៈ | សហគ្រាស | 421 | 1,096 | 160.33% |
| ២ | ទំនាក់ទំនង និងចុះជួបផ្ទាល់សហគ្រាស គ្រឹះស្ថាន ដើម្បីប្រមូលព័ត៌មានអំពីឱកាសការងារ និងពង្រឹងកិច្ចសហការ | ដង | 2,909 | 1,856 | -36.20% |
| | | សហគ្រាស | 2,154 | 1,366 | -36.58% |
| ៣ | ប្រមូល និងផ្សព្វផ្សាយព័ត៌មានឱកាសការងារពីគ្រប់ប្រភព | កន្លែង | 386,760 | 822,581 | 112.69% |
| ៤ | ក្រុមហ៊ុនដែលប្រកាសជ្រើសរើសកម្លាំងពលកម្ម | ក្រុមហ៊ុន | 0 | 694 | 100.00% |
| ៥ | ប្រមូល និងផ្សព្វផ្សាយវគ្គអប់រំបណ្តុះបណ្តាល និងអាហារូបករណ៍ពីគ្រប់ប្រភព | វគ្គ | 1,411 | 2,695 | 91.00% |
| ៦ | សិក្ខាសាលាជាមួយនិយោជក និងសហជីព | ដង | 13 | 3 | -76.92% |
| | | ស្រី | 213 | 98 | -53.99% |
| | | អ្នកចូលរួម | 562 | 264 | -53.02% |
| ៧ | ប្រមូលឱកាសកម្មសិក្សាការងារ | កន្លែង | 3,415 | 1,093 | -67.99% |
| ៨ | អ្នកចូលប្រើប្រាស់គេហទំព័រការងារ | លើក | 3,756,088 | 3,023,718 | -19.50% |
| ៩ | អ្នកទាញយកកម្មវិធីការងារលើទូរសព្ទដៃវៃឆ្លាត (Mobile App) | នាក់ | 16,827 | 6,494 | -61.41% |
| ១០ | អ្នកប្រើប្រាស់ទំព័រ Facebook | នាក់ | 463,074 | 1,064,929 | 129.97% |
| ១១ | អ្នកចូលរួមទស្សនាវីដេអូ TikTok | លើក | 2,442,792 | 2,492,863 | 2.05% |
| ១២ | អ្នកទទួលបានព័ត៌មានតាមរយៈ Youtube | លើក | 15,690 | 16,596 | 5.77% |

ប្រភព ៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ

៦៧

## តារាង ១.៩ ការងារស្ថិតិមុខរបរ និងហត្ថពលកម្ម

| ល.រ | បរិយាយ | ឯកតា | ២០២៤ | | | ២០២៥ | | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|---|---|---|
| | | | សរុប | ថ្នាក់កណ្ដាល | រាជធានីខេត្ត | សរុប | ថ្នាក់កណ្ដាល | រាជធានីខេត្ត | |
| ១ | ចុះបញ្ជិកាលើសេចក្ដីប្រកាសជូនដំណឹងស្ដីអំពីបុគ្គលិក (ចេញ) * | | | | | | | | |
| ១.១ | រោងចក្រ សហគ្រាស | សហគ្រាស | 17,565 | 16,684 | 881 | 21,424 | 19,071 | 2,353 | 21.97% |
| ១.២ | ចំនួនសំណើ | សំណើ | 18,909 | 18,011 | 898 | 23,636 | 21,219 | 2,417 | 25.00% |
| ១.៣ | កម្មករនិយោជិត | សរុប | 158,502 | 154,593 | 3,909 | 180,363 | 168,605 | 11,758 | 13.79% |
| | | ស្រី | 98,203 | 96,129 | 2,074 | 109,458 | 103,795 | 5,663 | 11.46% |
| ២ | ចុះបញ្ជិកាលើសេចក្ដីប្រកាសជូនដំណឹងស្ដីអំពីបុគ្គលិក (ចូល) * | | | | | | | | |
| ២.១ | រោងចក្រ សហគ្រាស | សហគ្រាស | 11,640 | 11,379 | 261 | 18,630 | 16,908 | 1,722 | 60.05% |
| ២.២ | ចំនួនសំណើ | សំណើ | 12,765 | 12,500 | 265 | 21,410 | 19,641 | 1,769 | 67.72% |
| ២.៣ | កម្មករនិយោជិត | សរុប | 96,017 | 93,795 | 2,222 | 149,369 | 142,085 | 7,284 | 55.57% |
| | | ស្រី | 59,127 | 58,104 | 1,023 | 91,863 | 88,939 | 2,924 | 55.37% |

ប្រភព ៖ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម

សម្គាល់ ៖ * គម្លាតខុសគ្នារវាងអំពីចលនាបុគ្គលិកចេញ និងចលនាបុគ្គលចូល គឺកម្មករនិយោជិតដែលប្ដូរសៀវភៅ និងបណ្ណការងារពីទម្រង់ចាស់ទៅទម្រង់ថ្មី មិនតម្រូវឱ្យធ្វើសេចក្ដីប្រកាសជូនដំណឹងអំពីចលនាបុគ្គលិកចូល ម្ដងទៀតទេ។

## តារាង ១.១០ ចំនួនទីភ្នាក់ងារឯកជនផ្ដល់សេវាកេការងារឱ្យធ្វើក្នុងស្រុកដែលបានចុះបញ្ជី

| ល.រ | បរិយាយ | ឯកតា | គិតត្រឹមឆ្នាំ២០២៤ | ២០២៥ | គិតត្រឹមឆ្នាំ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| ១ | ទីភ្នាក់ងារដែលទទួលបានចុះបញ្ជី | ទីភ្នាក់ងារ | 15 | 7 | 22 | 46.67% |
| ២ | ទីភ្នាក់ងារកំពុងដំណើរការ | ទីភ្នាក់ងារ | 15 | 7 | 22 | 46.67% |
| ៣ | ទីភ្នាក់ងារផ្អាកដំណើរការ | ទីភ្នាក់ងារ | 0 | 0 | 0 | - |
| ៤ | ទីភ្នាក់ងារដែលបិទ | ទីភ្នាក់ងារ | 0 | 0 | 0 | - |

ប្រភព ៖ នាយកដ្ឋានមុខរបរ និងហត្ថពលកម្ម

## តារាង ១.១១ ការពង្រីកការផ្តល់សេវាប្រឹក្សាយោបល់ និងមគ្គុទេសក៍ អាជីព ការងារ និងវិជ្ជាជីវៈ

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល (%) |
|---|---|---|---|---|---|
| ១ | ផ្តល់ប្រឹក្សាយោបល់អំពីអាជីពការងារ និងវិជ្ជាជីវៈ ទៅអ្នកស្វែងរកការងារ | ស្រី | 9,547 | 27,546 | 188.53% |
| | | អ្នកចូលរួម | 18,885 | 54,419 | 188.16% |
| ២ | រៀបចំសិក្ខាសាលាស្តីពីផែនការអាជីព និងជ្រើសរើសជំនាញសម្រាប់សិស្សបឋមភូមិ | ដង | 45 | 0 | -100.00% |
| | | ស្រី | 1,398 | 0 | -100.00% |
| | | អ្នកចូលរួម | 2,376 | 0 | -100.00% |
| ៣ | សិក្ខាសាលាស្តីពីផែនការអាជីព និងជ្រើសរើសជំនាញសម្រាប់សិស្សមធ្យមសិក្សាទុតិយភូមិ | ដង | 289 | 266 | -7.96% |
| | | ស្រី | 7,962 | 7,974 | 0.15% |
| | | អ្នកចូលរួម | 14,514 | 13,505 | -6.95% |
| ៤ | សិក្ខាសាលាស្តីពីការណែនាំអាជីពការងារ និងវិជ្ជាជីវៈ សម្រាប់សិស្ស និស្សិត នៅគ្រឹះស្ថានអប់រំបណ្តុះបណ្តាលបច្ចេកទេស និងវិជ្ជាជីវៈ និងសាកលវិទ្យាល័យ | ដង | 89 | 40 | -55.06% |
| | | ស្រី | 2,193 | 1,054 | -51.94% |
| | | អ្នកចូលរួម | 4,519 | 2,047 | -54.70% |
| ៥ | វគ្គបណ្តុះបណ្តាល ស្តីពីការត្រៀមលក្ខណសម្បត្តិក្នុងការស្វែងរកការងារ | វគ្គ | 116 | 68 | -41.38% |
| | | ស្រី | 1,980 | 979 | -50.56% |
| | | អ្នកចូលរួម | 5,546 | 2,138 | -61.45% |
| **សរុប** | | **ដង/វគ្គ** | **539** | **374** | **-30.61%** |
| | | **ស្រី** | **23,080** | **37,553** | **62.71%** |
| | | **អ្នកចូលរួម** | **45,840** | **72,109** | **57.31%** |

ប្រភព៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## តារាង ១.១២ បង្កើនផលិតភាពកម្លាំងដែលកំពុងស្ថិតក្នុងទីផ្សារការងារ

| ល.រ | បរិយាយ | ឯកតា | ២០២៤ | ២០២៥ | បម្រែបម្រួល(%) |
|---|---|---|---|---|---|
| ១ | វគ្គបណ្តុះបណ្តាលស្តីពីការលើកកម្ពស់ផលិតភាព និងសហគ្រិនភាពដល់សិស្ស និស្សិត អ្នកស្វែងរកការងារ និងកម្មករនិយោជិត | វគ្គ | 53 | 44 | -16.98% |
| | | ស្រី | 1,045 | 544 | -47.94% |
| | | សរុប | 1,834 | 1,176 | -35.88% |
| ២ | សហគ្រាស គ្រឹះស្ថានដែលបានបញ្ជូនកម្មករនិយោជិតឱ្យចូលរួមវគ្គបណ្តុះបណ្តាលអំពីជំនាញទន់ | សហគ្រាស | 3 | 139 | 4,533.33% |

ប្រភព ៖ ទីភ្នាក់ងារជាតិមុខរបរ និងការងារ

## តារាង ១.១៣ ការផ្តល់សៀវភៅការងារ និងបណ្ណសម្គាល់កម្មករនិយោជិតខ្មែរបែងចែកតាមទីតាំងភូមិសាស្ត្រ

| ល.រ | បរិយាយ | ២០២៤ | | ២០២៥ | | បម្រែបម្រួល (%) |
|---|---|---|---|---|---|---|
| | | សរុប | ស្រី | សរុប | ស្រី | |
| ១ | បន្ទាយមានជ័យ | 1,843 | 1,231 | 3,328 | 1,740 | 80.58% |
| ២ | បាត់ដំបង | 1,436 | 647 | 1,334 | 498 | -7.10% |
| ៣ | កំពង់ចាម | 9,377 | 7,967 | 6,441 | 5,050 | -31.31% |
| ៤ | កំពង់ឆ្នាំង | 13,721 | 11,061 | 8,516 | 4,921 | -37.93% |
| ៥ | កំពង់ស្ពឺ | 40,354 | 25,032 | 45,030 | 24,441 | 11.59% |
| ៦ | កំពង់ធំ | 3,117 | 1,364 | 2,905 | 1,214 | -6.80% |
| ៧ | កំពត | 2,894 | 1,832 | 3,348 | 1,878 | 15.69% |
| ៨ | កណ្តាល | 38,457 | 26,565 | 30,919 | 18,713 | -19.60% |
| ៩ | កោះកុង | 2,383 | 1,233 | 1,893 | 1,008 | -20.56% |
| ១០ | ក្រចេះ | 2,619 | 993 | 5,486 | 2,292 | 109.47% |
| ១១ | មណ្ឌលគិរី | 586 | 226 | 376 | 128 | -35.84% |
| ១២ | រាជធានីភ្នំពេញ | 118,374 | 74,800 | 100,690 | 60,693 | -14.94% |
| ១៣ | ព្រះវិហារ | 318 | 77 | 291 | 60 | -8.49% |
| ១៤ | ព្រៃវែង | 650 | 381 | 1,126 | 388 | 73.23% |
| ១៥ | ពោធិ៍សាត់ | 712 | 549 | 1,104 | 692 | 55.06% |
| ១៦ | រតនគិរី | 1,441 | 621 | 9,385 | 3,980 | 551.28% |
| ១៧ | សៀមរាប | 3,250 | 1,631 | 2,939 | 1,328 | -9.57% |
| ១៨ | ព្រះសីហនុ | 14,408 | 7,503 | 10,968 | 5,538 | -23.88% |
| ១៩ | ស្ទឹងត្រែង | 118 | 51 | 112 | 27 | -5.08% |
| ២០ | ស្វាយរៀង | 17,218 | 10,079 | 23,038 | 11,990 | 33.80% |
| ២១ | តាកែវ | 14,669 | 10,294 | 14,666 | 8,405 | -0.02% |
| ២២ | ឧត្តរមានជ័យ | 188 | 41 | 373 | 110 | 98.40% |
| ២៣ | កែប | 31 | 11 | 131 | 103 | 322.58% |
